ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- សវនាការចុងក្រោយរបស់មេដឹកនាំខ្មែរក្រហម
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តពោធិ៍សាត់ ទទួលបានកញ្ចប់អនុស្សាវរីយ៍
- សមរភូមិផ្លូវច្បាប់ចុងក្រោយបង្អស់នៅក្នុងការកាត់សេចក្តីនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦០ ខែសីហា ឆ្នាំ២០២១

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦០ ខែសីហា ឆ្នាំ២០២១

# មាតិកា

## សំបុត្រ

◆ សវនាការចុងក្រោយរបស់មេដឹកនាំ........១

## ផ្នែកឯកសារ

◆ ខៀវ សានះ នយោបាយវរសេនាធំ៨២... ៤

## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

### អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានកញ្ចប់អនុស្សាវរីយ៍

◆ ខេត្តពោធិ៍សាត់................................៧
◆ ខេត្តសៀមរាប ..............................១០
◆ ខេត្តតាកែវ ..................................១២
◆ ខេត្តកំពង់ចាម ..............................១៤
◆ ខេត្តស្វាយរៀង ..............................១៥
◆ អតីតកងចល័តយុវជនឃុំអន្លង់មៀន.....១៧
◆ បទចម្រៀង «ឱ! ភ្នំពេញអើយ» បានរំឭកអំពីការបង់ចាំ.....................២០
◆ ជីវិតអកុសលរបស់ម្ដាយខ្ញុំ ..............២២
◆ ថោង សានះ អតីតកងឈ្លបឃុំ.......... ២៨
◆ ទិត្យ ដា ស្ត្រីមេម៉ាយក្នុងរបបខ្មែរ ........ ៣១
◆ សៀវភៅ «នរោត្ដម សីហនុ និង ជូ អេនឡាយ៖ មិត្តភាពដ៏កម្រ.............៣៥
◆ ម៉ម ស្រឿន អតីតកងដឹកជញ្ជូន.......... ៣៧
◆ ខ្ញុំធ្វើដំណើរជាមួយសាកសព............. ៣៩
◆ សិល្បៈភូមិត្រពាំងត្រស់ .....................៤៣
◆ ប្រវត្តិសាស្ត្រគ្រួសារនៅខេត្តត្បូងឃ្មុំ..... ៤៦

## ផ្នែកច្បាប់

◆ សាលក្រមសំណុំរឿង០០២/០២ ........ ៥២

## ផ្នែកវេទិកាសាធារណៈ

◆ សមរភូមិផ្លូវច្បាប់ចុងក្រោយបង្អស់..... ៥៨



ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)។

## ផ្នែកស្រាវជ្រាវរកគ្រួសារ

### «ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

◆ ម៉ាក ទុន៖ អ្នកធាក់ស៊ីក្លូ ......................៦០

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ ៖** ឆាំង យុ, សោម ប៊ុនថន, វី លក្ខិណា, ស៊ាង ចិន្តា, ភា រស្មី, កែម សុភី, គាត ស្រីឡែន, ហ៊ាន ពិសី, ទូច វណ្ណេត, មីន សាណាស់, មេក វិន, ដារ៉ារដ្ឋ មេត្តា, មេន នឿន, ដេង ពង្សរ៉ាស៊ី, ប៊ាង ពីរីន្ត និង វេនី ខកហៀល
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# សវនាការចុងក្រោយរបស់មេដឹកនាំខ្មែរក្រហម

ឆាំង យុ




អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ធ្វើព្យុះហយាត្រាដើម្បីយុត្តិធម៌។ នៅលើបដាសរសេរថា៖ “អង្គជំនុំជម្រះវិសាមញ្ញ ជាឱសថរំងាប់ការចងពៀរ”។
រូបថតនេះ ទទួលបានពីកម្មវិធីផ្សព្វផ្សាយអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលកម្មវិធីនេះបាននាំយកអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរាប់ម៉ឺននាក់ ពីបណ្ដាភូមិនានា មកទស្សនាស្ដាប់សវនាការរបស់សាលាក្ដីខ្មែរក្រហម ធ្វើទស្សនកិច្ចទៅកាន់ទីតាំងឧក្រិដ្ឋកម្ម និងស្តូបរំលឹកវិញ្ញាណក្ខន្ធ និងជួបជាមួយថ្នាក់ដឹកនាំសហគមន៍អន្តរជាតិនានានៅរាជធានីភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខណៈដែលយើងចាប់ផ្តើមស្តាប់សវនាការជាសាធារណៈចុងក្រោយរបស់មេដឹកនាំខ្មែរក្រហម ធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅថា សាលាក្ដីខ្មែរក្រហម យើងចាំបាច់មិនត្រឹមតែពិចារណាទៅលើកិច្ចការដ៏សំខាន់របស់សាលាក្ដីខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែទៅលើការងារដ៏មានសារប្រយោជន៍ដទៃៗទៀត ដែលស្ថិតនៅចំពោះមុខរបស់យើងថែមទៀតផង។

វត្តមានរបស់សាលាក្ដីខ្មែរក្រហម គឺដោយសារអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ការទាមទាររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យមានតុលាការគឺពិតជាចាំបាច់ក្នុងការបង្កើតសាលាក្ដីខ្មែរក្រហមនេះឡើង។ ថ្វីត្បិតតែការបង្កើតសាលាក្ដីនេះត្រូវចំណាយពេលអស់ជាយូរ ហើយសាលាក្ដីខ្មែរក្រហម ត្រូវចំណាយពេលវេលារឹតតែយូរថែមទៀតក្នុងការបំពេញការងារ

របស់ខ្លួន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែបន្តអត់ធ្មត់ ពីព្រោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ ពិតជាចង់ផ្តល់ឱកាស និងភាពស្របច្បាប់ដល់សាលាក្តី ខ្មែរក្រហម រហូតដល់សវនាការចុងក្រោយរបស់ខ្លួន។

សាលាក្តីខ្មែរក្រហម សម្រេចបានការផ្តន្ទាទោសលើអតីតប្រធានមន្ទីរឃុំឃាំង ស-២១ និងមេដឹកនាំជាន់ខ្ពស់ពីររូបនៃរបបខ្មែរក្រហម រួមមាន នួន ជា និងខៀវ សំផន។ ជាការពិតណាស់ ខណៈដែលសាលាក្តីខ្មែរក្រហម នឹងត្រូវបានចងចាំអំពីលទ្ធផលនៃការផ្តន្ទាទោសដែលខ្លួនសម្រេចបាន សាលាក្តីខ្មែរក្រហម ក៏នឹងត្រូវបានសាធារណជនចងចាំអំពីសាលក្រមនានាដែលខ្លួនមិនដែលបានសម្រេចទាល់តែសោះ។

ប៉ុន្តែយើងអាចនឹងមានភាពឆ្គាំឆ្គង ប្រសិនបើយើងវាយតម្លៃសារសំខាន់នៃសាលាក្តីខ្មែរក្រហម ដោយផ្អែកទៅលើតែការផ្តន្ទាទោសដែលសាលាក្តីនេះសម្រេចបាន។ ក្នុងកាលៈទេសៈជាច្រើន សាលាក្តីខ្មែរក្រហម បានជួយស្រាយបំភ្លឺអំពីជំពូកដ៏ខ្មៅងងឹតនៅក្នុងប្រវត្តិសាស្ត្រ ហើយទោះបីជាមិនដោយផ្ទាល់ក្តី សាលាក្តីនេះបានជះឥទ្ធិពលទៅលើយុត្តិធម៌ជាច្រើនសណ្ឋានទៀត ដែលសង្គមកម្ពុជាកំពុងតែទាមទារ។ សាលាក្តី ខ្មែរក្រហម បានផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនោះរួមមានជនរងគ្រោះនៃរបបខ្មែរក្រហមជាច្រើនរូប នូវឱកាសក្នុងការនិយាយរៀបរាប់អំពីបទពិសោធន៍ផ្ទាល់ខ្លួន និងបទពិសោធន៍របស់ក្រុមគ្រួសារខ្លួន។ ទន្ទឹមនឹងនេះ សាលាក្តីខ្មែរក្រហម បានបង្កើតជាកំណត់ត្រាតាមផ្លូវច្បាប់យ៉ាងលម្អិតអំពីការដែលអំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើឃោរឃៅជាច្រើនផ្សេងទៀត ត្រូវបានប្រព្រឹត្តឡើង។ ដោយគ្មានមន្ទិលសង្ស័យ សាលាក្តីខ្មែរក្រហម បានជួយឲ្យសង្គមកម្ពុជា មិនត្រឹមតែប្រឈមតទល់នឹងប្រវត្តិសាស្ត្ររបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រសោបយកប្រវត្តិសាស្ត្រនេះ ធ្វើជាមេរៀនសោកនាដកម្មមួយ សម្រាប់ប្រជាជនកម្ពុជានិងពិភពលោកទាំងមូល។

នៅក្នុងអំឡុងរបបខ្មែរក្រហម (ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ខ្មែរក្រហម ប៉ុនប៉ងធ្វើគ្រប់សព្វបែបយ៉ាងដើម្បីបំផ្លាញវប្បធម៌ សម្ព័ន្ធភាពគ្រួសារ និងសូម្បីតែការចងចាំរបស់មនុស្ស។ នៅទីបំផុត មនោគមវិជ្ជាជ្រុលនិយមរបស់ខ្មែរក្រហម បានបណ្តាលឲ្យប្រជាជនកម្ពុជាជាងពីរលាននាក់បាត់បង់ជីវិត។ នៅពេលដែលសាលាក្តីខ្មែរក្រហមបិទបញ្ចប់ប្រតិបត្តិការ យើងមិនត្រូវបញ្ឈប់កិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការថែរក្សាការចងចាំ, ការសិក្សា និងការផ្សព្វផ្សាយនូវមេរៀនអំពីប្រវត្តិសាស្ត្រនេះ នៅក្នុងប្រទេសកម្ពុជា និងទៅកាន់ពិភពលោកនោះឡើយ។



អ្នករស់មានជីវិតពីរបបខ្មែរក្រហម ធ្វើព្យុះហយាត្រាដើម្បីយុត្តិធម៌នៅខេត្តសៀមរាប នៅឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្នុងអំឡុងទស្សនកិច្ចមកកាន់សាលាក្តីខ្មែរក្រហម អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានជួបជាមួយនឹងអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេប អេ. មូស្សូមេលី នៅឯលំនៅឋានរបស់លោក ក្នុងឆ្នាំ២០០៧។ រូបថតនេះ ទទួលបានពីកម្មវិធីផ្សព្វផ្សាយអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលកម្មវិធីនេះបាននាំយកអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរាប់ម៉ឺននាក់ពីបណ្តាភូមិនានាមកទស្សនាស្តាប់សវនាការរបស់សាលាក្តីខ្មែរក្រហមធ្វើទស្សនកិច្ចទៅកាន់ទីតាំងខត្រិដ្ឋកម្ម និងស្តូបរំឭក និងជួបជាមួយថ្នាក់ដឹកនាំសហគមន៍អន្តរជាតិនានានៅរាជធានីភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជារឿយៗ មានការយល់ខុសថា «ប្រវត្តិសាស្ត្រត្រូវបានសរសេរឡើងដោយអ្នកឈ្នះ» ។ នេះមិនមែនជាការពិតនោះទេ ហើយប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាគឺជាការសបញ្ជាក់ស្រាប់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺមិនមែនជាអ្នកឈ្នះនោះទេ ប៉ុន្តែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគឺជាវីរជន។ ដូច្នេះយើងត្រូវតែចងក្រងប្រវត្តិសាស្ត្ររៀបរាប់ដោយផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាវីរជនទាំងអស់នេះ។ ប្រវត្តិសាស្ត្រភាគច្រើនកើតចេញមកពីប្រវត្តិសាស្ត្ររៀបរាប់ដោយផ្ទាល់មាត់។ យើងត្រូវតែទទួលស្គាល់អំពីតួនាទីដ៏មានសារសំខាន់នៃប្រវត្តិសាស្ត្ររៀបរាប់ដោយផ្ទាល់មាត់ នៅក្នុងកិច្ចការប្រកបដោយសារប្រយោជន៍ដែលស្ថិតនៅចំពោះមុខយើង។

ការបិទបញ្ចប់របស់សាលាក្តីខ្មែរក្រហមក្នុងពេលខាងមុខនេះ គឺត្រូវទទួលស្គាល់ថាជាការចាប់ផ្តើមនៃជំពូកថ្មីមួយ ក្នុងការស្វែងរកយុត្តិធម៌របស់ប្រទេសកម្ពុជា។ ជំពូកថ្មីសន្ទាងសម្រាប់ប្រជាជនកម្ពុជានេះគឺត្រូវតែដាក់ចេញជាកិច្ចខិតខំប្រឹងប្រែងថ្មីៗ ដែលសាលាក្តីខ្មែរក្រហម មិនអាចសម្រេចបាន។ យើងត្រូវតែយកចិត្តទុកដាក់ថែទាំចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានចំនួនយ៉ាងហោចណាស់ ៥ លាននាក់ ដែលគឺជាក្រុមប្រជាជនងាយរងគ្រោះបំផុតនៅក្នុងប្រទេសកម្ពុជា។ យើងត្រូវតែបន្តពង្រឹងការចងក្រងប្រវត្តិសាស្ត្រ រួមបញ្ចូលនូវការប្រមែប្រមូលប្រវត្តិសាស្ត្ររៀបរាប់ដោយផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដោយប្រវត្តិសាស្ត្រនេះផ្ទាល់ គឺជាដំណើរការនៃការធ្វើឲ្យជាសះស្បើយ និងការផ្សះផ្សា។ យើងត្រូវតែព្យាយាមប្រើប្រាស់កំណត់ត្រាប្រវត្តិសាស្ត្រនេះ ជាមេរៀនមួយសម្រាប់យុវជន-យុវនារីជំនាន់ក្រោយរបស់កម្ពុជា និងពិភពលោក។

នៅចុងបញ្ចប់ នាពេលដែលសាលាក្តីខ្មែរក្រហមបិទបញ្ចប់ប្រតិបត្តិការរបស់ខ្លួន ជួយទៅវិញការងាររបស់យើងមិនទាន់បញ្ចប់នៅឡើយទេ។ យើងត្រូវតែខិតខំប្រឹងប្រែងបំពេញការងារដោយស្មោះអស់ពីចិត្ត ដើម្បីបង្កើតបានជាសង្គមកម្ពុជាមួយ ដែលក្រសោបយកប្រវត្តិសាស្ត្រនៃសោកនាដកម្មរបស់ខ្លួន ដែលមិនមែនក្នុងនាមជាជនរងគ្រោះ ប៉ុន្តែគឺជាវីរជនដែលរស់រានមានជីវិតពីរបបនេះ ដោយប្តេជ្ញាសម្រេចឲ្យបាននូវអនាគតមួយដែលសុខដុម ចម្រុងចម្រើននិងមានការចូលរួមពីប្រជាជនគ្រប់រូប។

# ខៀវ សានៈ នយោបាយវរសេនាធំ៨២

ដារ៉ាវដ្ឋ មេត្តា



កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ នៅពេលផ្តល់ព័ត៌មានទាក់ទីងអ្នកទោសជនជាតិបរទេសដែលត្រូវបានចាប់ខ្លួននិងឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ដល់ សីរិ សាវីណា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (អេង កុកថាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ខៀវ សាន អាយុ៣០ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានទីកន្លែងកំណើតនៅឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ឪពុករបស់ខ្ញុំឈ្មោះ ខៀវ អឹម និងម្តាយខ្ញុំឈ្មោះ ញ៉ែម លីម។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន ៥នាក់ គឺស្រីចំនួន៣នាក់ និងប្រុសចំនួន២នាក់។

ខ្ញុំរស់នៅជាមួយឪពុកម្តាយរហូតដល់ខ្ញុំមានអាយុ ១២ឆ្នាំ។ ក្រោយមកខ្ញុំទៅនៅជាមួយបងស្រីខ្ញុំ។ ខ្ញុំរស់នៅជាមួយបងស្រីរយៈពេល២ឆ្នាំ ឪពុកម្តាយខ្ញុំនាំខ្ញុំទៅរស់នៅជាមួយគាត់វិញ។

ខ្ញុំចូលបដិវត្តន៍នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧២។ ដំបូងខ្ញុំនៅក្នុងអង្គភាពដឹកជញ្ជូនរបស់កងវរសេនាធំលេខ៣៩ ដោយអ្នកទទួលខុសត្រូវឈ្មោះ ជ័យ មាននាទី គឺជាប្រធានវរសេនាធំ។ មួយរយៈក្រោយមកខ្ញុំផ្លាស់មកនៅកងថ្មើរជើងនៃកងវរសេនាធំលេខ ៣៩ ដែលមានអ្នកទទួលខុសត្រូវឈ្មោះ រ៉ុ គឺជានយោបាយកងវរសេនាធំ៣៩។ បន្ទាប់មកទៀត ខ្ញុំផ្លាស់មកនៅកងវរសេនាតូចលេខ២១៨ ភូមិភាគពិសេស ដោយមានអ្នកទទួលខុសត្រូវឈ្មោះ ទាប គឺជានយោបាយវរសេនាតូច។ ក្រោយមក ឈ្មោះ ឌួង មកទទួលខុសត្រូវកងវរសេនាតូចលេខ ២១៨ ជំនួស ទាប វិញ។ នៅអំឡុងពេលនោះ អង្គការបានរៀបចំបញ្ចូលកងវរសេនាតូចទៅជាកងពលលេខ១៤ ហើយខ្ញុំនៅអង្គភាពនេះរហូតដល់រំដោះបានទីក្រុងភ្នំពេញ។ ក្រោយមកអង្គការរៀបចំបង្កើតកងពល៨០១ថ្មី។

ក្រោយពីអង្គការរៀបចំកងពល៨០១ ដោយបានបញ្ចូលកម្លាំងមកពីអង្គភាពផ្សេងៗរួចហើយ អង្គការបានចាត់តាំងកងពល៨០១ មកឈរជើងការពារព្រំដែននៅភូមិភាគឦសាន។ ពេលយើងធ្វើដំណើរដល់ភូមិភាគឦសាន អង្គភាពរបស់ខ្ញុំបានសម្រេចចិត្តនាំគ្នាសម្រាកនៅភូមិបាបាំង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។ ខ្ញុំសម្រាកនៅផ្ទះប្រជាជនឈ្មោះ ថន គឺជា

សមាជិកសហករណ៍ នៅក្នុងភូមិនេះ។ ក្នុងរយៈពេលដែលខ្ញុំរស់នៅក្នុងភូមិបាប៉ាំងនេះ ខ្ញុំមិនទាន់ស្គាល់ ថន ច្បាស់ទេ។ នៅបានរយៈពេល៤ ទៅ៥ថ្ងៃ ខ្ញុំនិងថនទាក់ទងស្គាល់គ្នាបន្តិចម្តងៗដោយមានការលេងសើចនិងនិយាយពីនេះពីនោះ។ ថនយកចិត្តទុកដាក់ចំពោះខ្ញុំណាស់។ គាត់មានម្ហូនអ្វីឆ្ងាញ់តែងចែករំលែកដល់ខ្ញុំ។ ថ្ងៃមួយ ខ្ញុំបានអង្គុយលេងជាមួយ ថនរួចខ្ញុំសួរគាត់អំពីជីវភាពរស់នៅក្នុងស្រុកសៀមប៉ាង។ ថនប្រាប់ថាកាលពីមុនជីវភាពនៅក្នុងស្រុកសៀមប៉ាងសប្បាយណាស់និងមានការហូបចុកគ្រប់គ្រាន់។

នៅខែមីនាឆ្នាំ១៩៧៦ថននាំប្រជាជនចំនួន៤នាក់រត់ទៅប្រទេសឡាវ ចាប់តាំងពីពេលនោះមកខ្ញុំបានដាច់ការទាក់ទងជាមួយឈ្មោះ ថន មួយរយៈ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ពេលនោះមានឈ្មោះ លី នាទីជានយោបាយអនុសេនាធំ២២៣ វរសេនាតូច៨២២ វរសេនាធំ៨២ ចាប់ផ្តើមអប់រំអូសទាញរូបខ្ញុំឲ្យក្បត់បដិវត្តន៍។ នៅពេលដែលខ្ញុំធ្វើការពេលល្ងាចចប់ និងបន្ទាប់ពីហូបបាយរួច ឈ្មោះ លី ហៅខ្ញុំសួរអំពីលទ្ធផលការងារប្រចាំថ្ងៃ។ ទៅដល់ភ្លាម លី សួរខ្ញុំថា ផ្ទះដែលធ្វើពីថ្ងៃមុនធ្វើបានប៉ុន្មានខ្នងហើយ? ខ្ញុំឆ្លើយប្រាប់ លី ថានៅខ្វះ ផ្ទាន ផ្តោង និង សសរ។ បន្ទាប់មក លី បាននិយាយប្រាប់ផែនការឲ្យខ្ញុំដឹងនិងយកទៅអនុវត្តទៅថ្ងៃមុខៗ តមក លី ឃាត់ខ្ញុំឲ្យនៅនិយាយលេងជាមួយគាត់សិន។ ក្រោយពីជជែកគ្នាលេង លី លើកឡើងអំពីស្រុកពីដើមប្រាកដជាសប្បាយ មានផ្សារអ៊ូអរគគ្រឹកគគ្រេង។ លី និយាយប្រសិនបើដូចបង សាន ឯងពីមុនវិញប្រហែលជាមានស័ក្តិពាក់បាត់ទៅហើយ ព្រោះ សាន ឯងធ្វើការល្អយ៉ាងហ្នឹង។ ខ្ញុំនិយាយប្រាប់ លី ថាធ្វើយ៉ាងម៉េចព្រោះខ្ញុំធ្វើបដិវត្តន៍សង្គមនិយមទៅហើយមិនងាយនឹងកែប្រែទេ។ លីតបវិញថាងាយទេឲ្យតែខ្ញុំយល់ព្រមពិតជាធ្វើបាន។ ខ្ញុំស្តាប់ទៅបង លី ដូចជាមានគោលគំនិតដូចខ្ញុំដែរ។ បើពិតមែនខ្ញុំអរខ្លាំងណាស់។ ខ្ញុំយល់ព្រមនិយាយជាមួយគាត់ហើយថ្ងៃក្រោយគាត់ប្រាប់ខ្ញុំនឹងត្រូវធ្វើអ្វីខ្លះ។ ក្រោយមករំលងបាន១០ថ្ងៃ លីបានហៅខ្ញុំទៅជួបនៅក្រោមផ្ទះរបស់គាត់។ លីឲ្យខ្ញុំធ្វើសកម្មភាពប្រឆាំងមាគ៌ាបដិវត្តន៍ឲ្យខ្លាំងក្លា តាមគ្រប់រូបភាពជាក់ស្តែងប្រសិនបើបក្សមិនឲ្យធ្វើអ្វីត្រូវតែធ្វើហ្នឹង ត្រូវបំផុសអង្គភាពខាងស្រីញីពាលាអាវ៉ាសែ ធ្វើយ៉ាងណាឲ្យអង្គភាពនោះរង្គោះរង្គើ, ត្រូវបំផុសយុវជនឲ្យសេរី, ខ្ជិលធ្វើការងារ, ត្រូវតាមដានអប់រំ និងចាត់តាំងគិញនិងខ្សែរយៈឲ្យច្រើន ពិសេសត្រូវជួយរកខ្សែខាងក្នុងនិងក្រៅអង្គភាព។ ក្រោយពីទទួលផែនការ និងការអប់រំខ្ញុំបានធ្វើសកម្មភាពជាបន្តបន្ទាប់ បំផុសយុទ្ធជនមិនឲ្យធ្វើផ្ទះស្អាត គុណភាពមិនឲ្យជាប់បានយូរ ទាំងដំបូលរនាប និងជញ្ជាំង។ ខ្ជិលដឹកនាំយុទ្ធជននៅក្នុងអង្គភាពពិសេសបញ្ហាជីវភាព ដឹកនាំមិនឲ្យឯកភាពជាមួយអ្នកដឹកនាំបង្កទំនាស់ បំផុសយុទ្ធជនឲ្យខ្ជិលធ្វើការងារ បង្កឲ្យយុទ្ធមានទំនាស់នឹងការស៊ីចុកនៅក្នុងអង្គភាព។

នៅខែមេសា ឆ្នាំ១៩៧៧ ថនត្រឡប់មកពីឡាវវិញ។ ការត្រឡប់មកវិញលើកនេះ ថនមិនបានចូលក្នុងភូមិស្រុកទេ គាត់ធ្វើការសម្ងាត់ឲ្យ ឡាវ ចេញចូលដីកម្ពុជា ឡាវ។ ថន ឲ្យខ្ញុំអនុវត្តនិងចាត់តាំងខ្សែរយៈដែលប្រឆាំងនឹងបដិវត្តន៍ឲ្យបានច្រើន បំផ្លាញសម្ភារ បំផុសសីលធម៌ និង លាក់ការណ៍សម្ងាត់ឲ្យបាន។ ក្រោយពីដាក់ផែនការហើយ ថន កំណត់ពេលវេលា និងខ្សែរយៈដែលទាក់ទងមានសមមិត្ត លឿន នៅអង្គភាពវរសេនាតូច ៨២១, ប៊ូម និង សមមិត្ត វ៉ែន ដែលធ្វើនៅកងវរសេនាតូច ៨២១ វរសេនាធំ ៨២។ អ្នកទាំងបីនាក់នេះធ្វើការនៅក្នុងអង្គភាពទ័ព។ ថនបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំមានធុរៈអ្វីត្រូវទាក់ទងជាមួយឈ្មោះ ហួត។ ប្រសិនបើ ហួត បញ្ជាមកឲ្យខ្ញុំធ្វើអ្វី ត្រូវទទួលបញ្ជាពី ហួត ព្រោះគាត់ប្រគល់ភារកិច្ចខាងក្នុងឲ្យ ហួត ជាអ្នកទទួលខុសត្រូវ។ ថន គឺជាភ្នាក់ងារសម្ងាត់របស់ ឡាវ ធ្វើការទាក់ទងចេញចូលក្តាប់សភាពការណ៍ប្រទេសកម្ពុជាឲ្យប្រទេស ឡាវ យូៗបានគាត់មកប្រទេសកម្ពុជាម្តងៗ។ ខ្ញុំបានសួរសភាពការណ៍នៅក្នុងប្រទេសឡាវ ពី ថន។ ថន ប្រាប់ថា ប្រទេសឡាវឥឡូវកំពុងតែសម្បូរសប្បាយណាស់។ ខ្ញុំសុំគាត់ទៅប្រទេសឡាវ ចង់ឃើញផ្ទាល់ភ្នែកដែរ។ ថន ប្រាប់ខ្ញុំថាបើចង់ទៅ ត្រូវខិតខំធ្វើការចាត់តាំងខ្សែរយៈ បំផុសឲ្យ

ប្រឆាំងមាគ៌ាបដិវត្តន៍ឲ្យបានខ្លាំងក្លា រង់ចាំដល់ឆ្នាំ ១៩៧៨ ខ្ញុំអាចទៅបានហើយ។

នៅថ្ងៃទី២៥ ខែឧសភា ពេលខ្ញុំដើរទៅ ហូបបាយ ផាន នៅវរសេនាតូច៨២២ វរសេនាធំ៨២ កងពល ២២២ បានហៅខ្ញុំទៅកំពង់ទឹកនៅ ខាងជើងរោង បាយ។ នៅពេលខ្ញុំទៅដល់ ផាន សួរខ្ញុំថា ជាខ្សែរយៈ របស់ ថន មែនទេ ។ ផាន អប់រំខ្ញុំឲ្យធ្វើសកម្មភាពឲ្យ ខ្លាំងក្លា សកម្មប្រយុទ្ធខ្លាំងឡើង យើងនឹងទទួលបាន ជ័យជម្នះនៅថ្ងៃអនាគត។ អង្គការរបស់យើងមាន បង ឡាយ សារឹម ហើយមានបងៗខាងលើទៀត។

នៅថ្ងៃទៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ វេលា ម៉ោងប្រហែលជា៩យប់ ខ្ញុំឃើញភ្លើងស៊ីញ៉ូម្ដុំអូរ សៀមប៉ាង ដែលជាទីតាំងរបស់កងវរ៨២២។ ក្រោយពីឃើញភ្លើងសញ្ញានេះខ្ញុំដឹងថា ថនមករកខ្ញុំ។ លុះព្រឹកឡើងខ្ញុំដើរទៅកាន់កន្លែងភ្លើងនោះមាន ឈ្មោះ លឿន កំពុងឈរអែបគល់ឈើដើរស្រែក ហៅខ្ញុំ។ ខ្ញុំដើរទៅចាប់ដៃលឿននិងសួរសុខទុក្ខ។ លឿន នាំខ្ញុំចូលក្នុងព្រៃដែលមានចម្ងាយប្រហែលជា ១៥០ ម៉ែត្រ។ នៅក្នុងព្រៃខ្ញុំឃើញ ចូម, វ៉ែន នៅអង្គភាព វរសេនាតូច៨២១ អង្គុយនៅក្រោមដើមស្វាយធំមួយ ហើយងើបមកស្វាគមន៍ខ្ញុំ។ ខ្ញុំរាយការណ៍អំពីសកម្មភាព ដែលខ្ញុំបានធ្វើ ហើយអ្នកទាំងនោះបានបញ្ចូលខ្ញុំជា សេ.អ៊ី.អា របស់ ឡាវ។ ថន គឺជាប្រធានអង្គប្រជុំបាន ប្រកាសកម្មវិធីនិងនិយាយអំពីគុណសម្បត្តិដែលខ្ញុំ ធ្វើសកម្មភាពប្រឆាំងជាមួយបដិវត្តន៍កន្លងមក។ សកម្មភាពរបស់ខ្ញុំប្រឆាំងបដិវត្តន៍ បានធ្វើជាបន្ត បន្ទាប់រហូតដល់អង្គការចាប់ខ្លួនថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖** អត្ថបទនេះដកស្រង់ចេញពីចម្លើយ សារភាពឯកសារ J00៤៧៩។ រាល់ចម្លើយសារភាព របស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរ ពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិន អាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ខៀវ សាន ពិត ប៉ុយ៉ាងណានោះទេ។



យោធាខ្មែរក្រហម នៅអំឡុងឆ្នាំ១៩៧៥-១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តពោធិ៍សាត់ទទួលបានកញ្ចប់អនុស្សាវរីយ៍

*សោម ប៊ុនថន និង ដាព័រដ្ឋ មេត្តា*



*អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងសហគមន៍ជនជាតិភាគតិចចាម នៅឃុំអូរសណ្តាន់ ក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ទទួលកញ្ចប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តពោធិ៍សាត់)*

អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងខេត្តពោធិ៍សាត់ចំនួន១០នាក់ ក្នុងចំណោមអ្នកស្ម័គ្រចិត្តកម្ពុជាចំនួន ៥០០នាក់ នៅតាមតំបន់ជនបទដាច់ស្រយាលក្នុងប្រទេសកម្ពុជា កំពុងចុះសួរសុខទុក្ខ និងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីក្នុងរបបខ្មែរក្រហម។ រាល់ព័ត៌មានដែលអ្នកស្ម័គ្រចិត្តកម្ពុជាទទួលបានពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះ នឹងត្រូវប្រើប្រាស់សម្រាប់៖ ១) វាស់ស្ទង់ការយល់ឃើញពីដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការយល់ឃើញអំពីដំណើរការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបញ្ចប់ទៅ, ២) សិក្សាអំពីវិស័យសុខភាពសាធារណៈ, ៣) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ៤) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ៥) ដើម្បីសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតាមសហគមន៍ដាច់ស្រយាលសម្រាប់ផ្តល់ជាព័ត៌មានក្នុងការរៀបចំ

ជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជន និងសហគមន៍។

នៅរសៀលថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅខេត្តពោធិ៍សាត់បាននាំយកកញ្ចប់អនុស្សាវរីយ៍ចំនួន ២៨ ដែលរួមមាន ព្រឹត្តិបត្រព័ត៌មាន ណែនាំអំពីសុខភាព, សាប៊ូលាងដៃ, ម៉ាស់, នំ, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩),សៀវភៅអំពីប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក,ឧបករណ៍សង្គ្រោះបឋម, សេវាកម្មពិនិត្យសុខភាពនៅតាមមន្ទីរពេទ្យឯកជនក្នុងសហគមន៍ដោយឥតគិតថ្លៃ, សម្ភារជំនួយដល់ជនពិការ រួមជាមួយកាបូបស្ពាយ និងអាវយឺតទៅចែកជូនអ្នករស់មានជីវិតពីរបបខ្មែរក្រហមនៅក្នុងសហគមន៍ជនជាតិភាគតិចចាម នៅឃុំអូរសណ្ដាន់ ក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលខ្លួនបានចុះជួបសួរសុខទុក្ខ និងបានស្ដាប់រឿងរ៉ាវរបស់គាត់កន្លងមក។

ស្មាន់ សៀរ ភេទស្រី អាយុ៧៨ឆ្នាំ រស់នៅក្នុងឃុំអូរសណ្ដាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានប្រសាសន៍ថា «ខ្ញុំនិយាយរឿងរ៉ាវដែលខ្ញុំនៅចងចាំជាងគេទៅកាន់អ្នកស្ម័គ្រចិត្តកម្ពុជា គឺនៅពេលដែលខ្មែរក្រហមចូលមកចាត់តាំងខ្ញុំនិងប្រជាជនផ្សេងទៀតឲ្យទៅជីកប្រឡាយនៅភូមិថ្មីកំពង់ពោធិ៍ និងកំពង់ឡ។ យើងធ្វើការច្រើនម៉ោងទាំងយប់ទាំងថ្ងៃដោយមិនបានសម្រាក គ្មានអាហារហូបគ្រប់គ្រាន់ និងគ្មានសម្លៀកបំពាក់ដើម្បីផ្លាស់ប្ដូរ។ អង្គការចាត់តាំងប្ដីរបស់ខ្ញុំឲ្យទៅធ្វើការនៅកន្លែងផ្សេង។ ខ្ញុំមិនបានរស់នៅជាមួយប្ដីរបស់ខ្ញុំទេ ចំណែកម្ដាយរបស់ខ្ញុំដែលមានអាយុច្រើនត្រូវនៅមើលថែកូនរបស់ខ្ញុំ៤នាក់ ។ សមាជិកគ្រួសាររបស់ខ្ញុំ៦នាក់ ត្រូវបានឈ្លបខ្មែរក្រហមដឹកតាមរទេះសេះយកទៅសម្លាប់នៅខាងលិចខេត្តពោធិ៍សាត់។ ខ្ញុំពិតជាសប្បាយរីករាយណាស់នៅពេលដែលក្មេងជំនាន់ក្រោយ បានមកសួរអំពីជីវិតជូរចត់របស់ខ្ញុំ។ ខ្ញុំទទួលបានប្រអប់វត្ថុអនុស្សាវរីយ៍ ហើយនៅពេលខ្ញុំប្រើប្រាស់វា ខ្ញុំនឹកឃើញថានៅមានអ្នកដែលយកចិត្តទុកដាក់ចំពោះខ្ញុំ។

លី ហាន់ណាហ៊ី អាយុ២៧ឆ្នាំ និស្សិតផ្នែកអក្សរសាស្ត្រអង់គ្លេស និងជាអ្នកស្ម័គ្រចិត្តកម្ពុជាខេត្តពោធិ៍សាត់ រៀបរាប់ថា «ខ្ញុំចាប់អារម្មណ៍លើគម្រោងលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រោះខ្ញុំចូលចិត្តធ្វើការងារស្ម័គ្រចិត្តសម្រាប់សង្គម។ ខ្ញុំនឹងជួយមើលថែចាស់ទុំឲ្យមានសុខភាពល្អប្រសើរ ដែលកិច្ចការនេះហាក់ដូចជាការសងគុណដល់គាត់ដែលធ្លាប់ទទួលរងការលំបាក និងមិនបានទទួលសេវាសុខភាពកាលពីរបបខ្មែរក្រហម។ ណាហ៊ី បន្តថា «ចាស់ទុំក្នុងភូមិបានចែករំលែករឿងរ៉ាវរបស់គាត់ ហើយខ្ញុំចូលចិត្តស្ដាប់គាត់និយាយ»។ កាលពីខ្ញុំនៅក្មេង ខ្ញុំធ្លាប់ស្ដាប់រឿងរ៉ាវរបស់អ៊ំខ្ញុំក្នុងរបបខ្មែរក្រហម ហើយបានជំរុញខ្ញុំឲ្យចូលចិត្តការងារនេះ។ ចាប់តាំងពីខ្ញុំអនុវត្តកិច្ចការងារនេះពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ មក ខ្ញុំបានស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតចំនួន១០នាក់ហើយ។ ខ្ញុំនៅចងចាំសាច់រឿងរបស់យាយ យ៉ាន អាយុ៧៩ឆ្នាំ។ យាយ យ៉ាន ប្រាប់ខ្ញុំថា នៅក្នុងរបបខ្មែរក្រហមគាត់ទៅសុំអាហារពីអង្គការឲ្យឪពុករបស់គាត់ហូប ប៉ុន្តែអង្គការមិនឲ្យ ហើយថែមទាំងវាយធ្វើបាបគាត់ទៀត។ ឪពុករបស់យាយ យ៉ាន ស្លាប់ចំពោះមុខគាត់ ដោយសារជំងឺនិងការអត់ឃ្លាន។ ទឹកភ្នែករបស់គាត់ហូរនៅពេលគាត់រំឭករឿងរ៉ាវទាំងអស់នេះប្រាប់ដល់ខ្ញុំ។ យាយ យ៉ាន ចង់ចែករំលែករឿងរ៉ាវរបស់គាត់មកខ្ញុំដែលជាយុវជនជំនាន់ក្រោយ។ រឿងរ៉ាវរបស់គាត់ធ្វើឲ្យខ្ញុំដឹងអំពីទឹកចិត្ត និងសេចក្ដីស្រឡាញ់ទោះបីស្ថិតនៅក្នុងស្ថានភាពលំបាក ប៉ុន្តែគាត់បានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីជួយឪពុក។ ខ្ញុំគិតថាជារឿងល្អនៅពេលដែលខ្ញុំស្ដាប់រឿងរ៉ាវរបស់គាត់ ហើយជូនប្រអប់អនុស្សាវរីយ៍ដល់គាត់។

លី ខុយរ៉ូលីហ្សា អាយុ១៩ឆ្នាំ រៀនផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងសហគមន៍ជនជាតិភាគតិចចាម នៅឃុំអូរសណ្ដាន់ ក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ទទួលកញ្ចប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តពោធិ៍សាត់)

រស់នៅភូមិចុងខ្នុង ឃុំអូរសន្ដាន់ ខេត្តពោធិ៍សាត់ បានរៀបរាប់ថា «រហូតមកដល់សព្វថ្ងៃខ្ញុំស្ដាប់រឿងរ៉ាវក្នុងរបបខ្មែរក្រហមពីឪពុកម្ដាយ, យាយតា អ៊ំ ពូមីង នៅក្នុងភូមិបានចំនួន២០នាក់។ ខ្ញុំនៅចាំរឿងរ៉ាវរបស់ម្ដាយខ្ញុំ និយាយរៀបរាប់ថា ពេលខ្មែរក្រហមគ្រប់គ្រងអំណាចនៅឆ្នាំ១៩៧៥ គាត់ត្រូវបានខ្មែរក្រហមជម្លៀសពីភូមិចុងថ្នុង ទៅភូមិថ្មី ក្រោយមកប្រជាជនហៅថា ភូមិកាកាប។ ម្ដាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមបំបែកចេញពីគ្រួសារ និងចាត់តាំងឲ្យធ្វើការងារក្នុងកងកុមារ។ ម្ដាយខ្ញុំដើរកាប់ទន្ទ្រានខែត្រធ្វើជី ហើយគាត់ទទួលបានតែបបរប៉ុណ្ណោះសម្រាប់អាហារប្រចាំថ្ងៃ។ ប្អូនប្រុសរបស់ម្ដាយខ្ញុំម្នាក់បានស្លាប់ដោយសារជំងឺ។ នៅពេលស្ដាប់រឿងរ៉ាវរបស់ម្ដាយខ្ញុំបានធ្វើឲ្យខ្ញុំអាណិតគាត់យ៉ាងខ្លាំង ហើយមិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងម្ដងទៀតទេ។ ខ្ញុំចង់ជួយម្ដាយខ្ញុំឲ្យមានជីវភាពរស់នៅប្រសើរជាងកាលពីរបបខ្មែរក្រហមដែលគាត់រស់នៅលំបាក»។

អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តចែកកញ្ចប់អនុស្សាវរីយ៍ ជាបន្តបន្ទាប់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចែករំលែករឿងរ៉ាវរបស់គាត់នៅក្នុងរបបខ្មែរក្រហម។ កិច្ចការទាំងនេះគឺជាដំណើរការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហមផ្ទាល់មាត់ និងជាការលើកកម្ពស់នូវសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ហើយក៏ជាផ្នែកមួយនៃសំណងជំងឺចិត្តដល់ជនរងគ្រោះបន្ទាប់ពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងបញ្ចប់នៅពេលខាងមុខ។

# អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
## ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តសៀមរាប

ឤុន សុជាទី



អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តសៀមរាប ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តសៀមរាប)

បន្ទាប់ពីបានចុះសួរសុខទុក្ខ សម្ភាសបំពេញបែបបទសុង្ឃមតិ ប្រមូលរូបថតពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអស់រយៈពេល១ខែកន្លងមក នៅថ្ងៃទី២៨និង២៩ ខែសីហា ឆ្នាំ២០២១ អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តសៀមរាប បានវិលត្រឡប់ទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្តងទៀត ដើម្បីចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់គាត់ៗ អ្នកស្ម័គ្រចិត្ត ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងស្រុកចំនួន ៤ នៅក្នុងខេត្តសៀមរាប គឺស្រុកប្រាសាទបាគង ស្រុកសូទ្រនិគម ស្រុកអង្គរធំ និងស្រុកសៀមរាប ដែលក្នុងកញ្ចប់អនុស្សាវរីយ៍នោះរួមមានព្រឹត្តិបត្រព័ត៌មានណែនាំអំពីសុខភាព, សាប៊ូលាងដៃ, ម៉ាស់, នំ, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩), សៀវភៅអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក, ឧបករណ៍សង្គ្រោះបឋម, សេវាកម្មពិនិត្យសុខភាពនៅតាមមន្ទីរពេទ្យឯកជននៅក្នុងសហគមន៍ដោយឥតគិតថ្លៃ, សម្ភារជំនួយដល់ជនពិការ រួមជាមួយកាបូបស្ពាយ និងអាវយឺតៗ
















អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តសៀមរាប ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តសៀមរាប)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តតាកែវ ទទួលកញ្ចប់អនុស្សាវរីយ៍

រី លក្ខិណា និង កែវ សុភី




អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ)

អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅខេត្តតាកែវ ចាប់ផ្តើមចុះសួរសុខទុក្ខនិងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចាប់តាំងពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២១កន្លងមក។ អ្នកស្ម័គ្រចិត្តបានចុះសម្ភាសន៍ បំពេញបែបបទស្ម័គ្រចិត្ត ផ្តិតយករូបថតពីមូលដ្ឋាន និងប្រគល់កញ្ចប់អនុស្សាវរីយ៍ចំនួន៨០ប្រអប់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងតែរស់នៅក្នុងស្រុកចំនួន៧ ក្នុងខេត្តតាកែវ គឺ ស្រុកបាទី, ស្រុកព្រៃកប្បាស, ស្រុកសំរោង, ស្រុកអង្គរបុរី, ស្រុកទ្រាំង, ស្រុកគិរីវង្ស និងស្រុកត្រាំកក់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានកញ្ចប់អនុស្សាវរីយ៍ ដែលនៅក្នុងនោះរួមមាន ព្រឹត្តិបត្រព័ត៌មានណែនាំអំពីសុខភាព, សាប៊ូលាងដៃ, ម៉ាស់, នំ, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩), សៀវភៅអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក, ឧបករណ៍សង្គ្រោះបឋម, សេវាកម្មពិនិត្យសុខភាពនៅតាមមន្ទីរពេទ្យឯកជននៅក្នុងសហគមន៍ដោយឥតគិតថ្លៃ, សម្ភារជំនួយដល់ជនពិការរួមជាមួយការបូបស្តាយ និងអាវយឺត។ អ្នកស្ម័គ្រចិត្ត នឹងបន្តអនុវត្តកិច្ចការងាររបស់ខ្លួនសម្រាប់ខែកញ្ញាបន្តទៅទៀត។

សូមអរគុណដល់អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅខេត្តតាកែវមាន កែប ម៉ៃសុជាតា, អ៊ុំ ស្រីលី, ស្រឿន ធារ៉ា, ខុំ ស្រីនោរ, គ្រី ភាព, ថៃ ស៊ីណា, ហេង លីដា, ទុយ តារ៉ា, កង ពិដោរ, ហៀក ស្រីពេជ្រ, ពិន ពុំពា, មឿន ហាច, កាន់ សុខភាព, ហួ ស៊ីណាត, ជឹម សុខគា, ញ៉ាញ់ ធីប, រឹម ស្រីស្រស់, សៀង កញ្ញា, វ៉ែនចរិយា និង ស៊ុយ ហ៊ីម ម៉េង ឡាង ដែលបានបំពេញកិច្ចការងាររបស់ខ្លួនកន្លងមក។



អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ)

# ការផ្តល់ជូនកញ្ចប់អនុស្សាវរីយ៍
## ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពង់ចាម

*ស៊ាង ចិន្ដា*





អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ចាម ចែកកញ្ចប់អនុស្សាវរីយ៍ ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី ១ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ចាម)











អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តកំពង់ចាម ចាប់ផ្ដើមចុះសួរសុខទុក្ខនិងស្ដាប់រឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ ដោយបានសម្ភាសន៍បំពេញបែបបទស្ទង់មតិ ផ្ដិតយករូបថតពីមូលដ្ឋាន និងកញ្ចប់អនុស្សាវរីយ៍ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងតែរស់នៅក្នុងស្រុកចំនួន ៤ នៃខេត្តកំពង់ចាម រួមមាន៖ ស្រុកកំពង់សៀម ស្រុកកោះសូទិន ស្រុកកងមាស និងស្រុកស្ទឹងត្រង់។ អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តកំពង់ចាម នឹងបន្តអនុវត្តកិច្ចការងាររបស់ខ្លួនសម្រាប់ខែកញ្ញា ពេលខាងមុខនេះ។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
## នៅខេត្តស្វាយរៀងទទួលបានកញ្ចប់អនុស្សាវរីយ៍

**សោម ប៊ុនថន**

នៅវេលាម៉ោង៩ ព្រឹកថ្ងៃអាទិត្យ ទី២៩ ខែសីហា ឆ្នាំ២០២១ អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តស្វាយរៀងចំនួន ២០នាក់ មកពីស្រុករមាសហែក ស្រុកស្វាយទាប ស្រុករំដួល ស្រុកចន្ទ្រា និងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង មកជួបជុំគ្នានៅសាលាសំណាក់ ស្ថិតនៅក្នុងភូមិព្រៃបាសាក់ ឃុំព្រៃបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដោយអនុវត្តតាមវិធានការពាក់ពារការពាររបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា។ អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជានៃខេត្តស្វាយរៀង ចែករំលែកចំណេះដឹងគ្នាទាក់ទងនឹងការអនុវត្តការងារសុខភាពកន្លងមក និងពិភាក្សាលើបញ្ហាប្រឈមដែលខ្លួនទៅសម្ភាសន៍ និងស្តាប់ឪពុកម្តាយ យាយ តា អ៊ំ ពូមីង រៀបរាប់អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមនៅក្នុងភូមិឃុំរបស់ខ្លួននៅអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ រួមជាមួយដំណោះស្រាយ។ នៅក្នុងឱកាសនោះ សោម ប៊ុនថន បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ ជែលលាងដៃ, ម៉ាស់, អាវយឺត, លិខិតឧទ្ទេសនាម, ទម្រង់សំណួរស្ទាបស្ទង់មតិ, ទស្សនាវដ្តីស្វែងរកការពិត សម្រាប់អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារនៅខេត្តស្វាយរៀងប្រើប្រាស់នៅពេលចុះទៅសួរសុខទុក្ខ និងស្តាប់រឿងរ៉ាវឪពុក ម្តាយ យាយ តា អ៊ំ ពូមីង ព្រមទាំងកញ្ចប់អនុស្សាវរីយ៍។ បន្ទាប់មកអ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបាននាំយកកញ្ចប់អនុស្សាវរីយ៍ ចំនួន៥៥ កេស រួមមាន១) ព្រឹត្តិបត្រព័ត៌មានណែនាំអំពីសុខភាព, ២) សាប៊ូលាងដៃ, ៣) ម៉ាស់, ៤) នំ, ៥) សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩), ៦) សៀវភៅអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក, ៧) ឧបករណ៍សង្គ្រោះបឋម, ៨) សេវាកម្មពិនិត្យសុខភាពនៅតាមមន្ទីរពេទ្យឯកជនក្នុងសហគមន៍ដោយឥតគិតថ្លៃ, និង ៩) សម្ភារជំនួយដល់ជនពិការ រួមជាមួយកាបូបស្ពាយ និងអាវយឺតយកទៅចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលខ្លួនបានសម្ភាសន៍កន្លងមកនៅតាមភូមិឃុំរៀងៗខ្លួន។







អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តស្វាយរៀង ចែកកញ្ចប់អនុស្សាវរីយ៍ ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១។
(អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តស្វាយរៀង)



អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តស្វាយរៀងចែកកញ្ចប់អនុស្សាវរីយ៍ ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តស្វាយរៀង)

# អតីតកងចល័តយុវជនឃុំអន្លង់មៀន

មេក វិន



ង៉ាន ម៉ាក់ រស់នៅក្នុងភូមិស្រឡៅស្រោង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ រៀបរាប់អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមប្រាប់ មេក វិន បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (មេក វិន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ង៉ាន ម៉ាក់ ភេទប្រុស អាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅភូមិប្រ៉ាស់ ឃុំបឹងណាយ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ សព្វថ្ងៃ ម៉ាក់រស់នៅក្នុងភូមិស្រឡៅស្រោង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ម៉ាក់បាននិយាយរៀបរាប់ពីដំណើរនៃការតស៊ូ និងទុក្ខលំបាករបស់ខ្លួនក្នុងសម័យខ្មែរក្រហមដូចខាងក្រោមថា៖

កាលពីកុមារភាព ខ្ញុំរស់នៅក្នុងគ្រួសារមួយដែលមានជីវភាពមធ្យម។ គ្រួសារខ្ញុំ ប្រកបមុខរបរធ្វើស្រែចម្ការ និងដាំដំណាំបន្តិចបន្តួចសម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ចំណែកឯប្រជាជនដែលរស់នៅក្នុងភូមិប្រ៉ាស់ ការរកស៊ីលក់ដូរ ធ្វើស្រែចម្ការ មានភាពប្រសើរឡើង ជាពិសេសការហូបចុក ប្រជាជនមិនមានការខ្វះខាតឡើយ។ កាលណោះ ខ្ញុំរួមទាំងក្មេងៗនៅក្នុងភូមិជាច្រើននាក់ទៀតបាននាំគ្នាទៅឃ្វាលគោ ព្រមទាំងរត់លេងជាមួយគ្នាយ៉ាងសប្បាយក្អាកក្អាយ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ កើតមានឡើង។ ក្រោយមកក៏មានការទម្លាក់គ្រាប់បែកយ៉ាងច្រើន នៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ដែលធ្វើឲ្យឆាបឆេះផ្ទះប្រជាជនអស់ជាច្រើនខ្នង។ បន្ទាប់មកទៀតឪពុករបស់ខ្ញុំ សម្រេចចិត្តចូលបម្រើក្នុងរដ្ឋការរបស់ លន់ នល់។ នៅពេលដែលឪពុកខ្ញុំចូលជាមន្ត្រីរដ្ឋការ រដ្ឋាភិបាលដឹកនាំដោយ លន់ នល់ សម្រេចឲ្យឪពុកខ្ញុំមើលការខុសត្រូវខាងផ្នែកកសិកម្ម។ ឪពុករបស់ខ្ញុំត្រូវបានបញ្ជូនទៅទីក្រុងភ្នំពេញ បន្ទាប់ពីបានទទួលតំណែង។ ខ្ញុំរៀនត្រឹមថ្នាក់ទី១០ពីសង្គមចាស់ ដោយសារតែឪពុករបស់ខ្ញុំផ្លាស់ទីលំនៅទៅរស់នៅភ្នំពេញ ម្យ៉ាងវិញទៀតស្រុកទេសកំពុងតែកើតមានសង្គ្រាម។

នៅចន្លោះឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ភាពចលាចល និងអសន្តិសុខនៅក្នុងខណ្ឌចំការមន រដ្ឋធានីភ្នំពេញ តែងតែកើតមានជារៀងរាល់ថ្ងៃ។ សង្គ្រាមក្នុងប្រទេសកាន់តែរីកធំពីមួយថ្ងៃទៅមួយថ្ងៃ។ បន្ទាប់ពីមានភាពវឹកវរ និងអសន្តិសុខនៅចំការមនញឹកញាប់ពេក ឪពុកខ្ញុំ សម្រេចចិត្តត្រឡប់មករស់នៅស្រុកកំណើតវិញ។

នៅក្នុងឆ្នាំ១៩៧៣ ឪពុករបស់ខ្ញុំសម្រេចចិត្តលាលែងពីតំណែងក្នុងរដ្ឋការរបស់ លន់ នល់។ កាលណោះខ្ញុំទើបតែមានអាយុ១៣ឆ្នាំប៉ុណ្ណោះ។ បន្ទាប់មក ឪពុករបស់ខ្ញុំក៏សុំការអនុញ្ញាតគណៈគ្រប់គ្រងស្រុកព្រៃឈរផ្លាស់ទីលំនៅទៅរស់នៅក្នុងខេត្តប៉ៃលិនវិញ ដោយសារតែគាត់មានបងប្អូនរស់នៅទីនោះ។ គ្រួសារខ្ញុំទៅរស់នៅបរតាំងស៊ូ ក្នុងខេត្តប៉ៃលិន និងបានប្រកបមុខរបរជាជាងសាងសង់សាលាឆទាន និងវត្តអារាមជាដើម។ គ្រួសារខ្ញុំរួមទាំងប្រជាជនដទៃទៀតរស់នៅដោយសុខសប្បាយ មិនមានការទម្លាក់គ្រាប់បែក ឬអសន្តិសុខអ្វីឡើយ។

រហូតដល់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចូលមកដល់បរតាំងស៊ូ។ បន្ទាប់មក ខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំរួមទាំងប្រជាជនជាច្រើនអ្នកទៀតចាកចេញទៅកាន់ខេត្តបាត់ដំបង។ កាលណោះ ប្រជាជនដែលរស់នៅក្នុងខេត្តប៉ៃលិន មិនថានៅក្នុងក្រុង ឬស្រុកស្រែចម្ការទេ កងទ័ពខ្មែរក្រហមធ្វើការជម្លៀសចេញពីភូមិកំណើតទាំងអស់។ ចំណែកឯប្រធានភូមិ គណៈគ្រប់គ្រងឃុំ និងគណៈគ្រប់គ្រងតំបន់បរតាំងស៊ូ ត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រទាំងអស់។ ដោយឡែកចំពោះទាហាន លន់ នល់ កងទ័ពខ្មែរក្រហមប្រកាសថា អ្នកណាដែលធ្លាប់កាន់មុខតំណែងអ្វីក៏ដោយ មិនថាស័ក្តិមួយ ឬស័ក្តិពីរ កងទ័ពខ្មែរក្រហមឲ្យទទួលតំណែងរបស់ខ្លួនដដែល។ ខ្ញុំនៅចាំថា កងទ័ពខ្មែរក្រហមស្លៀកសម្លៀកបំពាក់ឈុតពណ៌ខ្មៅ មានទាំងក្មេង ទាំងមនុស្សចាស់ ប្រដាប់ដោយកាំភ្លើងគ្រប់ដៃ។ មិនតែប៉ុណ្ណោះ សម្លៀកបំពាក់ទាំងអស់ដែលកងទ័ពខ្មែរក្រហមស្លៀកពាក់ គឺសុទ្ធតែសម្លៀកបំពាក់ចាស់ៗ មិនមានថ្មីឡើយ។

ប្រជាជនដែលខ្មែរក្រហមជម្លៀសចេញពីបរតាំងស៊ូនាពេលនោះ ពិតជាមានការសោកស្តាយ ផ្ទះសម្បែង និងភូមិកំណើតរបស់ខ្លួនខ្លាំងណាស់។ អ្នកខ្លះ មានម៉ូតូ អ្នកខ្លះមានឡាន និងអ្នកខ្លះទៀតមានរទេះរុញ។ ចំណែកឯខ្ញុំអូសរទេះ ហើយឪពុកម្តាយរបស់ខ្ញុំជាអ្នករៀបចំរបស់របរ សម្ភារប្រើប្រាស់មានដូចជា អង្ករ អំបិល កាំបិត ពូថៅ និងសម្ភារប្រើប្រាស់មួយចំនួនទៀត ដាក់ក្នុងរទេះ។ បន្ទាប់មកគ្រួសាររបស់ខ្ញុំ រួមទាំងប្រជាជនជាច្រើននាក់ទៀតបានធ្វើដំណើរចាកចេញពីខេត្តប៉ៃលិន។ លើសពីនេះទៅទៀត កងទ័ពខ្មែរក្រហម ដឹកនាំប្រជាជនទាំងអស់ដើរចុះពីផ្លូវកៅស៊ូ ហើយសំដៅទៅទិសខាងកើត ដោយធ្វើដំណើរតាមផ្លូវរទេះ។ ក្រោយពីគ្រួសារខ្ញុំ រួមទាំងប្រជាជនជាច្រើននាក់ទៀតធ្វើដំណើរអស់រយៈពេល១យប់ ២ថ្ងៃ ក៏ទៅដល់រោងចក្រស្ករស ស្ថិតនៅជិតដងស្ទឹងសង្កែ។ បន្ទាប់ពីធ្វើដំណើរទៅដល់ទីនោះ កងទ័ពខ្មែរក្រហម បញ្ជាឲ្យខ្ញុំឈប់សម្រាកនៅរោងចក្រស្ករសរយៈពេល៣ថ្ងៃសិន។ លុះដល់ព្រឹកថ្ងៃទី៣ កងទ័ពខ្មែរក្រហមបញ្ជាឲ្យយើងបន្តដំណើរទៅមុខទៀត។ យើងដើររហូតដល់ម៉ោង៤ល្ងាច ទើបបានទៅដល់គោលដៅដែលស្ថិតនៅក្នុងភូមិអន្លង់មៀន ឃុំអន្លង់មៀន ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅទីនោះ កងកម្លាំងខ្មែរក្រហមប្រកាសប្រាប់ប្រជាជនឲ្យរកអាហារហូបចុកដោយខ្លួនឯង។ ប៉ុន្តែគណៈគ្រប់គ្រងនៅឃុំអន្លង់មៀនបានបើកឲ្យប្រជាជនដែលទើបតែជម្លៀសមកថ្មី ដែលមានមាសប្រាក់ កែវកង ឬសម្លៀកបំពាក់ថ្មីៗយកទៅដោះដូរយកជាអង្ករ គ្រាប់ពោត សណ្តែកដី ឡូង ជាមួយប្រជាជន១៨មីនា។ ប្រជាជន១៨មីនា ជាប្រជាជនដែលបានចាកចេញពីភូមិកំណើតរបស់ខ្លួនមកចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហមក្នុងព្រៃតាំងពីឆ្នាំ១៩៧០មកម៉្លេះ ដើម្បីប្រឆាំងជាមួយរដ្ឋការ លន់ នល់ និងទាមទារតំណែងជូនសម្តេចព្រះ នរោត្តម សីហនុ។ ប៉ុន្តែប្រជាជន១៨មីនា មិនបានរស់នៅក្នុងឃុំអន្លង់មៀនជាមួយប្រជាជនទើបតែជម្លៀសទៅក្រោយទេ គឺនៅក្នុងព្រៃដាច់ឆ្ងាយពីគ្នា។ ដោយសារតែភាពអត់ឃ្លាន ខ្វះខាតស្បៀងអាហារ ម្តាយរបស់ខ្ញុំ និងខ្ញុំបានធ្វើដំណើរអស់រយៈពេល៤ម៉ោង ទើបទៅដល់ទីកន្លែងរស់នៅរបស់ប្រជាជន១៨មីនា ឬហៅថាប្រជាជនមូលដ្ឋាន។ ពេលទៅដល់ទីនោះ ខ្ញុំឃើញមានផ្ទះតូចៗ គឺមិនមានផ្ទះធំទេ ប៉ុន្តែប្រជាជន១៨មីនា មានអាហារហូបចុក និងសម្ភារប្រើប្រាស់គ្រប់យ៉ាងដូចជា៖ ស្រូវ អង្ករ គោ ក្របី ។

នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំបានចូលជាកងចល័តយុវជនយុវនារី។ បន្ទាប់មក ខ្ញុំចេញទៅធ្វើការនៅតាមមុខសញ្ញាទាំងអស់ដែលស្ថិតនៅក្នុងឃុំអន្លង់មៀន។ ក្នុងកងចល័តយុវជនយុវនារី មានតែមួយកងប៉ុណ្ណោះ

ហើយ សរុបសមាជិកទាំងអស់មានចំនួន៤០០នាក់។ លើសពីនេះទៅទៀត កិច្ចការសំខាន់ចំនួនពីរដែលកងចល័តយុវជនយុវនារីត្រូវធ្វើនោះគឺ ទី១) ការលើកភ្លឺស្រែ និងទី២) ការជីកប្រឡាយបង្ហូរទឹក។ នៅពេលលើកភ្លឺស្រែម្តងៗ ប្រធានសហករណ៍បានបញ្ជាសមាជិកកងឲ្យវាស់ម៉ែត្រចែកគ្នាក្នុងម្នាក់ចំនួន៥ម៉ែត្រ និងមានកម្ពស់៥តឹក។ យុវជនយុវនារីទាំងអស់ត្រូវធ្វើយ៉ាងណាឲ្យរួចតាមចំនួនកំណត់របស់អង្គការ។ បើអ្នកណាធ្វើមិនរួចតាមការកំណត់របស់អង្គការ មិនត្រូវបានឈប់សម្រាកឡើយ។ ចំណែកឯ បុរស ឬស្ត្រី ណាដែលស្រឡាញ់គ្នា គឺត្រូវជូនដំណឹងទៅដល់ប្រធានសហករណ៍។ បន្ទាប់មកប្រធានសហករណ៍នឹងកត់ត្រាឈ្មោះទុករហូតគ្រប់ចំនួន២០គូ ទើបរៀបចំពិធីការឲ្យម្តងៗ។ ជាក់ស្តែង បងស្រីរបស់ខ្ញុំក៏រៀបការក្នុងចំណោម២០គូនោះដែរ។ ក្នុងពិធីរៀបការនេះ ប្រធានសហករណ៍ ហៅឪពុកម្តាយ បងប្អូន សាមីខ្លួនដែលរៀបការមកជួបជុំក្នុងពិធី។ បន្ទាប់មក គូស្វាមីទាំងកូនប្រុស កូនស្រី ក្រោកឈរទល់មុខគ្នា ដើម្បីចាប់ដៃប្តេជ្ញាចិត្តថា ព្រមស្ម័គ្រយកគ្នាជាប្តីប្រពន្ធពិតប្រាកដមែន។ លើសពីនេះទៅទៀត ការរៀបចំអាហារហូបចុកក្នុងពិធី គឺមានច្រើនមុខដូចជាៈ នំបញ្ចុកបាយសម្ល ស្ងោរមាន់ ស្ងោរទា សាច់ជ្រូក និងគោក្របី។ គូស្វាមីដែលរៀបការរួចហើយ មានសិទ្ធិឈប់សម្រាកចំនួន៣ថ្ងៃប៉ុណ្ណោះ។ បន្ទាប់មកក៏ត្រូវចេញទៅធ្វើការតាមមុខសញ្ញារៀងៗខ្លួន។

នៅថ្ងៃមួយដោយសារតែខ្ញុំហេវហត់អស់កម្លាំងខ្លាំងពេក ខ្ញុំធ្វើពុតជាឈឺដើម្បីបានឈប់សម្រាកមួយថ្ងៃ។ ភ្លាមៗនោះឈ្លបដើរមកទាត់ខ្ញុំ ដែលកំពុងដេកឈឺចំនួន៣ជើង ហើយថែមទាំងស្រែកឲ្យក្រោកទៅធ្វើការដើម្បីទទួលបានរបបបបរ។ នៅជំនាន់នោះ បើអ្នកណាមិនទៅធ្វើការទេ គឺមិនទទួលបានបបរហូបជាដាច់ខាត។ ចំពោះអ្នកឈឺ មិនបានធ្វើការ អង្គការបញ្ជាឲ្យទៅបើកកន្ទក់មួយកូនចានមកហូបក្នុងមួយថ្ងៃ។ បន្ទាប់ពីបើកកន្ទក់បានហើយអ្នកខ្លះយកកន្ទក់ទៅដាំឲ្យឆ្អិន ខ្លះទៀតយកទៅបបរដាក់លាយត្រកួនឬស្លឹកបាស។ ចំណែកខ្ញុំយកទៅលីងឲ្យឆ្អិនដើម្បីហូបកុំឲ្យមានការឈឺពោះ។ ខ្ញុំចូលធ្វើកងចល័តរហូតដល់ចុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមក៏វាយចូលមកដល់។ ខ្ញុំរួមទាំងយុវជនយុវនារីជាច្រើននាក់ទៀតរត់ទៅរកឪពុកម្តាយរៀងៗខ្លួនដើម្បីជួបជុំគ្រួសារ និងត្រឡប់ទៅស្រុកភូមិកំណើតវិញ។

នៅដើមឆ្នាំ១៩៨០ គ្រួសាររបស់ខ្ញុំត្រឡប់ទៅរស់នៅក្នុងស្រុកព្រៃឈរដែលជាស្រុកកំណើតវិញ។ នៅពេលដែលខ្ញុំទៅដល់ភូមិកំណើត ខ្ញុំពិតជាមានការសប្បាយចិត្តរីករាយជាខ្លាំង ព្រោះឃើញផ្ទះសម្បែង និងជួបជុំសាច់ញាតិបងប្អូនសារជាថ្មី។ ក្នុងឆ្នាំ១៩៨១ ខ្ញុំក៏រៀបការ។ ពិធីរៀបការរបស់ខ្ញុំមិនមានអ្វីធំដុំនោះទេ គ្រាន់តែមានបាយសម្លសម្រាប់ទទួលអ្នកចូលរួមក្នុងពិធីបន្តិចបន្តួចតែប៉ុណ្ណោះ។ បន្ទាប់ពីខ្ញុំរៀបការរួចហើយ ឪពុកម្តាយរបស់ខ្ញុំចែកដីធ្លីមួយចំនួនដើម្បីធ្វើស្រែចម្ការ និងសង់ផ្ទះសម្បែង។ កាលណោះ ដោយសារតែនៅក្នុងភូមិប្រាំសមិនទាន់មានភាពស្ងប់ស្ងាត់ស្រួលបួលជាពិសេសសង្គ្រាមតាមព្រំដែននៅតែបន្ត ទើបធ្វើឲ្យប្រជាជនដែលរស់នៅក្នុងភូមិប្រាំសមិនអាចចេញទៅប្រកបមុខរបរធ្វើស្រែចម្ការនៅឆ្ងាយៗពីភូមិបាន។ ប្រជាជនដែលរស់នៅក្នុងភូមិប្រាំសមានការខ្វះខាតការហូបចុកជាខ្លាំង។

នៅឆ្នាំ១៩៩០ ការរស់នៅក្នុងស្រុកភូមិ ចាប់ផ្តើមមានភាពប្រសើរឡើង។ ប្រជាជនអាចចេញទៅធ្វើស្រែចម្ការឆ្ងាយៗ និងរកស៊ីលក់ដូរនៅក្នុងភូមិបាន។ រហូតដល់ឆ្នាំ១៩៩៣ មានការបោះឆ្នោតជាសកលកើតមានឡើង។ ចាប់តាំងពីពេលនោះមក ប្រជាជនរស់នៅដោយមានសុខសន្តិភាព លែងមានសង្គ្រាមកើតមាននៅក្នុងស្រុកភូមិដូចមុនទៀត។ ខ្ញុំរួមទាំងគ្រួសារបន្តរស់នៅក្នុងស្រុកកំណើតរហូតដល់ចុងឆ្នាំ២០០០។ នៅដើមឆ្នាំ២០០១ ខ្ញុំសម្រេចចិត្តនាំគ្រួសារមកកាន់ទឹកដីអន្លង់វែង។ ខ្ញុំទិញដីបានមួយចំនួនសម្រាប់ធ្វើស្រែចម្ការ ដាំដំណាំ និងចិញ្ចឹមសត្វ។ ទឹកដីអន្លង់វែងពិតជាស្រស់ស្អាតខ្លាំងណាស់ដែលជាហេតុធ្វើឲ្យខ្ញុំសម្រេចចិត្តចាកចេញពីស្រុកកំណើតមករស់នៅទឹកដីនេះរហូតមកដល់បច្ចុប្បន្ន។

# បទចម្រៀង «ឱ! ភ្នំពេញអើយ» បានរំឭកអំពីការចងចាំ

សោម ប៊ុនថន





*ទិដ្ឋភាពផ្សារធំថ្មី បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។*

*(រូបខាងលើ) កងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាឈរនៅតាមបណ្តោយផ្លូវ ហ្សារលដឺហ្គោល ក្នុងក្រុងភ្នំពេញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។*

បទចម្រៀងបានជួយធ្វើឲ្យមនុស្សមានអារម្មណ៍ផ្លាស់ប្តូរ ការគិតពិចារណា និងជួយធ្វើឲ្យមានការផ្សះផ្សាផ្លូវចិត្ត។ រហូតមកដល់ពេលនេះមានរយៈពេល ៤២ឆ្នាំមកហើយ បទចម្រៀង **«ឱ! ភ្នំពេញអើយ»** នៅតែដក់ជាប់នៅក្នុងដួងចិត្តរបស់ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលបានឆ្លងកាត់របបខ្មែរក្រហមប្រមាណជាង ៥ លាន់នាក់ ដែលកំពុងនៅរស់រានមានជីវិត។

បទចម្រៀង«ឱ! ភ្នំពេញអើយ» និពន្ធដោយលោក កែវ ចិន្តា នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ គឺជាបទចម្រៀងទីមួយដែលត្រូវបានចាក់ផ្សាយបន្ទាប់ពីរបប

ខ្មែរក្រហមដួលរលំ។ បទចម្រៀង «ឱ! ភ្នំពេញអើយ» ត្រូវបានច្រៀងឡើងវិញដោយអ្នកនាង ពេជ្រ ចរិយា នៅពេលនេះបានរំឭកអំពី ការចងចាំ ប្រវត្តិសាស្ត្រ និងរឿងរ៉ាវ រន្ធត់ ដែលប្រជាជនកម្ពុជាបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ប្រជាជនកម្ពុជានឹងបានស្តាប់បទចម្រៀង«ឱ! ភ្នំពេញអើយ» គឺជាទម្រង់បទចម្រៀងថ្មី ដែលនឹងជួយឲ្យមានការគិតពិចារណាឡើងវិញអំពីអំពើឃោរឃៅដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ជួយឲ្យបានធូរស្បើយអារម្មណ៍ និងជួយឲ្យយកឈ្នះលើអតីតកាលដ៏ឈឺចាប់។



របស់របរនៅរាយប៉ាយនៅតាមផ្លូវម្តុំផ្សារអូរឫស្សី បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សេន វាសនា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង ដែលបានស្តាប់បទចម្រៀង «ឱ! ភ្នំពេញអើយ» ច្រៀងដោយអ្នកនាង ពេជ្រ ចរិយា សរសេរថា «បន្ទាប់ពីខ្ញុំបានស្តាប់បទនេះអមដោយរូបភាព ខ្ញុំមានអារម្មណ៍ថាអាណិតឈឺចាប់ខ្លោចផ្សា ហើយបទនេះបានបង្ហាញអំពីទុក្ខលំបាករបស់បងប្អូនប្រជាជនដែលរងគ្រោះពីរបបខ្មែរក្រហម»។

សុខ ចន្ទ្រា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង សរសេរថា «បទនេះពិរោះរណ្តំលាយ ឡំជាមួយភាពកម្សត់ និងចាក់ចូលជ្រៅទៅក្នុងចិត្ត ធ្វើឲ្យអ្នកស្តាប់នឹកឃើញដល់អតីតកាល ឈឺចាប់ នឹកដល់ដួងព្រលឹងជាតិ ហើយក៏ធ្វើឲ្យធូរស្បើយក្រោយការវិលមកសន្តិភាពវិញ»។

ទេព ម៉ាលី ណា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង សរសេរថា«បទនេះពិរោះ ហើយកម្សត់។ ពេលខ្ញុំស្តាប់បទនេះចប់ ខ្ញុំមានអារម្មណ៍ក្តុកក្តួល ព្រោះឃើញរូបភាព និងអត្ថន័យបទចម្រៀងប្រៀបដូចឃើញហេតុការណ៍ជាក់ស្តែងផ្ទាល់ភ្នែកពីការឈឺចាប់ លំបាកវេទនារបស់ប្រជាជនខ្មែរនៅក្នុងរបបខ្មែរក្រហម»។

បច្ចុប្បន្នអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមាណ៥០០នាក់ នៅតាមទីជនបទដាច់ស្រយាលទូទាំងប្រទេសកម្ពុជា កំពុងធ្វើការងារជួយលើផ្នែកសុខភាព និងស្តាប់នូវរឿងរ៉ាវរបស់ឪពុកម្តាយ យាយតា អ៊ំ ពូមីង ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។





ប្រជាជនវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជីវិតអកុសលរបស់ម្តាយខ្ញុំ

***យី សុឃី***



*រាប់ពីខាងឆ្វេង យី សុខន (កូនទី៤), យី សុខា (កូនទី៣), មូល យាង (ឪពុក), យី កួន (ម្តាយ), យី សុឃី (នៅលើដៃម្តាយខ្ញុំ), យី សុឃា (កូនទី២), កូយ ស្រីដាវ (កូនទី១)។ រូបថតនេះថតនៅកំឡុងទសវត្សរ៍ទី៩០ នៅភូមិអង្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដើម្បីស្វែងរកសាច់ញាតិដែលបានបែកគ្នានៅអំឡុងរបបខ្មែរក្រហម។ (យី សុឃី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ម្តាយខ្ញុំឈ្មោះ យី កួន អាយុ ៦៩ឆ្នាំ។ គាត់គឺជាកូនទី៣ ក្នុងចំណោមបងប្អូន៤នាក់។ ម្តាយខ្ញុំមានស្រុកកំណើតនៅក្នុងភូមិអង្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ គាត់ រៀនសូត្របានតិចតួចណាស់ ហើយគាត់បានសម្រេចចិត្តឈប់រៀនព្រោះតែប្រពៃណីទំនៀមទម្លាប់ពីបុរាណដែលយល់ឃើញថាកូនស្រីត្រូវនៅចាំផ្ទះថែរក្សាកូន និងក្រុមគ្រួសារដោយមិនចាំបាច់រៀនសូត្រឲ្យបានខ្ពង់ខ្ពស់នោះទេ។

នៅពេលម្តាយខ្ញុំមានអាយុប្រហែល១៨ឆ្នាំ គាត់រៀបការជាមួយឪពុកខ្ញុំឈ្មោះ មូល យាង នៅផ្ទះខាងឪពុកខ្ញុំស្ថិតក្នុងភូមិព្រៃសាក់ ឃុំអញ្ចាញរូង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ នៅក្នុងថ្ងៃរៀបការរបស់គាត់ មានកងទ័ពខ្មែរក្រហមមួយចំនួនចូលមកក្នុងភូមិហើយចង់អង្រើងដេកយាមក្បែររោងការដែលបង្កឲ្យប្រជាជនមានការភ័យខ្លាចយ៉ាងខ្លាំង។ នៅក្នុងរបប លន់ នល់ ម្តាយខ្ញុំបង្កើតបានកូន២នាក់ គឺបងស្រីរបស់ខ្ញុំឈ្មោះ យី សុភា និង យី សុផុន។ ឪពុកម្តាយរបស់ខ្ញុំ ប្រកបមុខរបរធ្វើស្រែចំការដើម្បីចិញ្ចឹមជីវិត។

នៅពេលដែលរបបខ្មែរក្រហមចូលមកកាន់កាប់ប្រទេសកម្ពុជាទាំងស្រុងក្នុងឆ្នាំ១៩៧៥ អង្គការបាន

បំបែកម្ដាយឪពុករបស់ខ្ញុំចេញពីគ្នា។ អង្គការមិនអនុញ្ញាតឲ្យម្ដាយឪពុករបស់ខ្ញុំត្រឡប់ទៅរស់នៅផ្ទះនោះទេ ទោះបីជាកន្លែងធ្វើការរបស់គាត់នៅក្បែរផ្ទះក៏ដោយ។ ប្រជាជនទាំងអស់ត្រូវរស់នៅរួមគ្នាក្នុងសហករណ៍ក្នុងខ្ទមប្រក់ស្បូវដែលអង្គការបានសាងសង់ទុកឲ្យ។ អង្គការបានរុះរើផ្ទះកេរដូនតារបស់ម្ដាយឪពុកខ្ញុំចោល ខ្ទេចខ្ទីអស់គ្មានសល់ ដោយយកសសរផ្ទះទៅសាងសង់ធ្វើជាស្ពានឆ្លងស្ទឹងលំហាចដែលនៅសល់រហូតដល់សព្វថ្ងៃ។ អង្គការបានជម្លៀសម្ដាយឪពុករបស់ខ្ញុំឲ្យទៅរស់នៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ព្រោះតែអង្គការគិតថាឪពុកខ្ញុំមានអត្តចរិតស្លូតបូតពេកមិនអាចធ្វើជាកងឈ្លបគ្រប់គ្រងប្រជាជន។ ក្រោយមក អង្គការបានជម្លៀសគាត់ទៅរស់នៅក្នុងស្រុកបវិល ខេត្តបាត់ដំបងវិញ ។ បងស្រីទាំងពីរនាក់របស់ខ្ញុំ ស្លាប់នៅតាមផ្លូវពេលជម្លៀសទៅកាន់ខេត្តបាត់ដំបង ដោយសារគាត់កើតជំងឺហើម។ ម្ដាយខ្ញុំធ្លាប់និយាយរៀបរាប់ប្រាប់ខ្ញុំថា នៅពេលដែលគាត់ជម្លៀសចេញពីខេត្តពោធិ៍សាត់ទៅកាន់ខេត្តបាត់ដំបង គាត់ឃើញរថក្រោះបើកកិនរទេះគោរបស់ប្រជាជនដែលបង្កឲ្យមានមនុស្សស្លាប់ហូរឈាមស្រោចស្រពពាសពេញដី។ ប្រជាជនមួយចំនួនផ្សេងទៀត ត្រូវក្រុមចោរព្រៃប្លន់យកសម្ភារប្រើប្រាស់និងទ្រព្យសម្បត្តិរួចសម្លាប់ចោល។ រទេះគោរបស់ម្ដាយឪពុកខ្ញុំនិងរទេះគោរបស់ប្រជាជនជម្លៀសដែលធ្វើដំណើររួមគ្នាត្រូវចោរព្រៃម្នាក់តាមជាប់រហូត ប៉ុន្តែពូម្នាក់ដែលជម្លៀសទៅជាមួយម្ដាយឪពុកខ្ញុំមានកាំភ្លើងជាប់ខ្លួន ហើយបានបាញ់សម្លាប់ចោរព្រៃ។

នៅពេលទៅដល់ខេត្តបាត់ដំបង អង្គការបានឲ្យឪពុកខ្ញុំទៅរស់នៅជាមួយកងភ្ជួរ ចំណែកម្ដាយខ្ញុំវិញត្រូវនៅជួយដាំបាយក្នុងរោងបាយ។ ទោះបីជាម្ដាយខ្ញុំ គឺជាអ្នកដាំបាយ គាត់ក៏ទទួលបានរបបអាហារដូចៗគ្នាទៅនឹងប្រជាជនដទៃទៀតដែរ។ រហូតដល់ឆ្នាំ១៩៧៩ នៅពេលកងទ័ពវៀតណាម ចូលមកវាយកងទ័ពខ្មែរក្រហម ឪពុកម្ដាយខ្ញុំ សម្រេចចិត្តត្រឡប់មករស់នៅក្នុងភូមិភ្លៀត ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំងវិញ។ ចុងក្រោយ ម្ដាយឪពុកខ្ញុំប្ដូរទីលំនៅមករស់នៅ



ឪពុករបស់ខ្ញុំឈ្មោះ មូល យាង និងម្ដាយឈ្មោះ ឃី កួន ថត នៅឆ្នាំ២០០០ ក្នុងពិធីមង្គលការបងស្រីទី២ នៅផ្ទះនៅភូមិអង្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។
(ឃី សុឃី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងភូមិអង្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដែលជាដីកេររបស់ឪពុកម្ដាយខ្ញុំវិញ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ម្ដាយឪពុករបស់ខ្ញុំ ចាប់ផ្ដើមប្រកបរបរធ្វើស្រែចម្ការឡើងវិញ ហើយបង្កើតបានកូនចំនួន៧ នាក់ថែមទៀត។ ក្នុងឆ្នាំ១៩៩៥ ឪពុកខ្ញុំ ចាប់ផ្ដើមឈឺភ្នែក។ ភ្នែករបស់គាត់ម្ខាងកើតជំងឺឡើងបាយភ្នែក ហើយបន្ទាប់មក ជំងឺនេះឆ្លងទៅភ្នែករបស់គាត់ម្ខាងទៀត ថែមទាំងបង្កឲ្យគាត់ងងឹតភ្នែក ទាំងសងខាង។ ម្ដាយខ្ញុំធ្លាប់នាំគាត់ទៅព្យាបាលភ្នែកជាមួយគ្រូខ្មែរបុរាណ ប៉ុន្តែភ្នែករបស់គាត់មិនបានប្រសើរឡើងវិញនោះទេ។

ក្រោយមកម្ដាយខ្ញុំ សម្រេចចិត្តនាំឪពុកខ្ញុំ បងស្រីទី២ និងប្អូនស្រីពៅ ដែលទើបនឹងកើតទៅរស់នៅនិងធ្វើស្រែចម្ការឯស្រុកកំណើតខាងឪពុកខ្ញុំវិញដែលស្ថិតក្នុងឃុំអញ្ចាញរូង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ នៅទីនោះមានចម្ងាយប្រហែលជា៣០គីឡូម៉ែត្រពីផ្ទះដែលខ្ញុំរស់នៅ។ ម្ដាយឪពុករបស់ខ្ញុំ សាងសង់ខ្ទមមួយប្រក់ដំបូលស្បូវនិងបាំងជញ្ជាំងស្លឹកត្នោតក្បែរទំនប់ព្រែកមួយដែលជីកតាំងពីសម័យខ្មែរក្រហម។ នៅទីនោះសម្បូរទៅដោយព្រៃក្រាស់ៗ និងមាន



នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ម្ដាយរបស់ខ្ញុំឈ្មោះ ឃីកួន ធ្វើតេស្តរហ័សរកឃើញវិជ្ជមានមេរោគកូវីត១៩ ហើយក្រុមគ្រូពេទ្យទៅទទួលគាត់យកទៅដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលព្យាបាលជំងឺ កូវីដ ១៩ កម្រិតស្រាលនៅស្ពានអូឡាំពិក។ ម្ដាយរបស់ខ្ញុំធ្វើមរណកាលនៅវេលាម៉ោង ១១ និង២២នាទីព្រឹក ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២១ នៅមណ្ឌលព្យាបាលជំងឺកូវីដ១៩កម្រិតស្រាលនៅ ស្ពានអូ ឡាំពិក។ (ក្រុមគ្រូពេទ្យដឹកអ្នកជំងឺកូវីដ-១៩/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សភាពស្វាត់ជ្រងំ ហើយរាល់ពេលល្ងាចឡើងហ្វូងសត្វចចកយំលាន់ឮពាសពេញព្រៃ។ ចំណែកខ្ញុំនិងបងៗ រស់នៅផ្ទះក្នុងភូមិអន្លង់ដែល និងជារឿយៗម្ដាយខ្ញុំ មកសួរសុខទុក្ខខ្ញុំនិងបងប្អូន។

រហូតដល់ចុងឆ្នាំ ២០០៣ ឪពុកខ្ញុំ ទទួលបានការព្យាបាលភ្នែករបស់គាត់នៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំងដោយក្រុមគ្រូពេទ្យស្ម័គ្រចិត្តជនជាតិបរទេស។ បន្ទាប់ពីព្យាបាល ភ្នែករបស់គាត់អាចមើលឃើញបានច្បាស់និងអាចត្រឡប់មកធ្វើការងារបានធម្មតាវិញ។ រហូតដល់ចុងឆ្នាំ ២០០៥ ឪពុកខ្ញុំ កើតជំងឺផ្ដាសាយធំ ហើយស្លាប់នៅពេលព្រឹកព្រលឹមក្នុងខ្ទមនោះ។ នៅពេលដែលឪពុកខ្ញុំស្លាប់ គឺមានតែម្ដាយខ្ញុំទេដែលរស់នៅក្នុងខ្ទមជាមួយគាត់។ ម្ដាយខ្ញុំមានភាពភ័យតក់ស្លុតយ៉ាងខ្លាំងចំពោះការស្លាប់របស់ឪពុកខ្ញុំ។ គាត់រៀបចំសាកសពឪពុកខ្ញុំ រួចដុតចង្កៀងបំភ្លឺក្នុងខ្ទម បន្ទាប់មកម្ដាយខ្ញុំរត់ទៅហៅអ្នកភូមិ ដែលរស់នៅចម្ងាយប្រហែលជា ២ គីឡូម៉ែត្រពីគ្នា ដើម្បីសុំឲ្យអ្នកភូមិជួយ និងយកដំណឹងស្លាប់របស់ឪពុកខ្ញុំទៅប្រាប់ដល់កូនៗដើម្បីយកសាកសពឪពុកខ្ញុំមករៀបចំពិធីបុណ្យនៅក្នុងភូមិអន្លង់។ បន្ទាប់ពីរៀបចំពិធីបុណ្យសពឪពុកខ្ញុំរួចរាល់ ម្ដាយខ្ញុំត្រឡប់មករស់នៅជុំគ្នាជាមួយកូនៗវិញ។

ក្នុងឆ្នាំ២០០៧ ម្ដាយខ្ញុំធ្លាក់ខ្លួនឈឺ ហើយមកព្យាបាលនៅមន្ទីរពេទ្យសម្ដេចឪនៅភ្នំពេញ។ បេះដូងរបស់ម្ដាយខ្ញុំបេះតែលោតលឿនខ្លាំងខុសធម្មតា។ គាត់ទទួលបានការព្យាបាលជំងឺបេះដូងរបស់គាត់រហូតត្រឡប់មកជាធម្មតាវិញ។ ម្ដាយខ្ញុំរស់នៅជាស្ត្រី មេម៉ាយ ដោយខិតខំចិញ្ចឹមបីបាច់កូនៗតែម្នាក់ឯង។ គាត់មិនដែលរអ៊ូរទាំឡើយ។

ថ្ងៃមួយកាលពីជាង ១ ឆ្នាំមុន ម្ដាយខ្ញុំវិលមុខដួលទៅលើដី។ ខ្ញុំនិងបងប្អូនភ័យខ្លាំងណាស់ រួចនាំគាត់ទៅពិនិត្យមើលអាការនៅឯមន្ទីរពេទ្យឯកជនមួយក្នុងស្រុកបរិបូណ៌។ គ្រូពេទ្យ បូមឈាមរបស់គាត់ទៅពិនិត្យរួចធ្វើរោគវិនិច្ឆ័យឃើញថា គាត់មានមេរោគក្នុងក្រពះ។ គ្រូពេទ្យបានផ្សំថ្នាំលេប និងចាក់សេរ៉ូមជំនួយកម្លាំងដល់គាត់។ ខណៈពេលនោះ ខ្ញុំមានបំណងចង់ឲ្យគ្រូពេទ្យពិនិត្យមើលបេះដូងរបស់គាត់ដែរ ប៉ុន្តែមន្ទីរពេទ្យនោះមិនមានឧបករណ៍សម្រាប់វាស់បេះដូងទេ។

ជារឿយៗ ម្ដាយខ្ញុំ មានអាការក្រហាយក្រហល់នៅក្នុងពោះរបស់គាត់ រាល់ពេលគាត់ហូបអាហារឆៅ ឬអាហារផ្អាប់ម្ដងៗ។ ខ្ញុំសម្រេចចិត្តយកគាត់មកពិនិត្យព្យាបាលនៅមន្ទីរពេទ្យសម្ដេចឪនៅក្នុងទីក្រុងភ្នំពេញ។ ក្រោយពីពិនិត្យឈាម ខ្ញុំស្នើសុំឲ្យគ្រូពេទ្យពិនិត្យមើលបេះដូងរបស់គាត់ ព្រោះខ្ញុំបារម្ភថា ភាពតក់ស្លុតដែលគាត់បានប្រឈមមុខតែម្នាក់ឯងកាលពី១០ឆ្នាំមុននៅពេលដែលឪពុកខ្ញុំស្លាប់ អាចប៉ះពាល់ដល់បេះដូងរបស់គាត់។ គ្រូពេទ្យបានស្ទង់មើលចង្វាក់បេះដូង ហើយពិនិត្យឃើញថាបេះដូងរបស់គាត់មានសភាពធម្មតាទេ។ គ្រូពេទ្យប្រាប់ថាម្ដាយខ្ញុំមានជំងឺក្រពះពោះវៀន ហើយគ្រូពេទ្យផ្សំថ្នាំលេបមួយចំនួន ដើម្បីឲ្យម្ដាយខ្ញុំយកមកលេបព្យាបាលនៅផ្ទះដោយខ្លួនឯង។

មួយរយៈពេលក្រោយមក ម្ដាយរបស់ខ្ញុំបានត្អូញត្អែរថា គាត់ឆ្អល់និងបេះតែក្ដៅនៅក្នុងពោះទៀត។ នៅពេលនោះ ជំងឺកូវីដ១៩ មានការឆ្លងរីក

រាលដាលខ្លាំង ហើយខ្ញុំមិនហ៊ានយកគាត់មកពិនិត្យនៅមន្ទីរពេទ្យក្នុងទីក្រុងភ្នំពេញទេ។ ខ្ញុំនិងបងប្អូនបានសម្រេចចិត្តយកគាត់មកពិនិត្យនៅមន្ទីរពេទ្យឯកជនក្នុងស្រុករលាប្អៀរម្តង។ បន្ទាប់ពីពិនិត្យជំងឺម្តាយខ្ញុំរួច គ្រូពេទ្យនៅមន្ទីរពេទ្យនោះ ប្រាប់ថាគាត់មានជំងឺក្រពះពោះវៀន រួចផ្សំថ្នាំឲ្យម្តាយរបស់ខ្ញុំលេប។ បន្ទាប់ពីលេបថ្នាំនោះរួច ម្តាយខ្ញុំធូរស្បើយបានមួយរយៈពេលទៀត។

រហូតមកដល់ខែឧសភា ឆ្នាំ២០២១ ម្តាយខ្ញុំមានអាការវិលមុខជាប្រចាំ។ បងស្រីទី១របស់ខ្ញុំ នាំគាត់មកពិនិត្យនិងព្យាបាលនៅមន្ទីរពេទ្យឯកជនមួយក្បែរផ្សារពង្រ ក្នុងស្រុករលាប្អៀរដដែល។ គ្រូពេទ្យ បានពិនិត្យនិងធ្វើរោគវិនិច្ឆ័យ ទើបដឹងថាបេះដូងរបស់ម្តាយខ្ញុំលោតយឺតខុសចង្វាក់។ បន្ទាប់មក គ្រូពេទ្យបានចេញវេជ្ជបញ្ជាឲ្យទិញថ្នាំលេប។ ម្តាយខ្ញុំលេបថ្នាំតាមវេជ្ជបញ្ជារបស់គ្រូពេទ្យបានចំនួន ៣ពេល រួចក៏ឈប់លេបបន្ទាប់ពី គាត់កត់សម្គាល់ឃើញថាមានអាការខុសប្រក្រតី ដូចជាងងុយដេក អស់កម្លាំង ល្ហិតល្ហៃ ហើមដៃជើងនិងហើមមុខជាដើម។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ បងស្រីខ្ញុំជូនម្តាយខ្ញុំមកភ្នំពេញដើម្បីព្យាបាលជំងឺរបស់គាត់។ ខ្ញុំបានទាក់ទងមន្ទីរពេទ្យឯកជនមួយក្នុងទីក្រុងភ្នំពេញដើម្បីងាយស្រួលក្នុងការពិគ្រោះ និងព្យាបាល។ ម្តាយខ្ញុំបានមកដល់មន្ទីរពេទ្យនៅម៉ោងប្រហែល ៣រសៀល។ មុនចូលទៅទទួលការព្យាបាល គ្រូពេទ្យតម្រូវឲ្យម្តាយខ្ញុំបំពេញសំណុំបែបបទឯកសារ កូវីដ១៩ និងបានធ្វើតេស្តរហ័សដើម្បីរកមេរោគកូវីដ១៩។ ម្តាយខ្ញុំជួបជាមួយគ្រូពេទ្យបរទេសម្នាក់។ គ្រូពេទ្យ សួរនាំអាការនិងវាស់ស្ទង់បេះដូងរបស់ម្តាយខ្ញុំ ហើយរកឃើញថាចង្វាក់បេះដូងរបស់គាត់លោតយឺត។ គ្រូពេទ្យ បានបញ្ជូនម្តាយខ្ញុំឲ្យទៅជួបជាមួយគ្រូពេទ្យខ្មែរដែលមានឯកទេសជំងឺបេះដូង។ គ្រូពេទ្យខ្មែរបានយកម្តាយខ្ញុំទៅពិនិត្យចង្វាក់បេះដូង បន្ទាប់មកគ្រូពេទ្យយកគាត់ទៅពិនិត្យអេកូបេះដូងបន្ថែមទៀត។ បន្ទាប់ពី គ្រូពេទ្យខ្មែរពិនិត្យឃើញថាចង្វាក់បេះដូងរបស់ម្តាយខ្ញុំដើរយឺតខុសធម្មតា គាត់ក៏ចេញវេជ្ជបញ្ជាឲ្យថ្នាំលេបដើម្បីតាមដានសុខភាពរបស់គាត់រយៈពេលមួយសប្តាហ៍សិន ហើយអនុញ្ញាតឲ្យគាត់មកសម្រាកនៅផ្ទះវិញ។ បន្ទាប់ពីម្តាយខ្ញុំលេបថ្នាំបានរយៈពេល៥ថ្ងៃ ខ្ញុំសម្គាល់ឃើញថាចង្វាក់បេះដូងរបស់គាត់ដើរលឿនល្អជាងមុន។

ព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ម្តាយខ្ញុំចុកពោះរាកនិងឈឺក្តៅក្នុងពោះ ខ្ញុំបានហៅទូរសព្ទទៅពិគ្រោះជាមួយគ្រូពេទ្យបរទេសម្នាក់ទៀត។ គ្រូពេទ្យ ចេញវេជ្ជបញ្ជាឲ្យទិញថ្នាំ និងប្រាប់ឲ្យម្តាយខ្ញុំឈប់លេបថ្នាំបេះដូងដែលខ្ញុំធ្លាប់ឲ្យគាត់លេប។ ម្តាយខ្ញុំចាប់ផ្តើមលេបថ្នាំទៅតាមវេជ្ជបញ្ជាថ្មី ហើយចង្វាក់បេះដូងរបស់គាត់បានប្រសើរឡើងវិញយ៉ាងច្រើន។ បន្ទាប់ពីទទួលបានការព្យាបាលរួចមក ម្តាយខ្ញុំ សុំត្រឡប់ទៅស្រុកកំណើតវិញ ដោយសារគាត់មិនចូលចិត្តរស់នៅទីក្រុងនោះទេ។

នៅពេលដែលម្តាយ និងបងស្រីរបស់ខ្ញុំធ្វើដំណើរត្រឡប់ទៅផ្ទះបាន១ថ្ងៃ គាត់ទទួលបានដំណឹងថា ឡានដែលគាត់ជិះទៅផ្ទះនោះ មានដឹកអ្នកដំណើរវិជ្ជមានកូវីដ១៩ម្នាក់។ អាជ្ញាធរតម្រូវឲ្យម្តាយខ្ញុំនិងបងស្រីរបស់ខ្ញុំធ្វើចត្តាឡីស័ក១៤ថ្ងៃ នៅវិទ្យាល័យហ៊ុនសែនបរិបូណ៌។ បងស្រីរបស់ខ្ញុំស្នើសុំឲ្យម្តាយខ្ញុំធ្វើចត្តាឡីស័កនៅផ្ទះព្រោះស្ថានភាពសុខភាពរបស់គាត់មិនល្អ ប៉ុន្តែសាលាស្រុកមិនអនុញ្ញាតទេ។

ម្តាយខ្ញុំនិងបងស្រី រួមទាំងអ្នកបើកឡាន ត្រូវទៅធ្វើចត្តាឡីស័កនៅក្នុងមណ្ឌលចត្តាឡីស័កដែលរៀបចំនៅក្នុងសាលារៀន។ អ្នកជាប់ពាក់ព័ន្ធជាមួយអ្នកវិជ្ជមានជំងឺកូវីដ១៩ចំនួន៤នាក់ ត្រូវស្នាក់នៅក្នុងបន្ទប់តែមួយ។ នៅក្នុងមណ្ឌលធ្វើចត្តាឡីស័ក មានបន្ទប់ទឹករួមមួយ និងកន្ទួរពិដានពីរ និងគ្រែសម្រាកចំនួន៤ស្ថិតនៅតាមជ្រុងបន្ទប់ឃ្លាតពីគ្នា។ គ្រែរបស់បងស្រីនិងម្តាយខ្ញុំនៅក្បែរគ្នា។ នៅក្នុងមណ្ឌលធ្វើចត្តាឡីស័ក មានអ្នកយាមនៅខាងក្រៅ និងមានការរៀបចំបាយម្ហូបចំនួន ៣ពេលក្នុងមួយថ្ងៃសម្រាប់អ្នកធ្វើចត្តាឡីស័ក។ ម្តាយខ្ញុំគាត់ពិបាកហូបអាហារដែលចុងភៅធ្វើឲ្យណាស់ ដូច្នេះហើយបងប្អូនរបស់ខ្ញុំនាំគ្នាយកបាយម្ហូបឲ្យគាត់ជារៀងរាល់ថ្ងៃ។

ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២១ គាត់ធ្វើតេស្តរកមេរោគកូវីដ១៩ ហើយទទួលបានលទ្ធផលអវិជ្ជមាន។ ម្តាយ និងបងស្រីរបស់ខ្ញុំ បានចេញពីមណ្ឌលធ្វើចត្តាឡីស័ក ហើយត្រឡប់មកផ្ទះវិញ។ មិនយូរប៉ុន្មាន បងស្រីទី២ របស់ខ្ញុំដែលជាកម្មកររោងចក្រ ទទួលបាន

ដំណឹងថា គាត់វិជ្ជមានកូវីដ១៩។ ម្ដាយខ្ញុំ បារម្ភបងស្រីរបស់ខ្ញុំខ្លាំងណាស់ រហូតឡើងសម្ពាធឈាមរហូតដល់១៩ ហើយសុខភាពរបស់គាត់ធ្លាក់ចុះ និងមិនប្រសើរឡើងវិញទេ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ ម្ដាយខ្ញុំមកដល់ភ្នំពេញនៅម៉ោង១១ព្រឹក ដើម្បីពិនិត្យតាមដានបេះដូងរបស់គាត់ទៀត។ ម្ដាយខ្ញុំនិងខ្ញុំចូលទៅបំពេញសំណុំឯកសារពាក់ព័ន្ធនឹងជំងឺកូវីដ១៩ រួចចូលទៅជួបជាមួយគ្រូពេទ្យ។ ពេលនោះម្ដាយខ្ញុំមានអាការចុក និងក្ដៅក្នុងពោះ ណែនចុងដង្ហើម ពិបាកក្នុងការដកដង្ហើម។ គ្រូពេទ្យបរទេសម្នាក់បានពិនិត្យឈាម និងអេកូពោះរបស់ម្ដាយខ្ញុំ ប៉ុន្តែមិនបានអេកូបេះដូងឲ្យគាត់នោះទេ ព្រោះគ្រូពេទ្យដែលពិនិត្យបេះដូងនៅមន្ទីរពេទ្យនោះជាប់រវល់មិនអាចពិនិត្យឲ្យគាត់បាន។ គ្រូពេទ្យបរទេស ចេញវេជ្ជបញ្ជាឲ្យម្ដាយខ្ញុំទិញថ្នាំលេប ហើយឲ្យគាត់តាមដានសុខភាពមួយសប្ដាហ៍បន្តទៀត។ ថ្ងៃនោះខ្ញុំនិងម្ដាយខ្ញុំអង្គុយរង់ចាំលទ្ធផលឈាមរហូតដល់ម៉ោង៥ល្ងាច ធ្វើឲ្យម្ដាយខ្ញុំមានភាពតានតឹងយ៉ាងខ្លាំង។ នៅពេលមកដល់ផ្ទះ ម្ដាយខ្ញុំព្យាយាមលេបថ្នាំបានរយៈពេល៣ថ្ងៃ ហើយអាការរបស់គាត់នៅតែចុកក្ដៅ និងណែនចុងដង្ហើមដដែល។ គាត់ហូបអាហារមិនសូវបានទេ ហើយថែមទាំងសម្រាន្តមិនសូវលក់ទៀត។ បេះដូងរបស់ម្ដាយខ្ញុំបានចាប់ផ្ដើមត្រឡប់មកដើរយឺតវិញម្ដងទៀត។ ខ្ញុំពិភាក្សាជាមួយម្ដាយខ្ញុំថាចង់ឲ្យគាត់ទៅសម្រាកនៅមន្ទីរពេទ្យដើម្បីតាមដានសុខភាពតែម្ដង ប៉ុន្តែម្ដាយខ្ញុំគាត់មិនព្រមទៅមន្ទីរពេទ្យនោះទៀតទេ ព្រោះគាត់មិនសប្បាយចិត្តនឹងសេវាកម្មរបស់ពេទ្យ។

ខ្ញុំឃើញម្ដាយខ្ញុំមិនសប្បាយចិត្តដូច្នោះ ក៏ពិភាក្សាជាមួយបងប្រុសនិងបងស្រីរបស់ខ្ញុំ ហើយសម្រេចចិត្តថា យកម្ដាយខ្ញុំទៅជួបជាមួយគ្រូពេទ្យឯកទេសបេះដូងថ្មីមួយទៀតម្ដុំទួលគោកវិញ។ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ខ្ញុំនាំម្ដាយខ្ញុំទៅជួបគ្រូពេទ្យនៅទីនោះ។ គ្រូពេទ្យ សាកសួរពីអាការជំងឺរបស់ម្ដាយខ្ញុំ និងពិនិត្យមើលថ្នាំដែលគាត់កំពុងតែលេប ហើយក៏បានដកថ្នាំមួយមុខចេញ រីឯថ្នាំដែលនៅសេសសល់គាត់អនុញ្ញាតឲ្យបន្តលេបតាមធម្មតា។ គ្រូពេទ្យបានណាត់ម្ដាយខ្ញុំឲ្យទៅធ្វើតេស្តឈាមនៅព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ថែមទាំងបំពាក់ម៉ាស៊ីនតាមដានបេះដូង២៤ម៉ោងដល់គាត់ ដើម្បីតាមដានចង្វាក់បេះដូងឲ្យបានច្បាស់លាស់។ ព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១ ម្ដាយខ្ញុំត្រឡប់ទៅមន្ទីរពេទ្យម្ដងទៀតដើម្បីដោះម៉ាស៊ីនបេះដូង និងទទួលលទ្ធផលឈាម។ បន្ទាប់ពីលទ្ធផលឈាមចេញមក គ្រូពេទ្យក៏ចេញវេជ្ជបញ្ជាឲ្យម្ដាយខ្ញុំទិញថ្នាំយកមកលេបបន្ត។ គ្រូពេទ្យ និយាយមកកាន់ខ្ញុំថាម្ដាយខ្ញុំត្រូវដាក់ថ្មបេះដូងប្រសិនបើការប្រើប្រាស់ថ្នាំដែលពេទ្យផ្ដល់ឲ្យមិនមានប្រសិទ្ធភាពទេនោះ។ ម៉ោងប្រហែល១២យប់ថ្ងៃដដែល ម្ដាយខ្ញុំមានអាការក្ដៅខ្លួនយ៉ាងខ្លាំង ដែលកំដៅរបស់គាត់ឡើងរហូតដល់៣៨អង្សា។ ខ្ញុំសួរទៅគ្រូពេទ្យខ្លាចក្រែងម្ដាយខ្ញុំប្រតិកម្មជាមួយនឹងថ្នាំដែលគ្រូពេទ្យបានឲ្យ ប៉ុន្តែគ្រូពេទ្យប្រាប់ថា ម្ដាយខ្ញុំប្រហែលជាគ្រុនក្ដៅទេ។ គ្រូពេទ្យបានប្រាប់ខ្ញុំឲ្យថ្នាំបញ្ចុះកំដៅទៅម្ដាយខ្ញុំលេប ហើយប្រសិនបើម្ដាយខ្ញុំមិនបានធូរស្រាលទេ គ្រូពេទ្យឲ្យខ្ញុំនាំគាត់ត្រឡប់ទៅពេទ្យពិនិត្យម្ដងទៀត។ ខ្ញុំឲ្យថ្នាំម្ដាយខ្ញុំលេបទៅតាមដែលពេទ្យណែនាំ ហើយមួយថ្ងៃក្រោយមក ម្ដាយខ្ញុំមានអាការក្អកញឹកញាប់ ឈឺក និង ក្ដៅខ្លួនមិនបាត់សោះ។ ពេលនោះ ខ្ញុំសង្ស័យថាម្ដាយខ្ញុំឆ្លងមេរោគកូវីដ១៩ ព្រោះអាការរបស់គាត់មានដូចទៅនឹងអ្វីដែលអ្នកជំងឺកូវីដ១៩មាន។

ព្រឹកថ្ងៃអង្គារ៍ ទី២៩ ខែមិថុនា ឆ្នាំ២០២១ ខ្ញុំជូនម្ដាយខ្ញុំទៅជួបពេទ្យម្ដងទៀតនៅបន្ទប់ពិគ្រោះជំងឺបេះដូង។ ដូចសព្វដង ខ្ញុំនិងម្ដាយខ្ញុំធ្វើតេស្តរហ័សរកមេរោគកូវីដ១៩ មុនចូលទៅជួបជាមួយគ្រូពេទ្យនៅក្នុងមន្ទីរពេទ្យ។ ក្រោយរង់ចាំលទ្ធផលតេស្ត ពេទ្យប្រាប់មកខ្ញុំវិញថា ម្ដាយខ្ញុំសង្ស័យឆ្លងជំងឺកូវីដ១៩។ ចំណែកលទ្ធផលរបស់ខ្ញុំគឺអវិជ្ជមាន។ គ្រូពេទ្យបានប្រាប់ឲ្យនាំម្ដាយខ្ញុំមកធ្វើតេស្តយកសំណាករកមេរោគកូវីដ១៩នៅសាលាបាក់ទូក។ ម្ដាយខ្ញុំធ្វើតេស្តរហ័សរកឃើញវិជ្ជមានមេរោគកូវីដ១៩។ នៅពេលទទួលបានលទ្ធផល អ្នកជំងឺវិជ្ជមានកូវីដ១៩ ត្រូវរៀបចំឲ្យអង្គុយរង់ចាំនៅក្នុងរោងដែលមានខ្សែព័ទ្ធជុំវិញ។ រហូតដល់ម៉ោង៦ល្ងាច ទើបក្រុមគ្រូពេទ្យទៅទទួលយកម្ដាយខ្ញុំ និងអ្នកជំងឺផ្សេងទៀតទៅដាក់សម្រាកព្យាបាលនៅ

មណ្ឌលព្យាបាលជំងឺកូវីដ១៩ កម្រិតស្រាលនៅស្តាតអូឡាំពិក ។ នៅទីនោះ ម្តាយខ្ញុំស្នាក់នៅជាន់ទី១ គ្រែលេខ ១៩៧ F1។

ព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ម្តាយខ្ញុំហូបអាហារមិនបានទេ ហើយគាត់បេះតែក្អួតៗ ពេទ្យបានបញ្ជូនម្តាយខ្ញុំមកស្នាក់នៅបន្ទប់សង្គ្រោះបន្ទាន់ជាន់ផ្ទាល់ដីវិញ។ គ្រូពេទ្យចាក់ថ្នាំឲ្យម្តាយខ្ញុំមួយម្ជុល និងដាក់សេរ៉ូម ហើយដាក់ឧបករណ៍ចាប់ចង្វាក់បេះដូងជាប់នៅនឹងខ្លួនរបស់គាត់ដោយមិនអាចចេញដើរបុង្គុតទឹកបានទេ។ យប់ថ្ងៃទី០២ខែកក្កដា ឆ្នាំ២០២១ នៅពេលដែលម្តាយខ្ញុំកំពុងតែសម្រាន្តលក់ ស្រាប់តែអ្នកដឹកជញ្ជូនធុងអុកស៊ីសែនធ្វើឲ្យធុងនោះរអិលដួលផ្ទុះឡើងហើយបានធ្វើឲ្យម្តាយខ្ញុំភ្ញាក់ឡើងភ័យយ៉ាងខ្លាំងរហូតធ្វើឲ្យបេះដូងគាត់លោតញាប់និងបណ្តាលឲ្យគាត់សន្លប់ភ្លាមៗ។ ក្រុមគ្រូពេទ្យបានជួយសង្គ្រោះដល់គាត់ដោយធ្វើចង្វាក់បេះដូងអស់រយៈពេលប្រហែលមួយម៉ោងទើបគាត់ដឹងខ្លួនត្រឡប់មកវិញ។ នៅព្រឹកថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០២១ ម្តាយខ្ញុំត្រឡប់មកសភាពធម្មតាវិញដោយអាចនិយាយលេងជាមួយខ្ញុំ និងអាចហូបអាហារបានល្មមគួរសម។ ម្តាយខ្ញុំនិយាយប្រាប់ខ្ញុំថា គាត់ជាពីជំងឺកូវីដ១៩ហើយ ព្រោះគាត់អត់សូវក្អកទៀតទេ ហើយក៏មិនមានធ្វើឲ្យក្តៅខ្លួនអ្វីទៀតដែរ។

នៅយប់ថ្ងៃទី០៣ខែកក្កដាដដែល មានរឿងធ្វើអត្តឃាតរបស់បុរសម្នាក់ដោយអារអណ្តាតនិងចាក់ពោះខ្លួនឯងស្លាប់ភ្លាមៗនៅក្នុងមន្ទីរពេទ្យនោះ។ នៅយប់ថ្ងៃទី០៤ខែកក្កដាឆ្នាំ២០២១ ធុងអុកស៊ីសែនក៏ដួលនៅខាងក្រៅម្តងទៀត ។ ម្តាយខ្ញុំជួបតែរឿងភ័យខ្លាចស្ទើររាល់ថ្ងៃ។

ថ្ងៃទី០៦ខែកក្កដាឆ្នាំ២០២១ ម៉ោងប្រហែល១០នាទី ព្រឹក បន្ទាប់ពីម្តាយខ្ញុំហូបបបរដែលជាអាហារពេលព្រឹករបស់គាត់រួចរាល់ គាត់មានអាការញ័រក្នុងពោះ និងមានអារម្មណ៍រង្វាញាក់ៗ បងស្រីរបស់ខ្ញុំបានទៅឱបម្តាយខ្ញុំបីត្រកងឡើង ហើយម្តាយខ្ញុំក៏ដំដ្កក់ដង្ហើមចុងក្រោយ រួចផុតដង្ហើមលែងដឹងខ្លួន។ គ្រូពេទ្យនៅទីនោះ ព្យាយាមជួយសង្គ្រោះគាត់ណាស់ ប៉ុន្តែមិនអាចជួយម្តាយខ្ញុំបាននោះទេ។ ម្តាយខ្ញុំស្លាប់នៅវេលាម៉ោង ១១ និង ២២ នាទីព្រឹក ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០២១។

សាកសពម្តាយខ្ញុំ ត្រូវក្រុមគ្រូពេទ្យដឹកយកទៅទុកនៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតរង់ចាំថ្ងៃបូជា។ ខ្ញុំនិងក្រុមគ្រួសារត្រូវរង់ចាំរហូតដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០២១ ទើបសាកសពម្តាយខ្ញុំយកទៅបូជានៅវេលាម៉ោង១១ និង ៤៨ នាទីយប់ក្នុងវត្តបុស្សស្បូវសាញ់ក្នុងទីក្រុងភ្នំពេញ។

ខ្ញុំខ្លាចជំងឺកូវីដ១៩ណាស់ ប៉ុន្តែអ្វីដែលខ្ញុំខ្លាចបំផុតនោះគឺរឿងរ៉ាវដែលបានកើតឡើងចំពោះម្តាយរបស់ខ្ញុំ ។



រូបរាប់ពីឆ្វេង យី សុខន (កូនទី៤), រិន ឡាគីន (ក្មួយប្រុស), ភីម សាមឿន (បងប្អូនជីដូនមួយនិងត្រូវជាម្តាយក្មួយប្រុស), យី យ៉ានូ (កូនពៅ), យី ក្លួន (ម្តាយ), កូយ ស្រីដាវ (កូនទី១), ម៉ប់ ស៊ីឡុង (កូនប្រសារ), យាង មិនា (ចៅស្រី), យី សុខា (កូនទី៣) និង យី សុឃី។ រូបថតនេះ ថតនៅយប់ថ្ងៃអង្គារ ទី ៤ ខែមេសា ឆ្នាំ២០១៧ នៅផ្ទះស្ថិតនៅក្នុងភូមិអង្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ក្នុងពិធីបុណ្យចម្រើនព្រះជន្មឆាក ពុទ្ធាភិសេក និងគម្រប់ខួប១១ឆ្នាំនៃការធ្វើមរណកាលរបស់ឪពុកខ្ញុំ។ (យី សុឃី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ថោង សានៈ អតីតកងឈ្លបឃុំខ្មែរក្រហម

**សុខ វណ្ណៈ**

ខ្ញុំឈ្មោះ ថោង សាន មានអាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅភូមិជាំតាម៉ៅ ខាងកើត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានប្រពន្ធឈ្មោះជួន អាយុ៦០ឆ្នាំ ហើយសព្វថ្ងៃយើងមានកូនប្រុសចំនួនពីរនាក់។ ខ្ញុំនិងប្រពន្ធប្រកបមុខរបរធ្វើស្រែចម្ការ។ ខ្ញុំមានបងប្អូនបង្កើតពីរនាក់។ ខ្ញុំមានឪពុកឈ្មោះ ថោង និងម្តាយឈ្មោះ ហួន ស្លាប់នៅក្នុងសម័យខ្មែរក្រហម។ កាលពីកុមារភាព ខ្ញុំចូលរៀននៅតាមសាលាបុណ្យនៅក្នុងភូមិ ព្រោះពេលនោះគ្មានសាលារៀនទេ។ នៅភូមិឈូក កាលពីសម័យមុនមិនមានផ្លូវល្អសម្រាប់ធ្វើដំណើរទេ។ ប្រជាជនភាគច្រើនដើរថ្មើរជើង ឬជិះរទេះគោក្របី។ នៅខ្ញុំដឹងក្តី ឡើងខ្ញុំឃើញនៅក្នុងភូមិសម្បូរដើមឈើធំៗ និងមានព្រៃព័ទ្ធជុំជិត ហើយប្រជាជននៅភូមិឈូក មានមិនដល់៥០គ្រួសារទេ។ តាមដែលខ្ញុំចាំ កាលពីជំនាន់ឪពុកម្តាយជីដូនជីតាខ្ញុំនៅក្មេងៗ ប្រជាជនមានចំនួនកាន់តែតិច គឺមាន២០ទៅ៣០គ្រួសារប៉ុណ្ណោះ ដែលរស់នៅលាយឡំជាមួយជនជាតិស្ទៀង។ នៅភូមិឈូក ប្រជាជនភាគច្រើនកាត់ស្ទៀងដូចជាជីដូនជីតារបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនចេះនិយាយភាសាស្ទៀងទេ។



ថោង សានមានអាយុ៦៣ឆ្នាំ រស់នៅភូមិជាំតាម៉ៅ ខាងកើត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅអំឡុងឆ្នាំ១៩៦០ មានក្រុមហ៊ុនរបស់ជនជាតិបារាំងមកដាំដើមកៅស៊ូនៅម្តុំល្វា, កំពោរ, ខ្លាយ, និងស្លាព្រោះទីតាំងទាំងនេះនៅតាមផ្លូវជាតិ ងាយស្រួលដឹកជញ្ជូនជ័រកៅស៊ូ និងមានសង់រោងចក្រចំហុយកៅស៊ូមួយទៀតនៅម្តុំខ្នងក្រពើ។ កាលនោះមានកម្មករចម្ការកៅស៊ូ ជនជាតិវៀតណាម ជនជាតិចាម និងជនជាតិខ្មែរ ដែលមានចំនួនតិចតួចប៉ុណ្ណោះ។ ខ្ញុំធ្លាប់ឃើញដើមកៅស៊ូធំៗ និងឃើញជនជាតិបារាំងដែលមានច្រមុះស្រួចជាច្រើននាក់ដើរចូលមកលេងនៅក្នុងភូមិ។

នៅឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ បណ្តាលឲ្យប្រជាជនខឹងសម្បាយ៉ាងខ្លាំង ហើយនាំគ្នាតវ៉ា និងធ្វើបាតុកម្មប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ។ ប៉ុន្តែការប្រឆាំងតវ៉ានោះមិនបានសម្រេចពីព្រោះ ទាហាន លន់ នល់ បាញ់បង្ក្រាប ហើយបាតុករនាំគ្នាត្រឡប់ទៅភូមិឋានរៀងៗខ្លួនវិញ។ បន្ទាប់មកខ្ញុំ

ឃើញមានកម្លាំងតស៊ូខ្មែរក្រហម និងកងទ័ពវៀតណាមខាងជើងបុ វៀតកុងបានចូលមកក្នុងភូមិ ហើយសង្គ្រាមក៏ចាប់កើតមានតាំងពីពេលនោះមករហូតដល់មានយន្តហោះមកទម្លាក់គ្រាប់បែកនៅក្នុងភូមិ។ នៅអំឡុងឆ្នាំនោះមានទាហានអាមេរិកាំងមាឌធំៗ ខ្ពស់ៗ ស្បែកខ្មៅ និងមានរថពាសដែកបរចូលភូមិថែមទៀត។ ទាហានអាមេរិកាំងទាំងនោះ ឈប់ចែកបារី និងស្ករគ្រាប់ឲ្យប្រជាជននៅក្នុងភូមិទៀតផង ប៉ុន្តែទាហានទាំងនោះនៅបានមួយរយៈពេលខ្លីក៏ដកទៅវិញអស់។

នៅឆ្នាំ១៩៧៣ ខ្ញុំបានស្ម័គ្រចិត្តចូលជាកងឈ្លបឃុំរបស់ខ្មែរក្រហម។ ខ្ញុំធ្វើការជាកងឈ្លបឃុំបានរយៈពេលពីរខែប៉ុណ្ណោះ ក៏ត្រូវបានអង្គការចាត់តាំងឲ្យឡើងទៅធ្វើយោធាស្រុកមេមត់ ដែលកាលនោះមិនទាន់បែងចែកស្រុកមេមត់ជាពីរទេ។ ខ្ញុំនៅយោធាស្រុកបានមួយរយៈពេលខ្លី អង្គការបញ្ជូនខ្ញុំបន្តទៅយោធាតំបន់ ២១ ។ ទៅដល់ដំបូង ខ្ញុំស្គាល់គណៈតំបន់មានឈ្មោះ សឿង, ដែន និង អ៊ុក ប៊ុនឈឿន។ បន្ទាប់មកទៀតខ្ញុំស្គាល់តាសុទ្ធ និងតាលាវ។ ខ្ញុំបានឡើងវាយជាមួយទាហាន លន់ នល់ នៅចារូ, បឹងព្រួល, កំពង់ឫស្សី និងទន្លេបិត រហូតទទួលបានជ័យជម្នះ។ ការធ្វើសង្គ្រាមនៅពេលនោះគឺ ស្លាប់កងទ័ពច្រើនណាស់ ទាំងកងទ័ពខ្មែរក្រហម ទាំងទាហាន លន់ នល់។

នៅខែកញ្ញា ឆ្នាំ១៩៧៤ ខ្ញុំរងរបួសដោយសារអំបែងគ្រាប់ដេកា៧៥ ដែលទាហាន លន់ នល់ បាញ់។ ខ្ញុំត្រូវអង្គការបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យព ២ នៅស្រុកអូររាំងឪ រហូតបានជាសះស្បើយទើបខ្ញុំចូលធ្វើការនៅអង្គភាព វរ៥៥ វិញ។

នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ របបខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំគិតថា ប្រទេសជាតិមានសុខសន្តិភាព និងមានការរីកចំរើន ផ្ទុយទៅវិញ ទាំងយោធាខ្មែរក្រហម ទាំងប្រជាជនរស់នៅលំបាកវេទនា និងរស់នៅជាមួយភាពភ័យខ្លាចជាប្រចាំ។ ប្រជាជនដែលខ្មែរក្រហមជម្លៀសចេញមកពីក្រុងភ្នំពេញមករស់នៅតាមជនបទស្រែចម្ការ ដែលមិនមែនជាស្រុកកំណើតខ្លួន និងមិនធ្លាប់ធ្វើការភ្ជួររាស់ ការងារស្រែចម្ការ ទទួលរងគ្រោះជាងប្រជាជនមូលដ្ឋាន ។

នៅអំឡុងឆ្នាំ១៩៧៥ យោធាខ្មែរក្រហមនៅក្នុងតំបន់២១ បានរៀបចំជាកងវរដើម្បីការពារព្រំដែន



បុគ្គលិកមជ្ឈមណ្ឌលឯកសា កោះថ្ម ខេត្តត្បូងឃ្មុំ ជួបសម្ភាសន៍ ថៅង សាន មានអាយុ៦៣ឆ្នាំ រស់នៅភូមិជាំតាម៉ៅ ខាងកើត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាមួយប្រទេសវៀតណាម។ កាលនោះវរ៥៥ ប្តូរហៅថា បញ្ជាការ (គ) រួមមាន (គ៦១, គ៦២, គ៦៣) ដែលដឹកនាំដោយបញ្ជាការវរមានឈ្មោះ សុខ សារឿន, សេន និង លនរឹងស្នងការនយោបាយឈ្មោះ អឿន ដែល កាលនោះមួយ(គ) មានកម្លាំង១២០នាក់។

នៅក្នុងឆ្នាំ១៩៧៥ ដដែល វរ៥៥ របស់ខ្ញុំមកឈរជើងនៅភូមិចង្កុំ និងវរ៧៥ ឈរជើងនៅភូមិកោះថ្ម ក្នុងគោលបំណងការពារព្រំដែនជាមួយប្រទេសវៀតណាម។

នៅឆ្នាំ១៩៧៧ សង្គ្រាមនៅតាមព្រំដែនជាមួយប្រទេសវៀតណាមផ្ទុះឡើង ស្របពេលនោះជម្លោះផ្ទៃក្នុងនៅក្នុងជួរកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ា និងភូមិភាគមួយចំនួនក៏កើតឡើងដែរ។ យោធាមជ្ឈិមរួមជាមួយយោធាភូមិភាគនិរតីចុះមកប្រើគោលនយោបាយលួងលោមកម្មាភិបាលថ្នាក់ស្រុកថ្នាក់តំបន់ ប្រធានយោធាស្រុក ប្រធានយោធាតំបន់ ប្រធានសេនាធិការតំបន់ក្នុងភូមិភាគបូព៌ាមួយចំនួនដោយហៅទៅរៀនសូត្រ ប៉ុន្តែតាមការពិតគឺហៅទៅដើម្បីចាប់ខ្លួននិងសម្លាប់។ ចំណែកអ្នកនៅសេសសល់មួយចំនួនទៀតដែលដឹងខ្លួនបានរត់ភៀសខ្លួនទៅប្រទេសវៀតណាម ហើយអ្នកខ្លះដែលគេចខ្លួនមិនរួចត្រូវបានសម្លាប់ទាំងអស់។ ខ្ញុំគឺ យុទ្ធជនក៏ភ័យខ្លាចដែរ ព្រោះខ្មែរក្រហមចាប់ខ្លួនមេរបស់ខ្ញុំយកទៅអស់ហើយ។ ខ្ញុំជាមួយយោធាមួយចំនួនទៀតសម្រេចចិត្តរត់គេចខ្លួន។ ខ្ញុំដោះសម្លៀកបំពាក់យោធាចេញនិងកប់កាំភ្លើង រួចបន្លំខ្លួនធ្វើការនៅក្នុងកងចល័តស្រុកត្រមូង។ ក្រោយមក ខ្ញុំបានទទួលដំណឹងថា សុទ្ធ, ដែន និង យិន សុភី គឺជាប្រធានសន្តិសុខតំបន់២១ដែលធ្លាប់ចាប់ប្រជាជនយកទៅសម្លាប់ ត្រូវបានយោធាមកពីភូមិភាគនិរតីបាញ់សម្លាប់។

នៅឆ្នាំ១៩៧៩ ខ្ញុំត្រឡប់មករស់នៅភូមិកំណើតនិងប្រកបមុខរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។ នៅឆ្នាំ ១៩៧៩ ទោះរបបខ្មែរក្រហមដួលរំលំ ប៉ុន្តែកម្លាំងខ្មែរក្រហមនៅតែប្រមូលផ្តុំគ្នានៅតាមទល់ដែនថៃ និងបានធ្វើសង្គ្រាមប្រឆាំងជាមួយរដ្ឋាភិបាលរបបសាធារណរដ្ឋកម្ពុជា និងកងទ័ពវៀតណាម។ សង្គ្រាមនៅប្រទេសកម្ពុជាបន្តរហូតដល់មានការបោះឆ្នោតរៀបចំដោយអង្គការសហប្រជាជាតិ នៅឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៨ សង្គ្រាមនៅប្រទេសកម្ពុជាបានបញ្ចប់ ទាំងស្រុងទើបប្រជាជនទូទាំងប្រទេសមានសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ និងប្រកបរបរចិញ្ចឹមជីវិត។



ចម្ការម្រេចនៅឃុំដាំតាម៉ោ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទិត្យ ផា ស្ត្រីមេម៉ាយក្នុងរបបខ្មែរក្រហម

*ពេជ សាន*



*ទិត្យ ផា សព្វថ្ងៃអាយុ៦៩ឆ្នាំ រស់នៅផ្ទះរបស់គាត់ក្នុងភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ទិត្យ ផា រៀបរាប់អំពីរឿងរ៉ាវជីវិតរបស់គាត់ដែលឆ្លងកាត់របបខ្មែរក្រហមប្រាប់ ពេជ សាន គឺជាអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅខេត្តស្វាយរៀង ដែលបានទៅសួរសុខទុក្ខគាត់កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១។ (ពេជ សាន/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី ១១ ខែសី ហា ឆ្នាំ ២០២១ តាមរយៈការងារស្ម័គ្រចិត្តនៃគម្រោងការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ពេជ សានបានទៅសួរសុខទុក្ខអ៊ំ ទិត្យ ផា ដែលរស់នៅក្បែរៗផ្ទះរបស់ខ្លួន និងស្តាប់រឿងរ៉ាវរបស់អ៊ំ ទិត្យ ផា គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានរៀបរាប់ដូចខាងក្រោម៖

ខ្ញុំឈ្មោះ ទិត្យ ផា កើតនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៥២ នៅភូមិពោធិ៍តារស់ ឃុំបាសាក់ ស្រុកស្វាយជ្រំខេត្តស្វាយរៀង។ សព្វថ្ងៃ ខ្ញុំមានអាយុ៦៩ឆ្នាំ និងរស់នៅម្នាក់ឯង។ ឪពុករបស់ខ្ញុំឈ្មោះ ទិត្យ សរ មានអាយុ៦៣ឆ្នាំ និងម្តាយឈ្មោះ ទេព យ៉ា មានអាយុ៥២ឆ្នាំ នៅអំឡុងរបបខ្មែរក្រហម។ ឪពុកម្តាយរបស់ខ្ញុំប្រកបរបរធ្វើស្រែ។ ខ្ញុំមានបងប្អូនស្រី ចំនួន ៦នាក់ គឺទី១) ឈ្មោះ ទិត្យ សាលី, ទី២) ឈ្មោះ ទិត្យ ផា, ទី៣) ឈ្មោះ ទិត្យ សុផល, ទី៤) ឈ្មោះ ទិត្យ ផាន់, ទី៥) ឈ្មោះ ទិត្យ ផន និង ទី៦) ឈ្មោះ ទិត្យ ភន។ នៅក្នុង

ចំណោមបងប្អូន៦នាក់ មានបងប្អូន៣នាក់បានស្លាប់។

រឿងរ៉ាវដែលខ្ញុំចាំមិនភ្លេច គឺនៅពេលដែលខ្មែរក្រហមចាត់តាំងឲ្យខ្ញុំធ្វើការលំបាក ទាំងខ្ញុំមានកូនខ្ចី។ ខ្មែរក្រហមបង្ខំខ្ញុំឲ្យធ្វើការ ទាំងយប់ទាំងថ្ងៃ និងគ្មានពេលសម្រាកឡើយ។ ចំណែករបបអាហារខ្ញុំមិនដែលហូបឆ្អែតឡើយ។ ខ្មែរក្រហមបំបែកខ្ញុំជាមួយ ប្តី និងកូនៗ។ ប្តីរបស់ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឲ្យធ្វើការនៅភូមិតាស្អាង ឃុំកំពង់ចម្លង ស្រុកស្វាយជ្រំ ក្រោយមកក៏ផ្លាស់ឲ្យគាត់ទៅនៅទួលថ្នស។ នៅពេលនោះខ្មែរក្រហមបែងចែកឲ្យអ្នកដែលមានកូនខ្ចី នៅសមរភូមិក្រោយ ចំណែកអ្នកគ្មានកូនគឺត្រូវទៅសមរភូមិមុខ។ ខ្មែរក្រហមចាត់តាំងឲ្យប្តីរបស់ខ្ញុំធ្វើស្រែ និងមើលថែទាំស្រូវ។ ប្តីរបស់ខ្ញុំត្រូវហែលឆ្លងទន្លេធំទៅមកដើម្បីមើលថែទាំស្រូវ។ ប្តីរបស់ខ្ញុំបានលង់ទឹកស្លាប់នៅពេលរដូវទឹកឡើង និងមានទឹកហូរខ្លាំង។ ខ្ញុំនៅចាំថា នៅវេលាម៉ោង៥រសៀលពេលខ្ញុំសម្រាក និងអង្គុយនៅចុងតុទិសខាងលិចបម្រុងនឹងហូបអាហារដែលចុងភៅដួសដាក់តម្រៀបលើតុដែលរៀបចំជាជួរវែងៗ ស្រាប់តែមានយាយម្នាក់មកពីភូមិតាស្អាងដែលអង្គុយនៅចុងតុខាងកើតនិយាយប្រាប់អ្នកនៅក្បែរគាត់ថា តាវ៉ាត់ លង់ទឹកស្លាប់ហើយ។ ពេលឮដូច្នេះ ខ្ញុំបានស្ទុះទៅសួរបញ្ជាក់គាត់ថា «នរណាស្លាប់មីង! មីងនោះមិនមើលមុខខ្ញុំទេ គឺគាត់ងាកមុខចេញ ដូច្នេះខ្ញុំសួរគាត់ម្តងទៀតថាអ្នកណាលង់ទឹកមីង! ទើបគាត់បញ្ជាក់ម្តងទៀតថា តាវ៉ាត់»។ ពេលនោះខ្ញុំរៀបដាក់បាយចូលមាត់ទៅហើយ ប៉ុន្តែនៅពេលឮឈ្មោះប្តីខ្ញុំទម្លាក់ស្លាបព្រាបាយចុះវិញ ព្រោះខ្ញុំរន្ធត់ចិត្តខ្លាំងណាស់។ ខ្ញុំរស់នៅជាស្ត្រីមេម៉ាយចាប់តាំងពីពេលនោះមក។

ខ្ញុំនៅចងចាំថា នៅពេលដែលរបបខ្មែរក្រហមចូលមកដល់ភូមិពោធិតារស់ ខ្ញុំមានអាយុ២១ឆ្នាំប៉ុណ្ណោះ។ នៅពេលនោះ ខ្ញុំមានកូនខ្ចីទើបអាយុ៣ខែ និងកូនច្បងមានអាយុ៣ឆ្នាំ។ ខ្ញុំយកកូនទៅទុកឲ្យយាយៗមើលថែទាំនៅពេលដល់ម៉ោងឈប់សម្រាកហូបអាហារ ខ្ញុំបានទៅបំបៅកូនរួចហើយទើបត្រឡប់មកហូបបាយវិញ។ នៅពេលហូបអាហារថ្ងៃត្រង់រួច ខ្ញុំត្រូវទៅបំបៅកូនម្តងទៀត ហើយដល់ម៉ោង២ទើបខ្ញុំទៅធ្វើការងារបន្ត។ ការងារដែលខ្មែរក្រហមដាក់ឲ្យគឺខ្ញុំត្រូវដេរស្លឹកត្នោតសម្រាប់ប្រក់ផ្ទះ ដោយខ្ញុំត្រូវដេរក្នុងមួយថ្ងៃឲ្យបាន៣០កណ្តប។ នៅពេលនោះខ្មែរក្រហមបែងចែកអ្នកដេរស្លឹកត្នោតជាក្រុម ដោយក្នុងមួយក្រុមមានសមាជិក១២នាក់។ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យដេរស្លឹកត្នោតរយៈពេលកន្លះខែ បន្ទាប់មកបានចាត់តាំងខ្ញុំឲ្យទៅធ្វើជីដាក់ស្រែវិញ។ ខ្ញុំដើររកដីដំបូក និងលាមកមនុស្សយកមកហាលឲ្យស្ងួតរួចដំឲ្យហ្មត់ដើម្បីប្រកដាក់ការ៉ុងទុក។ ក្នុងមួយថ្ងៃខ្ញុំត្រូវប្រមូលលាមកមនុស្សមកហាលស្ងួតឲ្យបាន ៣គីឡូក្រាម។ ខ្មែរក្រហមឲ្យខ្ញុំហូបបាយរួម ដោយក្នុងមួយថ្ងៃផ្តល់អាហារឲ្យ២ពេល។ ចុងភៅបានដាំបាយឆ្នាំងលេខ៨ ប៉ុន្តែមិនបានពេញទេ គឺបានតែកន្លះឆ្នាំងប៉ុណ្ណោះសម្រាប់មនុស្ស១០នាក់។ យើងត្រូវដួសចែករបបគ្នាឲ្យស្មើភាពប្រសិនបើនរណាដួសយកលើសគេអ្នកនោះបាត់ខ្លួនមិនខាន។ ពេលធ្វើជីបានគ្រប់គ្រាន់ហើយ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យមកធ្វើស្រែ និងដកស្ទូងវិញ។ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យស្ទូងជាក្រុម ដោយដាក់កំណត់ឲ្យស្ទូងស្រែមួយហិចតា ១៥នាក់ យើងស្ទូងឲ្យហើយក្នុងមួយថ្ងៃ។ នៅពេលខ្ញុំស្ទូងរួចហើយ ខ្មែរក្រហមឲ្យខ្ញុំទៅដកសំណាបសម្រាប់ទុកស្ទូងនៅថ្ងៃបន្ទាប់ទៀត។ ប្រសិនបើយើងដកសំណាបមិនគ្រប់ចំនួនសម្រាប់ស្ទូងទេ នៅថ្ងៃបន្ទាប់ខ្មែរក្រហមចាត់តាំងយើងឲ្យដកសំណាបទៀត ដោយក្នុងម្នាក់ដកឲ្យបាន៥០កណ្តាប់។ នៅពេលយើងដកមិនគ្រប់ចំនួនទេ ប្រធានរោងបាយចែកអាហារឲ្យយើងតិចជាងគេ ហើយខ្មែរក្រហមយកយើងទៅកសាងដោយចោទយើងថាដេកចាំស៊ីកម្លាំងបាយគេ និងខ្ជិលធ្វើការងារ។ មុនពេលខ្ញុំចេញទៅស្ទូង ខ្ញុំត្រូវក្រោកឡើងមុនគេដើម្បីឲ្យកូនបៅបន្ទាប់មកខ្ញុំយកកូនទៅផ្ញើទុកជាមួយចាស់ៗមើលថែ។ នៅពេលខ្ញុំចេញទៅស្ទូង ប្រធានកងបានផ្តល់របបអាហារពន្លឺ (អាហារពេលព្រឹក) ដោយហូបជាមួយសម្លដើមចេកលាយជាមួយត្រី និងស្ករបន្តិចបន្តួចប៉ុណ្ណោះ។ ខ្ញុំហូបសម្លនេះស្ទើររាល់ថ្ងៃ។

នៅពេលហូបម្តងៗ កងឈ្លបតាមមើលយើងរហូត ដោយមិនឲ្យយើងនិយាយស្តី ឬតមាត់ទេ ដែលនៅសម័យនោះប្រជាជននាំគ្នានិយាយថា យើងត្រូវដាំដើមគរៗ ពេលត្រឡប់មកពីស្ទូងវិញ ខ្ញុំរួសរាន់ទៅឲ្យកូនបៅសិនទើបមកហូបបាយៗ នៅពេលយើងឈឺថ្កាត់ម្តងៗ ខ្មែរក្រហមចោទយើងថា «ខ្ជិល» ឬប្រើពាក្យស្លោកប្រៀបធៀបថា «ដេកដួល រមួល ដង្វំគ្រេច» គឺតាមដែលខ្មែរក្រហមចោទយើងៗ ជាទូទៅពេលវេលាធ្វើការងារ គឺខ្ញុំចេញទៅធ្វើការនៅម៉ោង៦ព្រឹក ប៉ុន្តែបើអ្នកស្ទូង អ្នកភ្ជួរ គឺត្រូវក្រោកទៅធ្វើការតាំងពីម៉ោង៤ទៀបភ្លឺៗ ខ្ញុំធ្វើការនៅក្នុងភូមិរយៈពេល២ឆ្នាំ ទើបខ្មែរក្រហមជម្លៀសខ្ញុំទៅភូមិភាគពាយ័ព្យៗ

ខ្ញុំនិងគ្រួសារដើរពីផ្ទះនៅខេត្តស្វាយរៀងទៅអ្នកលឿង រួចជិះកប៉ាល់បន្តទៅឈប់នៅច្បារអំពៅក្នុងក្រុងភ្នំពេញៗ ខ្ញុំសម្រាកនៅច្បារអំពៅរយៈពេល១យប់ ដោយយប់នោះ ខ្មែរក្រហមបញ្ចាំងកុនបង្ហាញពីការតស៊ូរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហមៗ ព្រឹកឡើងខ្មែរក្រហមបានយកកញ្ចប់បាយ ក្រមា សំពត់ មកចែកឲ្យខ្ញុំៗ ចំណែកខោអាវដែលមានពណ៌ យើងត្រូវយកទៅជ្រលក់ភក់ និងសម្បកឈើដើម្បីឲ្យចេញពណ៌ខ្មៅ ដើម្បីស្លៀកពាក់ៗ បន្ទាប់មកខ្ញុំបានឡើងជិះរថភ្លើងបន្តទៅខេត្តពោធិ៍សាត់ៗ នៅពេលខ្ញុំចុះពីរថភ្លើងមេឃងងឹតទៅហើយ ដូច្នេះខ្មែរក្រហមឲ្យខ្ញុំឈប់ដាំបាយហូបៗ នៅពេលហូបបាយរួច ខ្មែរក្រហមបញ្ជូនឲ្យខ្ញុំនិងគ្រួសារដើរទាំងយប់ងងឹត ដោយកុហកថាដើរទៅមុខបន្តិចទៀតដល់ហើយៗ ខ្ញុំដើរស្ទើរមួយយប់នៅតែមិនដល់ៗ នៅវេលាប្រហែលម៉ោង៣ទៀបភ្លឺ ខ្មែរក្រហមអនុញ្ញាតឲ្យយើងឈប់សម្រាកមួយរយៈពេលខ្លីរួចហើយដាស់យើងឲ្យក្រោកដើរទៅមុខទៀតៗ នៅពេលនោះដោយសារកូនរបស់ខ្ញុំនៅតូច ដូច្នេះខ្ញុំបានរែកវា ចំណែកម្តាយក្មេករបស់ខ្ញុំមានវ័យចំណាស់បានជួយទូលបង្វេចៗ ពេលខ្លះខ្ញុំយកកូនម្នាក់ដាក់ស្ពាយពីមុខ ហើយកូនម្នាក់ទៀតខ្ញុំពរពីចំហៀងៗ ខ្ញុំដើររយៈពេល២យប់ ៣ថ្ងៃ ទើបទៅដល់ទួលអន្ទេប គឺជាគោលដៅដែលខ្មែរក្រហមបានកំណត់ៗ ខ្ញុំទៅដល់ទួលអន្ទេបនៅពេលរសៀលម៉ោង៣ទៅហើយ ទើបខ្មែរក្រហមចែកបាយឲ្យយើងហូបៗ បន្ទាប់ពីយើងហូបបាយរួច ខ្មែរក្រហមអនុញ្ញាតឲ្យយើងដេកនៅទីនោះមួយយប់ៗ នៅព្រឹកថ្ងៃបន្ទាប់ ខ្មែរក្រហមបានចាត់តាំង និងបំបែកយើងឲ្យទៅធ្វើការងារនៅតាមសហករណ៍រៀងខ្លួនៗ ខ្ញុំបានរស់នៅជុំជាមួយម្តាយក្មេកបានមួយរយៈ ចំណែកម្តាយបង្កើតរបស់ខ្ញុំ ខ្មែរក្រហមបំបែកឲ្យទៅរស់នៅផ្សេងៗ រយៈពេលមិនបានប៉ុន្មានថ្ងៃផង ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅនៅសម្បុកប្រវឹក ឬហៅថាសហករណ៍អាងទំលែង គឺជាសហករណ៍គំរូ ដែលមានព្រៃដុះជុំជិត និងមើលមិនឃើញពន្លឺថ្ងៃឡើយៗ នៅទីនោះមានដើមឈើធំៗដុះគ្របពីលើ និងមានវាលស្រឡះមួយកន្លែងៗ ពេលខ្ញុំទៅដល់ដំបូង ខ្មែរក្រហមផ្តល់បាយឲ្យខ្ញុំហូបឆ្អែត ប៉ុន្តែរយៈពេលប្រមាណ ៣ថ្ងៃក្រោយមក សូម្បីតែចានឆ្នាំងក៏ខ្មែរក្រហមដកយកពីខ្ញុំដែរៗ ខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំទុករបស់របរប្រើប្រាស់ទាំងនោះទេៗ ខ្ញុំដេកនៅក្នុងរោងគោរួមជាមួយអ្នកជម្លៀសមកពីភូមិស្រុកភូមិផ្សេងៗៗ រោងគោមួយខ្មែរក្រហមឲ្យយើងដេក ៥០គ្រួសារៗ ខ្ញុំនៅចាំថាពេលនោះគ្មានគោទេ គឺខ្មែរក្រហមសង់រោងនោះសម្រាប់ឲ្យកងចល័តដេកៗ ខ្ញុំដេកលើកន្ទេលស្លឹកត្នោត ដែលខ្ញុំក្រងនិងយកមកពីខេត្តស្វាយរៀងៗ នៅពេលខ្ញុំដេក គឺមានកងឈ្លបចាំយាមៗ ខ្មែរក្រហមបានយកដើមឈើធំៗដុតភ្នក់ភ្លើងដោយសារក្នុងព្រៃសម្បូរឈើ ៗ ខ្មែរក្រហមដុតភ្នក់បំភ្លឺ ព្រោះនៅទីនោះមានសត្វឆ្កែចចកច្រើន និងតែងតែលូនៅពេលយប់ៗ ព្រឹកឡើងខ្មែរក្រហមបែងចែកខ្ញុំទៅតាមក្រុម និងបែងចែកការងារឲ្យធ្វើៗ ពេលនោះ ក្រុមមេម៉ាយ ឬហៅកងស្រួចខ្មែរក្រហមចាត់តាំងឲ្យកាប់ដីត្រឡប់ប្រវែង ១០ម៉ែត្រ សម្រាប់មនុស្សម្នាក់ៗ នៅពេលខ្ញុំកាប់ដី ហើយប៉ះចំដើមឈើ គឺខ្ញុំត្រូវកាប់រំលំ និងគាស់គល់ឈើនោះចេញទៀតៗ ពេលដល់ម៉ោងសម្រាក និងដល់ពេលត្រឡប់មកកន្លែងស្នាក់នៅវិញ ប្រធានកងឲ្យខ្ញុំលីគល់

ឈើនោះយកមកទុកនៅរោងបាយរួម ទើបខ្ញុំបានហូបបាយ។ ខ្មែរក្រហមមិនឲ្យយើងទំនេរទេ។ នៅពេលខ្ញុំហូបបាយល្ងាចរួចហើយ យាយៗបានយកកូនមកឲ្យខ្ញុំបំបៅដោះ បន្ទាប់មកប្រធានកងបានចាត់តាំងឲ្យខ្ញុំជីកស្រះរហូតដល់ម៉ោង១០យប់ ទើបបានចូលដេក។ ប្រធានកងបែងចែកក្រុមការងារ ដោយក្នុងមួយក្រុមមានសមាជិក១០នាក់ ហើយក្នុងម្នាក់ត្រូវជីកឲ្យបានប្រវែង១០ម៉ែត្រ។ ប្រសិនបើក្រុមណាជីកមិនហើយតាមផែនការ ខ្មែរក្រហមនឹងស្តីបន្ទោស ហើយយើងក៏មិនហ៊ានតវ៉ាដែរ។ នៅទីនោះចុងភៅបានដាំបាយឆ្នាំងលេខ៨ឲ្យយើងហូប ប៉ុន្តែដាំតែកន្លះឆ្នាំងប៉ុណ្ណោះសម្រាប់មនុស្ស ១០នាក់ ។ ខ្មែរក្រហមបានស្ងសម្លកន្លះឆ្នាំងលេខ៨ ដែលមានតែស្លឹកដំឡូង លាយផ្លែពោតខ្ចី និងបង់ស្ករបន្តិចបន្តួចប៉ុណ្ណោះ។ សូម្បីតែស្លឹកផ្ទីរក៏ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងបេះហូបដែរ។ ឈ្លបបានតាមដានយើងជាប្រចាំ ប៉ុន្តែប្រសិនបើអ្នកណាហ៊ានបេះស៊ីនឹងបាត់ខ្លួនមិនខាន។ ពេលខ្លះ ប្រធានកងចាត់តាំងខ្ញុំឲ្យកាប់រំលាយដំបូកទំហំប៉ុនៗកូនផ្ទះ។ បន្ទាប់មកឲ្យយើងរោយគ្រាប់ពូជដំណាំ។ ខ្ញុំធ្វើការនៅទីនោះរយៈពេល៨ខែ ទើបខ្មែរក្រហមកៀរខ្ញុំទៅកន្លែងផ្សេង។ ខ្ញុំដើរតាំងពីព្រឹកទល់ល្ងាចទើបទៅដល់ទីតាំងថ្មី។ ពេលនោះសមាជិកនៅក្នុងកងដែលទៅដល់មុនខ្ញុំបានចេញទៅធ្វើការអស់ហើយ ចំណែកខ្ញុំជាប់កូនខ្ចីដើរទៅដល់ក្រោយគេ។ នៅពេលយប់នោះខ្មែរក្រហមបានទទួលដំណឹងថា កងទ័ពវៀតណាមវាយចូលមកជិតដល់ហើយ ទើបខ្មែរក្រហមរំសាយប្រជាជននៅក្នុងកងឲ្យទៅរកបងប្អូននិងក្រុមគ្រួសារវិញ។ ខ្ញុំដើររយៈពេល១៥ថ្ងៃ ទើបមកដល់ខណ្ឌក្តុ ខេត្តកំពង់ស្ពឺ។ ខ្ញុំឈប់សម្រាក់ដាំបាយហូប និងដេកនៅតាមផ្លូវអស់ជាច្រើនថ្ងៃ។ នៅពេលមកដល់ស្រុកកំណើតនៅក្នុងភូមិពោធិតារស់ ឃុំបាសាក់ ខ្ញុំនិងបងប្អូន៤នាក់នាំគ្នាកាប់រានដីដាំស្រូវ។ ក្រោយមករដ្ឋអំណាចបានចងក្រងជាក្រុមប្រវាស់ដៃ និងមានគោក្របីសម្រាប់ព្យួររាស់។ ខ្ញុំរស់នៅជាមួយកូនស្រី ប៉ុន្តែក្រោយមកកូនស្រី របស់ខ្ញុំចាកចេញទៅរស់នៅស្រុកផ្សេងជាមួយប្តី ដូច្នេះខ្ញុំរស់នៅម្នាក់ឯងរហូតមកដល់សព្វថ្ងៃ។





# សៀវភៅ «នរោត្តម សីហនុ និង ជូ អេនឡាយ៖ មិត្តភាពដ៏កម្រនៅក្នុងអំឡុងនៃការរីកសាយភាយរបស់សង្គ្រាមត្រជាក់»

*ហូលីយ៉ូ អេ. ហែលឌ្រេស*




*សៀវភៅ «នរោត្តម សីហនុ និង ជូ អេនឡាយ៖ មិត្តភាពដ៏កម្រនៅក្នុងអំឡុងនៃការរីកសាយភាយរបស់សង្គ្រាមត្រជាក់» (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

បណ្ណាល័យសម្តេចម៉ែមានសេចក្តីសោមនស្ស ផ្ញើសេចក្តីប្រកាសអំពីការចេញផ្សាយសៀវភៅ «នរោត្តម សីហនុ និង ជូ អេនឡាយ៖ មិត្តភាពដ៏កម្រនៅក្នុងអំឡុងនៃការរីកសាយភាយរបស់សង្គ្រាមត្រជាក់» ដែលជាស្នាដៃនិពន្ធរបស់ឯកអគ្គរាជទូត បណ្ឌិត ហូលីយ៉ូ អេ. ហែលឌ្រេស អតីតលេខាផ្ទាល់ និងជាអ្នកសរសេរជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មានប្រសាសន៍ថា សៀវភៅនេះ ពិពណ៌នាអំពីទំនាក់ទំនងដែលគ្មានពីរ រវាងប្រមុខរដ្ឋពីររូបដែលមានសាវតារផ្ទុយគ្នាស្រឡះ ដែលមួយរូប គឺជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងមួយរូបទៀតគឺ ជាអ្នកដឹកនាំបក្សកុម្មុយនីស្តរបស់សាធារណរដ្ឋប្រជាមានិតចិន។ បុគ្គលទាំងពីរបានព្យាយាមរក្សាទំនាក់ទំនងដ៏យូរអង្វែងមួយ ដែលបន្តផ្តល់ជាសារៈប្រយោជន៍ដល់ប្រទេសទាំងពីររហូតមកទល់ពេលបច្ចុប្បន្ន។

បណ្ឌិត ហែលក្រេស បានចាប់អារម្មណ៍ទៅលើមិត្តភាពដ៏កម្ររវាងសែស្រឡាយរាជវង្សនៃព្រះរាជាណាចក្របុរាណមួយ និងនាយករដ្ឋមន្ត្រីនៃរដ្ឋប្រកាន់យករបបកុម្មុយនីស្តដ៏លេចធ្លោមួយក្នុងទ្វីបអាស៊ីក្នុងឆ្នាំ១៩៧០ នៅពេលដែលលោកនៅជាសិស្សវិទ្យាល័យម្នាក់នៅក្នុងមាតុប្រទេសរបស់លោក គឺ ប្រទេសស៊ីលីក្នុងទ្វីបអាមេរិកខាងត្បូង។

បណ្ឌិត ហែលក្រេស រំឭកថា នៅខែមីនា ឆ្នាំ១៩៧០ បន្ទាប់ពីសម្តេច សីហនុ ត្រូវបានទម្លាក់ចេញពីដំណែងដោយរដ្ឋប្រហាររបស់សេនាប្រមុខ លន់ នល់ លោកមានការឈឺចាប់ប្រកបដោយក្តីអាណិតអាសូរចំពោះព្រះរាជកិច្ចខិតខំប្រឹងប្រែងរបស់សម្តេចសីហនុក្នុងការការពារបូរណភាពទឹកដី និងឯករាជ្យភាពរបស់ប្រទេសកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៦៧មក បណ្ឌិត ហែលក្រេស កាន់មុខដំណែងជាអ្នកឆ្លើយឆ្លងផ្ទាល់របស់សម្តេច សីហនុនិងតែងចង់ដឹងអំពីព្រះរាជសុខទុក្ខ និងព្រះរាជហឫទ័យរបស់ទ្រង់ បន្ទាប់ពីព្រឹត្តិការណ៍ដ៏ខ្លោចផ្សារនេះ កើតមាននៅក្នុងទីក្រុងភ្នំពេញ។

«នេះបានញុំាងឲ្យរូបខ្ញុំចាប់អារម្មណ៍ជាពន់ពេកចំពោះព្រះរាជដំណើរជីវិតនយោបាយរបស់ សម្តេចសីហនុះ សម្ព័ន្ធភាពរបស់ទ្រង់ជាមួយនឹងនាយករដ្ឋមន្ត្រីចិន ជូ អេន ឡាយ។ ទំនាក់ទំនងនេះ ហាក់ដូចជាទំនាក់ទំនងមួយដ៏វិសេសវិសាល រវាងព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រមួយដែលប្រណិប័តន៍ព្រះពុទ្ធសាសនា និងនាយករដ្ឋមន្ត្រីនៃរដ្ឋកុម្មុយនីស្តមួយ។ ក្នុងនាមជាអ្នកស្រាវជ្រាវក្មេងវ័យលើ ផ្នែកទំនាក់ទំនងអន្តរជាតិ ខ្ញុំបានដឹងតិចតួចណាស់អំពីការដែលទំនាក់ទំនងរវាងរដ្ឋពីរប្រព្រឹត្តទៅ ហើយទំនាក់ទំនងខាងលើហាក់ដូចជាចម្លែកសម្រាប់រូបខ្ញុំ ពោលគឺអ្នកដឹកនាំម្នាក់ដែលអះអាងថាជាទាយាទរបស់ព្រះមហាក្សត្រនៃរាជវង្សអង្គរ បានកសាងទំនាក់ទំនងដែលគ្មានពីរជាមួយនឹងអ្នកដឹកនាំនយោបាយនៃប្រទេសដែលប្រកាន់នូវមនោគមន៍វិជ្ជាប្រឆាំងនឹងការគ្រប់គ្រងរបស់រាជវង្ស។»

បណ្ឌិត ហែលក្រេស បានស្រាវជ្រាវរកឃើញថា សាខានៃភ្នាក់ងារសារព័ត៌មានចិន ស៊ីនហួរ ក្នុងទីក្រុងសាន់ត្យាហ្គោ ប្រទេសស៊ីលី បានរក្សាទុកនូវឯកសារទាំងអស់ជាភាសាអេស្ប៉ាញ ស្តីអំពីព្រះរាជសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ ដែលទ្រង់ធ្វើឡើងនៅរដ្ឋធានីរបស់ប្រទេសចិននៅមុនព្រឹត្តិការណ៍នោះមួយថ្ងៃ។ មើលទៅដូចជាមិនទំនងសោះ ដែលរបបកុម្មុយនីស្តមួយ ផ្តល់នូវការគោរពរាក់ទាក់ចំពោះអតីតសមាជិករាជវង្សយ៉ាងដូច្នេះ ជាពិសេសក្នុងអំឡុងបដិវត្តន៍វប្បធម៌ចិនទៀតនោះ។ តាមពិតទៅអ្វីៗកើតឡើងបែបនេះមែនៗ មិត្តភាពបានយកឈ្នះលើមនោគមន៍វិជ្ជា។

ការស្រាវជ្រាវដើម្បី សរសេរជាសៀវភៅនេះឡើង បានចាប់ផ្តើមតាំងពីឆ្នាំ១៩៧០ និងបានបញ្ចប់ទៅនៅអំឡុងឆ្នាំ២០១៥។ បន្ទាប់ពីសំណេរបានបញ្ចប់ទៅ គឺមានការកែសម្រួល និងកែតម្រូវបន្ថែមទៀតនៅរវាងឆ្នាំ២០១៥និងឆ្នាំ២០២០។

សៀវភៅនេះមានកម្រាស់ ២២០ទំព័រ និងត្រូវបោះពុម្ពឡើងដោយគម្រោងស្រាវជ្រាវភាសាចិនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានហិរញ្ញប្បទានពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ។

# ម៉ម ស្រឿន អតីតកងដឹកជញ្ជូនអ្នកទោស យកទៅសម្លាប់នៅមន្ទីរសន្តិសុខគគរ

*កែម សុភី និង មេន នឿន*




ម៉ម ស្រឿន អតីតកងដឹកជញ្ជូនអ្នកទោសយកទៅសម្លាប់នៅមន្ទីរសន្តិសុខគគរ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទស្សនាការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តកំពង់ចាម នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃអង្គារ៍ ទី១៧ ខែសីហា ឆ្នាំ២០២១ មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ចាម បានរៀបចំវេទិកាស្រាវជ្រាវអំពីដំណើរជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈប្រព័ន្ធវីដេអូ ដោយមានការអញ្ជើញចូលរួមពី លោកតា ម៉ម ស្រឿន អតីតកងដឹកជញ្ជូនអ្នកទោសយកទៅសម្លាប់នៅមន្ទីរសន្តិសុខគគរ ស្ថិតនៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម និងនិស្សិតស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គោលបំណងនៃវេទិកាស្រាវជ្រាវនេះ គឺដើម្បីអនុញ្ញាតឲ្យនិស្សិតស្រាវជ្រាវរីយក្មេងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតក្នុងរបបខ្មែរក្រហម និងដើម្បីជាការចែករំលែកនូវបទពិសោធន៍ និងការចង់ចាំរបស់គាត់ក្នុងការស្វែងយល់បន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

លោកតា ម៉ម ស្រឿន បានរំលេចអំពីសាវតាររបស់ខ្លួនទៅកាន់និស្សិតស្រាវជ្រាវថា ខ្ញុំឈ្មោះម៉ម ស្រឿន កើតនៅក្នុងឆ្នាំ១៩៤៧ នៅក្នុងភូមិមហាខ្ញូង ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្រពន្ធឈ្មោះ គួង ហ៊ិន និងបច្ចុប្បន្នគឺជាកសិកររស់នៅក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកម្តាយឈ្មោះ ម៉ម ទុំ និងម្តាយឈ្មោះ បាន ណែម។ ខ្ញុំគឺជាកូនទី៦ ក្នុងចំណោមបងប្អូនប្រុសស្រី ចំនួន៧នាក់។ ខ្ញុំរៀនថ្នាក់

ទី៧ សង្កមចាស់ នៅសាលាបឋមសិក្សាវត្តមហាខ្វូង ប៉ុន្តែខ្ញុំឈប់រៀនដើម្បីជួយធ្វើស្រែចំការឪពុកម្តាយវិញ។ នៅពេលនោះ ខ្ញុំមានអាយុ១៣ឆ្នាំ។ ខ្ញុំធ្វើស្រែចម្ការរហូតដល់ឆ្នាំចុងឆ្នាំ១៩៦៩។ បន្ទាប់ពីមានរដ្ឋប្រហាររបស់ លន់ នល់ នៅដើមឆ្នាំ១៩៧០ ខ្ញុំឃើញប្រជាជនធ្វើបាតុកម្មនៅក្នុងភូមិរបស់ខ្ញុំ។ នៅពេលនោះ ខ្ញុំមិនបានចូលរួមបាតុកម្មទេ។

លោកតា ស្រឿន រៀបរាប់បន្តថា នៅឆ្នាំ១៩៧១ ខ្ញុំស្ម័គ្រចិត្តចូលធ្វើជាកងចល័ត។ នៅឆ្នាំ១៩៧៣ ខ្ញុំរៀបការប្រពន្ធ និងមានកូនស្រីម្នាក់។ នៅឆ្នាំ១៩៧៤ ដល់១៩៧៥ ខ្ញុំ និងគ្រួសារ បានផ្លាស់ទៅរស់នៅភូមិចំការសាមសិប និងធ្វើជាកងចល័តដដែល។ ក្រោយមកទៀត ខ្ញុំត្រូវបានបញ្ជូនទៅធ្វើស្រែរហូតដល់ឆ្នាំ១៩៧៥។ ចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានផ្លាស់ទៅលើកទំនប់តាសេក អស់រយៈពេលប្រហែល ២ខែ ទើបត្រឡប់មកផ្ទះវិញ។ ៥ថ្ងៃក្រោយមក ខ្ញុំត្រូវបានដកឲ្យទៅធ្វើការនៅកងដឹកជញ្ជូនវិញ។ មិត្ត សៀ គឺជាប្រធានកងដឹកជញ្ជូននៅចន្លោះឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ បញ្ជាខ្ញុំឲ្យទៅដឹកជនជាតិចាមតាមរទេះគោ ដើម្បីយកមកសម្លាប់នៅមន្ទីរសន្តិសុខគគរ។ មិត្ត សៀ រៀបចំរទេះគោចំនួន១៥គ្រឿង ដើម្បីដឹកជញ្ជូនប្រជាជន និងប្រាប់ប្រជាជនថា អង្គការជម្លៀសគាត់ពីភូមិឲ្យទៅរស់នៅមូលដ្ឋានថ្មី ប៉ុន្តែនៅពេលដែលមកដល់ផ្លូវក្បាលទំនប់គគរ កងឈ្លបខ្មែរក្រហមប្រាប់ទិសឲ្យបររទេះចូលទៅក្នុងវត្តគគរដើម្បីសម្លាប់ប្រជាជនទាំងនោះទៅវិញ។ បន្ទាប់ពីដឹកប្រជាជនទៅដល់ទីតាំង ខ្ញុំត្រូវបានកងឈ្លបបញ្ជាឲ្យទៅជីករណ្តៅ។ ខណៈពេលដែលខ្ញុំកំពុងជីកដី កងឈ្លបចាប់ផ្តើមសម្លាប់អ្នកទោសជាបន្តបន្ទាប់ ដោយយកពូថៅវាយក្បាលប្រជាជន និងយកដាវចាក់ទម្លុះបំពង់ក រួចហើយតម្រៀបនៅក្នុងរណ្តៅ។

ខ្ញុំឃើញការសម្លាប់នេះដោយផ្ទាល់ ដោយមានកងឈ្លបប្រមាណ ៣ទៅ៤នាក់សម្លាប់ប្រជាជនទម្លាក់ទៅក្នុងមួយរណ្តៅ។ នៅពេលខ្ញុំជីករណ្តៅរួច និងស្នើសុំបររទេះគោចេញទៅវិញ គឺមានកងឈ្លបម្នាក់ជាអ្នកជូនខ្ញុំ។ ប្រសិនបើខ្ញុំដើរមកម្នាក់ឯង ខ្ញុំនឹងត្រូវបានយល់ច្រឡំថា ជាអ្នកទោសនិងត្រូវយកទៅសម្លាប់ដែរ។ នៅពេលដែលមកដល់ផ្ទះវិញ ខ្ញុំពិតជាភ័យតក់ស្លុតខ្លាំងណាស់ ហើយខ្ញុំបានប្រាប់ប្រពន្ធអំពីហេតុការណ៍សម្លាប់នោះ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំត្រូវបានដកឲ្យទៅធ្វើការនៅរោងជាងដើម្បីសាងសង់រោងបាយរួមសម្រាប់សហករណ៍។ នៅពេលនោះ វត្តគគរ ត្រូវបានរៀបចំជួសជុលឡើងវិញ និងប្រើប្រាស់ជាឃ្លាំងស្តុកស្រូវអង្ករ។ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ ខ្ញុំរួមជាមួយក្រុមគ្រួសារបន្តរស់នៅក្នុងភូមិ និងប្រកបរបរធ្វើស្រែរហូតមកដល់សព្វថ្ងៃ។

បន្ទាប់ពីលោកតា ស្រឿន រៀបរាប់អំពីដំណើរជីវិតប្រាប់ដល់និស្សិតស្រាវជ្រាវវ័យក្មេងរួច និស្សិតមួយចំនួនបានសួរសំណួរទាក់ទងនឹងការកាប់សម្លាប់នៅមន្ទីរសន្តិសុខគគរ។ ជាចុងក្រោយ លោកតា ស្រឿន ផ្តាំផ្ញើទៅកាន់និស្សិតស្រាវជ្រាវអំពីសារសំខាន់ក្នុងការយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន និងត្រូវខិតខំសិក្សារៀនសូត្របន្ថែមទៀត។



ម៉ម ស្រឿន អតីតកងដឹកជញ្ជូនអ្នកទោសយកទៅសម្លាប់នៅមន្ទីរសន្តិសុខគគរ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និយាយទៅកាន់និស្សិតស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមរយៈប្រព័ន្ធវីដេអូ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំធ្វើដំណើរជាមួយសាកសពទាហាន លន់ នល់

**ស្លួត វិចិត្រ**

មៀច គីម ហ័ន ភេទស្រី អាយុ៦៦ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងឃុំអំពិលលើ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បច្ចុប្បន្នរស់នៅក្នុងភូមិស្រឡៅស្រោង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ គីម ហ័ន បានរៀបរាប់ពីដំណើរជីវិតរបស់ខ្លួនដែលធ្លាប់ឆ្លងកាត់នៅក្នុងជំនាន់ខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំមានអាយុ១៦ឆ្នាំ នៅត្រឹមឆ្នាំ១៩៧០។ នៅពេលនោះខ្ញុំបានរៀបការជាមួយ ម៉ា ជូ ដែលជាទាហាន លន់ នល់។ រយៈពេលកន្លះខែក្រោយមក ខ្ញុំនិងប្តី បានឃ្លាតឆ្ងាយពីគ្នា ដោយសារតែគាត់ជាប់កាតព្វកិច្ចជាកងទ័ពនៅឯសមរភូមិ។ ក្រោយមក ខ្ញុំបានចូលបម្រើការងារនៅក្នុងរោងចក្រកាត់ដេរ និងតម្បាញ ដែលមានចម្ងាយប្រមាណ៦គី ឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម។



មៀច គីម ហ័ន អាយុ៦៦ឆ្នាំ រស់នៅក្នុងភូមិស្រឡៅស្រោង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ស្លួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងខែមីនា ឆ្នាំ១៩៧០ រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ កើតមានឡើង ដែលជាហេតុបណ្តាលឲ្យកម្មករនៅក្នុងរោងចក្រមានការភ្ញាក់ផ្អើល និងនាំគ្នាចេញមកក្រៅយ៉ាងកកកុញដើម្បីមើលការវែហបាតុកម្ម។ នៅពេលនោះ ខ្ញុំបានឃើញបាតុករជាច្រើនបាននិងកំពុងនាំគ្នាស្រែកតវ៉ាដើម្បីទាមទារអំណាចឲ្យសម្តេចព្រះ នរោត្តម សីហនុ ។ បាតុករទាំងនោះកាន់កាំបិត ពូថៅ និងដំបង ហើយបានវាយប្រហារទៅលើកងកម្លាំងរក្សាសន្តិសុខ លន់ នល់ ទៀតផង។ សកម្មភាពទាំងអស់នេះ បានប្រែក្លាយទៅជាការប្រើប្រាស់អំពើហិង្សា និងការបាញ់តបតមិនញញើតដៃពីសំណាក់កងកម្លាំងប្រដាប់អាវុធ លន់ នល់។

ខ្ញុំមានការរន្ធត់ចិត្តណាស់ និងបានអង្គុយយំនៅក្បែររបងរោងចក្រក្នុងចំណោមមនុស្សជាច្រើន។ ខ្ញុំឃើញឪពុករបស់ខ្ញុំរត់សំដៅមករកខ្ញុំនៅក្នុងរោងចក្រដើម្បីយកខ្ញុំត្រឡប់ទៅផ្ទះវិញ។ បាតុកម្មនេះបានបណ្តាលឲ្យមនុស្សជាច្រើនស្លាប់បាត់បង់ជីវិត ហើយប្រជាជនមួយចំនួនបានចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ដើម្បីទៅសម្ងំរស់នៅក្នុងព្រៃ។ ប្រជាជននៅក្នុងឃុំអំពិលលើព្រម ទាំងគ្រួសាររបស់ខ្ញុំបាននាំគ្នាធ្វើដំណើរដោយថ្មើរជើងទៅកាន់ឃុំរលួស រកកន្លែងសុវត្ថិភាព។ ចៃដន្យយើងជួបកងទ័ពវៀតកុងនៅពាក់កណ្តាលផ្លូវ ហើយកងទ័ពវៀតកុងទាំងនោះ បានឲ្យយើងចូលបម្រើក្នុងចលនារបស់ខ្លួន។ យើងត្រូវបានចាត់តាំងឲ្យធ្វើជាកងកម្លាំងស្នូលដើម្បីបំផ្លិចបំផ្លាញផ្លូវថ្នល់ និងស្ពាន ដើម្បីកាត់ផ្តាច់ការធ្វើដំណើររបស់ទាហាន លន់ នល់។

បន្ទាប់ពីបម្រើដល់ចលនាវៀតកុងបានមួយរយៈ យើងក៏មានឱកាសធ្វើដំណើរទៅកាន់ឃុំរលួស នៃស្រុកចំការលើ បន្ទាប់ពីកងទ័ពវៀតកុងត្រូវបានវាយ

វុញប្រានដោយទាហាន លន់ នល់ ត្រឡប់ទៅវិញ។ ឃុំរលួសជាទីតាំងដែលមានការប្រមូលផ្តុំដោយកងទ័ពខ្មែរក្រហម និងវៀតកុង។

សកម្មភាពឆក់ប្លន់នៅក្នុងភូមិកើតមានឡើងជាបន្តបន្ទាប់ និងបន្តក្តីព្រួយបារម្ភដល់កូនចៅរបស់អ្នកភូមិនៅពេលកងទ័ពវៀតកុងបានចូលមកភូមិកាន់តែច្រើន។ នារីៗនៅក្នុងភូមិរស់នៅដោយលួចលាក់ពីក្រសែភ្នែករបស់កងទ័ពទាំងនោះ និងត្រូវធ្វើសកម្មភាពគ្រប់បែបយ៉ាងដើម្បីបំផ្លាញសម្រស់របស់ខ្លួន។ នារីភាគច្រើនបានប្រើប្រាស់មធ្យោបាយដោយការលាបធ្យូងកោរសក់ និងត្រូវសម្ងំលាក់ខ្លួននៅក្នុងផ្ទះ។

លុះដល់ឆ្នាំ១៩៧២ យើងបានធ្វើដំណើរត្រឡប់ទៅកាន់ឃុំអំពិលលើវិញ បន្ទាប់ពីមានការរំដោះដោយទាហាន លន់ នល់។ យើងបានធ្វើដំណើរប្រហែល៥០គីឡូម៉ែត្រដើម្បីទៅដល់ភូមិកំណើតរបស់ខ្លួនដែលមានសភាពខ្ទេចខ្ទាំ។ នៅទីនោះ ខ្ញុំជួបជុំជាមួយសាច់ញាតិ និងប្តីរបស់ខ្ញុំ ហើយក្រោយមកខ្ញុំសម្រេចចិត្តធ្វើដំណើរទៅកាន់អង្គភាពតាំងគោក បន្ទាប់ពីមានការវាយបែកដោយប្រតិបត្តិការចេនឡាទី១ និងចេនឡាទី២។ អង្គភាពតាំងគោក ជាអង្គភាពទ័ពរបស់ លន់ នល់ ហើយនៅទីនោះខ្ញុំធ្វើការនៅក្នុងអង្គភាពពេទ្យដែលមានអ្នករបួសជាច្រើនមកពីសមរភូមិ។ ខ្ញុំមើលថែអ្នករបួសហើយជួនកាលបានរុំសាកសព នៅពេលដែលអ្នករបួសស្លាប់បាត់បង់ជីវិត។ អ្នករបួសម្នាក់បានស្រែកហៅខ្ញុំ ហើយប្រាប់ឲ្យជួយយកទឹកឲ្យគាត់ផឹក ប៉ុន្តែត្រូវបានក្រុមគ្រូពេទ្យព្យួរសេរ៉ូមឲ្យគាត់វិញដើម្បីជួយសង្គ្រោះគាត់បានភ្លាមៗ។ ទិដ្ឋភាពទាំងអស់នេះ បានបន្តឲ្យខ្ញុំមានការភ័យខ្លាចកាន់តែខ្លាំងឡើង ដោយសារពុំមានបទពិសោធន៍លើការងារទាំងអស់នេះ។ ក្រោយមក តំបន់តាំងគោក ត្រូវបានវាយរំដោះដោយកងទ័ពខ្មែរក្រហម ដោយសារតែប្រជាជននៅតំបន់នេះមានភក្តីភាពជាមួយខ្មែរក្រហម និងផ្តាច់ខ្លួនចេញពីការគ្រប់គ្រងរបស់ លន់ នល់។

ភ្លាមៗបន្ទាប់ពីទទួលបរាជ័យ អង្គភាពរបស់ខ្ញុំបានបញ្ជូនខ្ញុំទៅកាន់រដ្ឋធានីភ្នំពេញតាមរយៈឧទ្ធម្ភាគចក្រដឹកសាកសពទាហាន លន់ នល់ អំឡុងពេលការវាយប្រហារ។ នៅពេលនោះ ខ្ញុំបានធ្វើដំណើរជាមួយនឹងសាកសពប្រហែល២០ទៅ៣០ ដែលមានសភាពខ្ទេចខ្ទីដោយសារការផ្ទុះគ្រាប់នៅសមរភូមិ។ ខ្ញុំមានអារម្មណ៍ព្រឺព្រួចខ្លាំងណាស់ ដោយបានអើតក្បាលទៅកាន់អ្នកបើកបរនៅខាងមុខ ខណៈពេលដែលខ្ញុំកំពុងអង្គុយពីលើសាកសពដែលចាប់ផ្តើមរឹង។ បន្ទាប់ពីភាពព្រឺព្រួចនេះបានកន្លងផុតទៅ ខ្ញុំទៅដល់រដ្ឋធានីភ្នំពេញ។ ក្រោយមក ខ្ញុំធ្វើដំណើរទៅកាន់ចម្ការដូងដើម្បីជួបជាមួយឪពុកម្តាយក្មេករបស់ខ្ញុំ។

លុះដល់ឆ្នាំ១៩៧៣ ខ្ញុំសម្រាលបានកូនស្រីម្នាក់។ ខ្ញុំសម្រេចចិត្តធ្វើដំណើរទៅកាន់បរប៉ៃលិនបីនាក់ម្តាយក្មេករួមជាមួយកូនអាយុ៦ខែ។ បរប៉ៃលិន គឺជាទីតាំងដែលមានសុខសុវត្ថិភាពកាលជំនាន់នោះ ដោយសារតែតំបន់នេះមានការគ្រប់គ្រងដោយនាយទុន ឈ្មួញជនជាតិបារាំង និងជាតំបន់ដែលមិនទាន់មានភាពចលាចល។ ក្រោយមកប្តីរបស់ខ្ញុំបានទៅដល់ទីនោះដែរ បន្ទាប់ពីគាត់រត់ចេញអង្គភាពដែលកំពុងប្រយុទ្ធលើសមរភូមិ។ ប្តីរបស់ខ្ញុំបានរស់នៅដោយលួចលាក់ គេចពីការតាមចាប់របស់គិញសម្ងាត់នៅក្នុងអង្គភាពរបស់ខ្លួន។ ប៉ុន្តែដោយសារការធ្វេសប្រហែសរបស់គាត់នៅថ្ងៃមួយគិញសម្ងាត់របស់ លន់ នល់ បានចាប់ខ្លួនគាត់រួចបញ្ជូនទៅគុកធំនៃខេត្តបរប៉ៃលិន។ រយៈពេលពីរថ្ងៃក្រោយមក ខ្ញុំទទួលបានដំណឹងពីគាត់ ហើយបានយកមាសមួយតម្លឹងឲ្យឆ្មាំគុកជាថ្នូរជាមួយការដោះលែងគាត់។

លុះដល់ខែចេត្រ ឆ្នាំ១៩៧៣ សភាពការណ៍នៃការទម្លាក់គ្រាប់បែករបស់ទាហាន លន់ នល់ បានកើតឡើងកាន់តែខ្លាំងក្លា ដែលបណ្តាលឲ្យប្រជាជននៅបរប៉ៃលិនធ្វើដំណើរទៅកាន់តំបន់ព្រំដែននៃជួរភ្នំដងរែកជាមួយខ្មែរក្រហម។ កងទ័ព លន់ នល់ បានប្រកាសតាមឧទ្ធម្ភាគចក្រថា សូមបងប្អូនកុំធ្វើដំណើរទៅកាន់ព្រំដែនឲ្យសោះពីព្រោះវាជាគោលនយោបាយរបស់ខ្មែរក្រហមទេ ព្រោះពេលនោះកងទ័ពខ្មែរក្រហមដែលត្រៀមខ្លួនជាអ្នកនាំផ្លូវប្រជាជនទៅកាន់ព្រំដែន។

នៅឆ្នាំ១៩៧៥ ខ្ញុំទទួលដំណឹងថា ខ្មែរក្រហមទទួលជ័យជម្នះនៅក្នុងទីក្រុងភ្នំពេញ ហើយនៅពេលនោះខ្ញុំឃើញកងទ័ពជាច្រើនស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ។ ពីរថ្ងៃក្រោយមក ខ្មែរក្រហមបានបណ្តេញ

យើងចេញពីទីប្រជុំជនប៉ៃលិនទៅកាន់ទីជនបទដាច់ស្រយាល។ យើងធ្វើដំណើរទៅដល់ភ្នំដើងទីង ខេត្តបាត់ដំបង។ នៅទីនោះ ខ្មែរក្រហមបានឲ្យយើងសម្រាកបណ្ដោះអាសន្ន និងរង់ចាំនូវការចាត់ចែងពីថ្នាក់លើ។ ក្រោយមក ខ្មែរក្រហមឲ្យខ្ញុំទៅរស់នៅត្រង់មុំបឹងវៀងជិតដងស្ទឹងអូរឈើទាលដើម្បីធ្វើស្រែចម្ការ។ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមយកមនុស្សទៅសម្លាប់ចោល។ នារីម្នាក់ដែលជាកូនចៅរបស់ក្រុមគ្រួសារដ៏ស្ដុកស្ដម្ភម្នាក់ត្រូវបានខ្មែរក្រហមបាញ់សម្លាប់ បន្ទាប់ពីគាត់បានលួចហូបម្ហូបអាហាររបស់សហករណ៍ គាត់ត្រូវបានខ្មែរក្រហមតាមទាន់ចំនួនពីរដង ហើយបណ្ដើរគាត់មុខខ្ញុំយកទៅសម្លាប់នៅប្រប់មាត់ព្រៃចម្ងាយតែប៉ុន្មានម៉ែត្រប៉ុណ្ណោះពីកន្លែងខ្ញុំ។

រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមចាត់ខ្ញុំចូលក្នុងអង្គភាពចិញ្ចឹមជ្រូក ដែលមានជ្រូកសរុបចំនួនប្រមាណជាង៤០ក្បាល។ នៅទីនោះ ខ្ញុំជួបប្រទះនូវការអត់ឃ្លានយ៉ាងខ្លាំង។ ជាញឹកញយខ្ញុំលួចដីរបុង និងបាយជ្រូកយកមកហូបចម្អែតក្រពះ។ ការរស់នៅក្រោមការអត់ឃ្លានបន្តរហូតដល់យើងត្រូវបានជម្លៀសទៅភ្នំក្រពើ ខេត្តបាត់ដំបង នៅពេលរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។

ភ្នំក្រពើគឺជាសមរភូមិក្ដៅរបស់ខ្មែរក្រហមដែលមានការបាញ់ប្រោះ និងជម្លៀសប្រជាជនពីទីតាំងមួយទៅទីតាំងមួយទៀត។ យើងរស់នៅទីនោះដោយមានការប្រទាញប្រទង់គ្នារវាងកងកម្លាំងខ្មែរក្រហម និងកងទ័ពវៀតណាម ហើយបណ្ដាលឲ្យមានការបាត់បង់ជីវិតមនុស្សយ៉ាងច្រើន។ ខ្ញុំឃើញកងកម្លាំងខ្មែរក្រហមនិងកងទ័ពវៀតណាម ស្លាប់ពាសពេញដីនៅពេលដែលយើងចល័តចេញពីតំបន់មួយទៅតំបន់មួយទៀត។

នៅថ្ងៃមួយប្រហែលម៉ោងប្រាំពីរកន្លះ ខ្ញុំឃើញមានទង់ជ័យ ដែលបង្ហាញថាជាជ័យជម្នះរបស់កងស្ម័គ្រចិត្តវៀតណាមបានកាន់កាប់ស្ទើរពាសពេញភ្នំក្រពើ។ ភ្លាមៗនោះ កងទ័ពវៀតណាមបានមកដល់និងរំដោះយើង។ ក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនដទៃទៀតវិលត្រឡប់មកកាន់ភូមិកំណើតវិញ និងចាប់ផ្ដើមកសាងជីវិតឡើងវិញ។



ផ្ទះរបស់ មៀច គឹមហ័ន នៅភូមិស្រឡៅស្រោង ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)




# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្ដីខ្មែរក្រហម។







មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្ទឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្ដៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។







តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។







ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្ដា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!






# សិល្បៈភូមិត្រពាំងត្រស់

***ហ៊ាន ពិសី***



ហម សឿម អាយុ៦៧ រស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ហម សឿម ភេទស្រី អាយុ៦៧ មានទីកន្លែងកំណើតនៅភូមិត្រពាំងត្រស់ ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប។ សឿម ចូលរួមចែករំលែកពីបទពិសោធជីវិត ដូចខាងក្រោម៖

នៅសម័យសង្គមរាស្ត្រនិយម គឺជាសម័យមួយដែលពោរពេញទៅដោយភាពសប្បាយរីករាយបំផុតសម្រាប់ខ្ញុំ។ យើងតែងចំណាំថា សម្តេចព្រះ នរោត្តម សីហនុ ទ្រង់តែងតែប្រទាននូវព្រះរាជអំណោយដល់ប្រជាជនតាមរយៈការទម្លាក់ពីយន្តហោះ។ ជាពិសេសក្មេងៗជំទង់ៗ មើលទៅត្រេកអរណាស់នៅពេលទទួលបានអំណោយនោះម្តងៗ ដែលមានដូចជា សំពត់ក្រមា និងរបស់របរផ្សេងៗទៀត។ សម្តេចព្រះ នរោត្តម សីហនុ ទ្រង់តែងតែសណ្តោសប្រណីចំពោះប្រជាជនណាស់ ទ្រង់មិនដែលគៀបសង្កត់ប្រជាជន ហើយប្រជាជនអាចប្រកបរបរលក់ដូរទៅតាមសមត្ថភាពរៀងៗខ្លួន ឲ្យតែការងារនោះជាការងារដែលសុចរិត។

ប៉ុន្តែមកដល់ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារប្រឆាំង ទម្លាក់ព្រះអង្គចេញពីតំណែង។ ជីវិតប្រជាជនម្នាក់ៗមានការប្រែប្រួលទៅតាមនោះដែរ។ ខ្ញុំនៅចងចាំថា មានការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកនៅក្នុងភូមិរបស់ខ្ញុំ ដែលធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ ប្រជាជនអស់ជាច្រើន ប៉ុន្តែមិនមានការបាត់បង់ជីវិតមនុស្សទេ។ ស្ថានការណ៍នៅពេលនោះគឺពិបាកណាស់សម្រាប់យើង យើងមិនហ៊ានចេញទៅក្រៅដើម្បីប្រកបរបររកស៊ីនោះ ក្រៅពីត្រូវលាក់ខ្លួន

នៅក្នុងលេណដ្ឋានរៀងៗខ្លួន និងរង់ចាំសភាពការណ៍ស្ងប់ស្ងាត់ឡើងវិញ។

លុះឆ្នាំ១៩៧៣ យើងឃើញមានខ្មែរក្រហមចូលមកពាសពេញភូមិ។ ខ្មែរក្រហមចាប់ផ្ដើមបង្កើតឲ្យមានជាក្រុមយុវជនយុវនារី ស្ម័គ្រចិត្តនៅតាមភូមិដែលមានកងឈ្លប, ក្រុមសិល្បៈភូមិ និងក្រុមស្ម័គ្រចិត្តផ្សេងៗជាច្រើនទៀត។ នៅពេលនោះខ្ញុំបានស្ម័គ្រចិត្តចូលហ្វឹកហាត់រាំសម្ដែងសិល្បៈដែរ។ ការហ្វឹកហាត់ត្រូវបានធ្វើឡើងរៀងរាល់ល្ងាចម៉ោង ៥ ។ យើងតែងតែហាត់ជាក្រុមនៅតាមភូមិនីមួយៗ។ ក្រុមសិល្បៈនីមួយៗដាក់ឈ្មោះទៅតាមភូមិដែលយើងរស់នៅដោយមានឈ្មោះថា «ក្រុមសិល្បៈភូមិត្រពាំងត្រស់» ។ ក្រុមសិល្បៈភូមិខ្ញុំភាគច្រើនចេញសម្ដែងនៅតាមកម្មពិធី ដូចជា ការប្រជុំកម្មពិធីបុណ្យទានផ្សេងៗដោយយើងធ្វើការសម្ដែងនៅលើដីផ្ទាល់មិនមានឆាកដូចខាងក្រុមសិល្បៈស្រុកនោះទេ។ ចំពោះសម្លៀកបំពាក់សម្រាប់សម្ដែងយើងពុំមានអ្វីច្រើនទេ ដោយគ្រាន់តែស្លៀកពាក់ធម្មតាទៅតាមអ្វីដែលយើងប្រើប្រាស់រាល់ថ្ងៃ។ ចំណែកសម្ភារសម្រាប់សម្ដែងវិញ យើងប្រើទៅតាមអ្វីដែលយើងមានរៀងៗខ្លួន អ្នកខ្លះមាន ចប បង្គី អ្នកខ្លះយកផ្កាមកក្រងធ្វើជាកម្រងផ្កា។ សម័យនោះ សាច់រឿងដែលយើងសម្ដែងភាគច្រើនចង់ពន្យល់អំពីការធ្វើបដិវត្តន៍របស់ខ្មែរក្រហម និងកងកម្លាំងសាធារណរដ្ឋខ្មែរ, ពន្យល់អំពីជីវិតប្រជាជនដែលត្រូវខ្លាំងធ្វើបាប ឬពន្យល់អំពីផលវិជ្ជមានដែលប្រជាជនរស់នៅជាសហករណ៍ដោយប្រជាជនមិនពិបាកប្រកបរបរចិញ្ចឹមជីវិត និងមិនពិបាកជំពាក់បំណុលនរណាឡើយ។ នៅក្នុងជំនាន់នោះខ្ញុំនៅចាំសាច់រឿងខ្លះៗដែលខ្ញុំបានសម្ដែង ដោយប្រធានក្រុមតម្រូវឲ្យខ្ញុំសម្ដែងជាកុមារកំព្រាឪពុកម្ដាយដែលត្រូវខ្មាំងយកទៅសម្លាប់។ ក្នុងសាច់រឿងនោះ ខ្ញុំសម្ដែងធ្វើជាយាយខ្ញុំឱបប្អូនពីរនាក់រង់ចាំឪពុកម្ដាយដែលចេញទៅដីកទំពាំង ហើយបាត់មិនឃើញត្រឡប់មកផ្ទះវិញ។ ពេលនោះខ្ញុំបានសម្ដែងជាធ្វើស្រែកយំដង្ហោយហៅពុកម៉ែព្រមទាំងសួរអ្នកជិតខាងថា «មានឃើញពុកម៉ែខ្ញុំទេ?»។

លុះឆ្នាំ១៩៧៥ មុនពេលបែកទីក្រុងភ្នំពេញមួយខែ ខ្ញុំបានរៀបការមានគ្រួសារ។ ប្ដីខ្ញុំបានស្នើរទៅថ្នាក់លើមានភូមិ-ឃុំ ដើម្បីរៀបកម្មពិធីដោយនៅពេលនោះយើងរៀបការតែចំនួនពីរគូប៉ុណ្ណោះ។ លុះដល់ថ្ងៃទី១៧ មេសា ១៩៧៥ ក្នុងឆ្នាំដដែលនោះ ក៏លេចឮដំណឹងមកថា ខ្មែរក្រហមទទួលបានជ័យជម្នះលើរបប លន់ នល់ នៅទីក្រុងភ្នំពេញ។ ដូច្នេះប្រជាជននៅក្នុងស្រុកជីក្រែងត្រូវបានជម្លៀសចេញមករស់នៅខេត្តសៀមរាប ហើយចាប់តាំងពីពេលនោះមកខ្ញុំនិងគ្រួសារបានបែកគ្នា។ ប្រជាជនស្រុកជីក្រែងទាំងអស់ត្រូវបានខ្មែរក្រហមចាត់ទុកថា អ្នកប្រជាជន ១៧ មេសា ឬជាប្រជាជនកសាងខ្លួន។ គោលការណ៍របស់ខ្មែរក្រហមនៅពេលនោះគឺយកប្រជាជន១៧ មេសា ឬប្រជាជនកសាងខ្លួននោះទៅសម្លាប់ទាំងអស់នៅភ្នំហប់។ ប៉ុន្តែដោយខ្ញុំបានដឹងខ្លួនមុន ខ្ញុំបានប្ដូរឈ្មោះនិងប្ដូរប្រវត្តិរូបខ្លួនឯងថាខ្ញុំជាប្រជាជនរស់នៅភូមិត្រពាំងទឹម ទើបខ្ញុំមានជីវិតរស់។

បន្ទាប់ពីនោះមក ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យមកធ្វើជាកងចល័តនៅក្នុងខេត្តសៀមរាប ដែលត្រូវធ្វើការងារដូចជា ភ្ជួរស្រែ ស្ទូងស្រូវ និងច្រូតស្រូវ។ ខ្មែរក្រហមបានកំណត់ផែនការឲ្យយើងច្រូតស្រូវ ១ហិកតា មានគ្នា៨នាក់។ បើយើងគិតជាកណ្ដាប់ស្រូវក្នុងម្នាក់ ១៥០០កណ្ដាប់ដែលយើងត្រូវច្រូតឲ្យរួចរាល់ក្នុងរយៈពេលមួយយប់មួយថ្ងៃ។ ចំពោះអ្នកភ្ជួររាស់ ខ្មែរក្រហមកំណត់ផែនការថាមួយហិកតាគ្នាបីនាក់ ឲ្យរួចរាល់ត្រឹមម៉ោង១១ថ្ងៃត្រង់ ឬស្មើនឹងកន្លះថ្ងៃ ដោយប្រើនង្គ័លសម្រាប់ភ្ជួរ។ ចំណែកអ្នកលើកភ្លឺស្រែវិញក្នុងម្នាក់កំណត់យក២៥ម៉ែត្រ កម្ពស់កន្លះម៉ែត្រ ធ្វើយ៉ាងណាឲ្យរួចក្នុងរយៈពេលមួយថ្ងៃ។ កិច្ចការងារទាំងអស់ត្រូវធ្វើទៅតាមអ្វីដែលខ្មែរក្រហមបានកំណត់ បើមិនដូច្នេះទេយើងនឹងត្រូវដាក់ទោសដោយការបង្អត់បាយ ឬយកទៅសម្លាប់ចោលតែម្ដង។ ពេលនោះខ្ញុំគិតថាទោះបីខ្ញុំមានជីវិតនៅរស់មែន ប៉ុន្តែនោះគឺជាពេលវេលាដ៏សែនវេទនាណាស់សម្រាប់ខ្ញុំ។ យើងទទួលបានរបបមួយថ្ងៃពីរពេលប៉ុណ្ណោះគឺ ពេលព្រឹក និងពេលថ្ងៃ។ ការហូបចុកយើងមានកំណត់ ហើយយើងមិនដែលស្គាល់សជាតិបាយយ៉ាងណានោះទេ ទោះបីមាន

បាយក៏ត្រូវបានចុងភៅច្របល់លាយគ្នាជាមួយដំឡូងដែរ។ បើមិនដូច្នេះយើងទទួលបានត្រឹមបបរម្នាក់មួយកូនចាន ចង្កឹះដែលមានតែទឹកថ្លាឈ្វេង។ ជារឿយៗខ្ញុំតែង ឃើញកម្មាភិបាលធំៗចុះមកមើលការខុសត្រូវលើការងារដកស្ទូង ប៉ុន្តែខ្ញុំមិនស្គាល់ថាជានរណានោះទេ។ គ្រាន់តែខ្ញុំដឹងថាក្រុមដកស្ទូងណាធ្វើការងារបានល្អ ក្រុមកម្មាភិបាលសរសើរទៅតាមនោះដែរ។ ប៉ុន្តែវាគ្មានយុត្តិធម៌សម្រាប់យើងនោះទេ កម្មាភិបាលទាំងនោះមកគ្រាន់តែចង់បង្ហាញថាខ្លួនបានធ្វើការដើម្បីរាយការណ៍ទៅកាន់ថ្នាក់លើប៉ុណ្ណោះ។

បន្ទាប់មកនៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនខ្ញុំមកវែកដីនៅទំនប់កោះខ្យល់ ខេត្តបាត់ដំបង។ ខ្ញុំវែកដីនៅទីនោះបាន១ខែ ២០ថ្ងៃ ខ្មែរក្រហមក៏ប្តូរខ្ញុំឲ្យមកធ្វើជាអ្នកដេរស្បៀក និងជួសសំណាញ់បង់ត្រីនៅភូមិគោកចាស់ ខេត្តបន្ទាយមានជ័យវិញ។ ការរស់នៅទីនោះមានការប្រសើរជាងមុនបន្តិច ដោយសារខ្មែរក្រហមបានអនុញ្ញាតឲ្យយើងធ្វើការនេសាទត្រីយកមកហូបដោយខ្លួនឯង។ ដូច្នេះនៅក្នុងសហករណ៍របស់យើងពុំសូវជួបប្រទះនូវការខ្វះខាតម្ហូបអាហារឡើយ។

លុះដល់ឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមកនៅតាមសហករណ៍នីមួយៗក៏ចាប់ផ្តើមបែកខ្ញែកគ្នា។ យើងបានរត់ភៀសខ្លួនទៅតាមភូមិស្រុករៀងៗខ្លួន ដោយខ្ញុំបានធ្វើដំណើរមកកាន់ភូមិកំណើតខ្ញុំនៅភូមិត្រពាំងត្រស់ ខេត្តសៀមរាបវិញ។ ពេលនោះខ្ញុំគិតថា ជីវិតខ្ញុំហាក់បីដូចបានកើតជាថ្មីម្តងទៀត ព្រោះខ្ញុំបានវិលមកជួបជុំគ្រួសារ និងឪពុកម្តាយវិញ។

នៅក្នុងឆ្នាំ១៩៩៩ ខ្ញុំនិងគ្រួសារក៏ផ្លាស់ប្តូរមកប្រកបរបរលក់បន្លែនៅផ្សារក្រឡាញ់ ខេត្តសៀមរាប។ ប៉ុន្តែដល់ឆ្នាំ២០០០ ដោយសារមុខរបរខ្ញុំពុំសូវកាក់កប ខ្ញុំនិងគ្រួសារក៏សម្រេចចិត្តធ្វើដំណើរមករស់នៅស្រុកអន្លង់វែង។ មូលហេតុដែលខ្ញុំមករស់នៅស្រុកអន្លង់វែង ដោយសារតែខ្ញុំគិតថានៅទីនេះមានផ្ទៃដីគ្រប់គ្រាន់ឲ្យខ្ញុំអាចប្រកបរបរធ្វើស្រែចម្ការសម្រាប់ចិញ្ចឹមគ្រួសារបាន។

កន្លងមកខ្ញុំធ្លាប់បានដឹងទាក់ទងនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម នៅភ្នំពេញដែរ។ សម្រាប់ខ្ញុំ ការកាត់ទោស គឺជារឿងមួយដ៏ល្អណាស់សម្រាប់ប្រជាជនខ្មែរដែលជាអ្នករស់រានក្រោយរបបខ្មែរក្រហម។ ខ្ញុំគិតថាអ្នកដឹកនាំខ្មែរក្រហមបានប្រព្រឹត្តខុស ធ្វើបាបប្រជាជនគឺសាកសមទទួលនូវអ្វីដែលខ្លួនបានធ្វើ។ បើទោះបីវាមិនអាចសងនូវអ្វីដែលបាត់បង់ត្រឡប់មកវិញក៏ពិតមែន ប៉ុន្តែវាបានជួយផ្សះផ្សានូវភាពឈឺចាប់របស់ប្រជាជនខ្មែរយើងបានមួយចំនួន។

ខ្ញុំសូមផ្តាំទៅកូនចៅជំនាន់ក្រោយថា ធ្វើយ៉ាងណាកុំឲ្យរបបមួយនេះវិលត្រឡប់មកវិញម្តងទៀត។ យើងត្រូវប្រឹងប្រែងរៀនសូត្រ យកចំណេះវិជ្ជាមកកសាងប្រទេសជាតិឲ្យកាន់តែមានការរីកចម្រើនតទៅមុខជានិរន្តរ៍។



ហម សឿម អាយុ៦៧
រស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ហ៊ាន ពិសី /មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិសាស្ត្រគ្រួសារនៅខេត្តត្បូងឃ្មុំ

ឡុង ដានី

*ពីថ្ងៃទី១៦ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ រួមមាន ឡុង ដានី រី លក្ខិណា និង គាត់ ស្រី ឡែន ទៅសម្ភាសន៍ប្រជាជននៅក្នុងឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ គម្រោងនេះនឹងផ្តល់ការយល់ដឹងកាន់តែច្បាស់លាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងគ្រួសារ ក្រៅពីការសិក្សារៀនសូត្រនៅក្នុងកម្មវិធីសិក្សាផ្លូវការនៅតាមសាលាចំណេះទូទៅរបស់រដ្ឋ ដែលជាមធ្យោបាយដើម្បីការពារក្រុមគ្រួសារ សហគមន៍ និងប្រទេសជាតិពីអំពើប្រល័យពូជសាសន៍។ ខាងក្រោមគឺជាសាច់រឿងរបស់ប្រជាជនះ*

ខ្ញុំឈ្មោះ ប៉ិច សាំង អាយុ ៦៦ឆ្នាំ គឺជាជនជាតិដើមភាគតិចស្ទៀង មានស្រុកកំណើតនៅភូមិទំពូក ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុកខ្ញុំឈ្មោះ ព្រះ ប៉ិច និងម្តាយឈ្មោះ មិច ទៀន។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ស្រីចំនួន១នាក់។ បងប្អូនប្រុសចំនួន២នាក់ បានស្លាប់ដោយសារតែទៅធ្វើទាហាននៅភូមិភាគបូព៌ា។ កាលពីក្មេងខ្ញុំបានរៀនសូត្របានរយៈពេល ២ឆ្នាំនៅវត្តកន្ទួត។ ខ្ញុំឈប់រៀននៅឆ្នាំ១៩៧៣ ក្រោយពីឈប់រៀនខ្ញុំបានចូលធ្វើជាឈ្លបនៅក្នុងឃុំជាំតាម៉ៅ ដែលមាននាទីយាមការពារប្រជាជនក្នុងភូមិ។ ឆ្នាំ១៩៧៤ ខ្ញុំចូលធ្វើជាយោធាស្រុកមេមត់គណៈស្រុកមេមត់ឈ្មោះ ញឹក ហួន។ តា ចាន់ គឺជាប្រធានតំបន់២១។ បន្ទាប់ពីរំដោះឆ្នាំ១៩៧៥ ខ្ញុំផ្លាស់ទៅនៅតំបែ និងនៅមន្ទីរស១០០ ដែលមានតា សឿង និងតាដែន គឺជាប្រធាន និងអនុប្រធានយោធាតំបន់២១។ បន្ទាប់មកខ្ញុំត្រូវបានបញ្ជូនមកការពារព្រំដែននៅក្នុងឃុំចាន់មូល។ នៅឆ្នាំ១៩៧៧ កងទ័ពមជ្ឈិមបានហៅកងទ័ពដែលមានឋានៈចាប់ពី ប្រធាន «ខ» ប្រធាន «គ» ប្រធាន «ឃ» ទៅប្រជុំនិងចាប់ដាក់ឡានយកទៅសម្លាប់ចោល។ ចំណែកខ្ញុំគឺជាកូនចៅដែលគ្មានឋានៈ



ប៉ិច សាំង អាយុ ៦៦ឆ្នាំ គឺជាជនជាតិដើមភាគតិចស្ទៀង មានស្រុកកំណើតនៅភូមិទំពូក ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (រី លក្ខិណា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្វីគេមិនបានចាប់នោះទេ។ ខ្ញុំក៏ដូរខោអាវ និងយកកាំភ្លើងទៅកប់ក្នុងដី ហើយត្រឡប់មកធ្វើជាកងចល័តវិញ។ ក្រោយមកក្រុមនិរតីបន្តស្រាវជ្រាវរហូតដឹងពីសមាសភាពរបស់ខ្ញុំធ្លាប់ធ្វើយោធា ក្រុមនិរតីបានចាប់ខ្ញុំទៅមន្ទីរសន្តិសុខ ដែលមានគ្នាសរុប ៣០នាក់។ ពេលនៅក្នុងមន្ទីរសន្តិសុខ ខ្មែរក្រហមបញ្ជាឲ្យធ្វើការងារគាស់គល់ឈើធ្វើស្រែ។ ពេលនោះមានអ្នកទោសបានលួចដំឡូង ហើយត្រូវសន្តិសុខចាប់យកទៅសម្លាប់។ នៅពេលដែលវៀតណាមចូលមកទម្លាក់គ្រាប់បែកនៅស្រែរនាម។ ក្រុមសន្តិសុខ

រត់អស់ ទើបខ្ញុំបានរួចខ្លួន និងធ្វើដំណើរមកដល់ស្ទឹងត្រង់ជាមួយកងទ័ព និងប្រជាជនផ្សេងៗទៀត។ ពេលមកដល់ស្ទឹងត្រង់ ប្រជាជនចែកបាយឲ្យហូបគ្រប់គ្រាន់។ នៅឆ្នាំ១៩៧៩ ខ្ញុំបានសុំឡានកងទ័ពវៀតណាមជិះត្រឡប់មកស្រុកកំណើតវិញ។ ឆ្នាំ១៩៨៨ ទើបខ្ញុំរៀបការ។



តូច រឿង ភេទប្រុស អាយុ៦៧ឆ្នាំ ។
(គាត ស្រីឡែន / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ តូច រឿង ភេទប្រុស អាយុ៦៧ឆ្នាំ គឺជាជនជាតិស្ទៀង។ រឿង មានស្រុកកំណើតនៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃរស់នៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ វ៉ិក និងម្ដាយឈ្មោះ ភេម។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូន៦នាក់ ស្រីចំនួន២នាក់ និងប្រុសចំនួន ៤នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ពៅ ញ៉ាក់ និងមានកូនចំនួន ៧នាក់ ស្រី ៥នាក់ និងប្រុស២នាក់។ កាលពីតូចៗខ្ញុំរៀនបានតិចតួច ព្រោះគ្មានសាលារៀន មានតែរៀននៅវត្តលោក។ ខ្ញុំធ្លាប់បានទៅស៊ីឈ្នួលចៀរជ័រកៅស៊ូឲ្យបារាំង។ ទីតាំងចម្ការកៅស៊ូបារាំងនៅឡាំ ប៉ោ ដែលមានចម្ងាយពីភូមិរបស់ខ្ញុំប្រមាណជា២គីឡូម៉ែត្រ។ កម្មករនៅក្នុងចម្ការកៅស៊ូមាន បងប្អូនជនជាតិចាម និងជនជាតិវៀតណាម និងជនជាតិខ្មែរដែលមកពីភូមិផ្សេងៗ។ ភូមិខ្ញុំកាលពីដើមមានប្រជាជនប្រហែល២០ខ្នងផ្ទះ និងប្រើប្រាស់ភាសាស្ទៀង។ ពេលមានជំងឺម្ដងៗអត់មានពេទ្យទេនៅក្នុងភូមិ ឪពុកម្ដាយខ្ញុំប្រើប្រាស់ថ្នាំបុរាណ និងរកគ្រូស្ដោះផ្លុំ ឬបញ្ជាន់អារក្ខ។ នៅឆ្នាំ១៩៧០ ខ្ញុំ ប្រជាជនខ្មែរលក់អង្ករឲ្យយៀកកុងនៅតាមព្រំដែន។



ពៅ ញ៉ាក់ អាយុ៦៣ឆ្នាំ។
(ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ពៅ ញ៉ាក់ ភេទស្រី អាយុ៦៣ឆ្នាំ គឺជាជនជាតិដើមភាគតិចស្ទៀង និងរស់នៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានម្ដាយឈ្មោះ ផែ ឡាញ់ និងឪពុកឈ្មោះ ពៅ ចប។ ខ្ញុំមានបងប្អូន ចំនួន ៧នាក់ គឺប្រុស ចំនួន ៤នាក់ និងស្រីចំនួន ៣នាក់ ។ កាលពីក្មេងខ្ញុំបានរៀនសូត្រត្រឹមថ្នាក់ទី ២ នៅវត្តកន្ទួត ដែលស្ថិតនៅក្បែរផ្ទះ។ ខ្ញុំរៀនអក្សរលេខបានត្រឹមចេះអានសរសេរបន្តិចបន្តួចប៉ុណ្ណោះ។ បន្ទាប់មកខ្ញុំឈប់រៀនមកជួយធ្វើការងារម្ដាយខ្ញុំវិញ។ ម្ដាយខ្ញុំកាលនោះគាត់ខុសរ្យាហ៍ឈឺ ខ្ញុំមើលប្អូនតូចៗ និងជួយធ្វើស្រែចម្ការម្ដាយរបស់ខ្ញុំ។ ក្រោយមកក្នុងឆ្នាំ ១៩៧០ នៅក្នុងប្រទេសកើតមានរដ្ឋប្រហារ កាលនោះ ឪពុករបស់ខ្ញុំបានទៅចូលរួមធ្វើបាតុកម្ម ។ នៅពេលគាត់ត្រឡប់មកផ្ទះវិញ គាត់បាននិយាយប្រាប់ខ្ញុំថា មានគេមកឃោសនាឲ្យទៅទទួលសម្ដេចឪ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីមករស់នៅក្នុងភូមិរបស់ខ្ញុំ រស់នៅតាមផ្ទះប្រជាជន និងធ្វើស្រែធ្វើចម្ការដូចប្រជាជនទូទៅដែរ។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវខ្មែរក្រហមឲ្យទៅលើកប្រព័ន្ធភ្លឺស្រែនៅឃុំជាំតាម៉ៅ ដែល នៅទីនោះមានមនុស្សប្រហែលជា១០០នាក់។ នៅពេលទៅធ្វើការនៅទីនោះ ខ្ញុំនៅឆ្ងាយពីឪពុកម្ដាយ ហើយខ្ញុំបានសុំខ្មែរក្រហមមកលេងឪពុកម្ដាយ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបាននាំខ្ញុំទៅធ្វើជាកងទ័ពនារី នៅឃុំចាន់មូល។ កងទ័ពនារីមានសមាជិកប្រហែល១០០នាក់ ។ ខ្មែរក្រហមបានចាត់តាំងកងទ័ពនារីធ្វើការងារ

ដូចជាដាំបាយ ធ្វើម្ហូបសម្រាប់កងទ័ពបុរសដែលទៅសមរភូមិ។ ខ្ញុំធ្វើការនៅទីនោះបានមួយវស្សា ខ្មែរក្រហមជម្លៀសខ្ញុំទៅក្រចេះ។ ទៅដល់ទីនោះ ខ្មែរក្រហមបានឲ្យខ្ញុំសែងអ្នករបួស និងសាកសពកងទ័ព។ កាលនោះខ្ញុំសែងអ្នករបួសនៅស្រែស្រណុក ស្រុកឆ្លូង។ ក្នុងសាកសពម្នាក់ត្រូវសែងដោយនារីពី៣នាក់។ នៅឆ្នាំ១៩៨០ ខ្ញុំបានរៀបការជាមួយប្ដីរបស់ខ្ញុំ។



សេក អ៊ូច អាយុ៦៧ឆ្នាំ។
(ឡុង ដានី / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សេក អ៊ូច ភេទស្រី អាយុ៦៧ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម ប៉ុន្តែប្ដូរទៅជាខេត្តត្បូងឃ្មុំ។ សព្វថ្ងៃខ្ញុំរស់នៅភូមិដដែល។ ខ្ញុំមានម្ដាយឈ្មោះ កែវ និងឪពុកឈ្មោះ នៅ។ ប្ដីរបស់ខ្ញុំឈ្មោះ ស សារូ។ ខ្ញុំមានកូនចំនួន៧នាក់ គឺ ប្រុស៤នាក់ ស្រី ៣នាក់។ កាលពីក្មេងខ្ញុំរៀនសូត្របន្តិចបន្តួចនៅពេលយប់ នៅសាលាវត្តកន្ទួត។ នៅម៉ោង៧យប់ខ្ញុំ និងក្មេងក្នុងភូមិនាំគ្នាដើរទៅវត្តកន្ទួតដើម្បីរៀនអក្សរ។ ខ្ញុំឈប់រៀនក្នុងឆ្នាំ១៩៧០ ដោយសារសង្គ្រាម។ ខ្ញុំឃើញមានទាហានអាមេរិកចូលមកដល់ក្នុងភូមិ។ ប្រសិនប្រជាជនណាម្នាក់មានជំងឺ ទាហានអាមេរិកយកទៅព្យាបាល និងចាក់ថ្នាំឲ្យប្រជាជនគ្រប់គ្នា។ ថ្ងៃមួយខ្ញុំឈឺគ្រុនក្ដៅ ទាហានអាមេរិកនាំខ្ញុំទៅព្យាបាលចាក់ថ្នាំ និងឲ្យថ្នាំលេប។

នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាទាហានកងទ័ពរំដោះ ខ្ញុំត្រូវផ្លាស់ទៅនៅគោញ ក្នុងឃុំរូង។ នៅទីនោះខ្ញុំបានជួយធ្វើស្រែប្រជាជន។ ប្រធានគ-២ ឈ្មោះយាយម៉ៅ និងប្រធានគ-១ ឈ្មោះ យាយសេង។ ក្រោយមកទៀតនៅឆ្នាំ១៩៧៥ ខ្ញុំ និងអង្គភាពត្រូវផ្លាស់មករស់នៅភូមិ ងើ ធ្វើស្រែជាមួយប្រជាជនបានរយៈពេល១ខែ អង្គភាពរបស់ខ្ញុំត្រូវត្រឡប់មកនៅភូមិបេងកោងវិញ។ ខ្ញុំជួយធ្វើការងារដាំស្រូវជាមួយអ្នកភូមិ រហូតដល់ឆ្នាំ១៩៧៧។ នៅពេលកងទ័ពមជ្ឈិមចូលមកចាប់យាយម៉ៅ និងយាយសេង នៅបេងកោង ខ្ញុំបានរត់បែកពីក្រុម មករកឪពុកម្ដាយនៅជំនុំពល។ ខ្ញុំស្នាក់នៅផ្ទះប្រជាជន។ ក្រោយមកខ្ញុំត្រូវជម្លៀសទៅក្រចេះ។ នៅពេលកងទ័ពវៀតណាមចូលមក ខ្ញុំដើរត្រឡប់មកផ្ទះជាមួយបងប្រុសរបស់ខ្ញុំ។



ខៀវ ប៉ិច អាយុ៧៨ឆ្នាំ។
(ឡុង ដានី / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ខៀវ ប៉ិច ភេទស្រី អាយុ៧៨ឆ្នាំ។ ខ្ញុំគឺជាជនជាតិដើមភាគតិចស្អៀង និងរស់នៅក្នុងភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ម្ដាយរបស់ខ្ញុំឈ្មោះ អៀន និងឪពុកឈ្មោះ ខៀវ។ ខ្ញុំមានបងប្អូនចំនួន៧នាក់ ស្រី ៦នាក់ និងប្រុស១នាក់។ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្មានសាលា ហើយខ្ញុំត្រូវនៅផ្ទះជួយការងារឪពុកម្ដាយធ្វើចម្ការ និងដាំស្រូវ។ នៅពេលទំនេរខ្ញុំតែងតែទៅចម្ការកៅស៊ូរបស់បារាំងនៅឡាំបោ ដើម្បីបេះបន្លែ បេះល្ពៅ យកមកធ្វើម្ហូប។ ខ្ញុំរៀបការនៅមុនរដ្ឋប្រហារ។ បន្ទាប់ពីរៀបការរួច ខ្ញុំនិងប្ដីរត់ចូលព្រៃដើម្បីគេចពីទម្លាក់គ្រាប់បែក។ ខ្ញុំពួនតាមព្រៃឫស្សី ពេលនោះខ្ញុំមានកូនមួយ ខ្ញុំរត់ឱបកូនមុជបន្ទាឫស្សីដោយភ័យ

ខ្លាចសំឡេងយន្តហោះទម្លាក់គ្រាប់។ កាលនោះទាហានអាមេរិកមានបន្ទាយនៅខាងកើតភូមិ។ នៅឆ្នាំ១៩៧៣ នៅក្នុងភូមិ ប្រជាជនធ្វើស្រែប្រវាស់ដៃ ក្រោយមកមិនបានប៉ុន្មាន ខ្មែរក្រហមបានឲ្យប្រជាជនហូបបាយរួម។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំត្រូវខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែនៅក្នុងភូមិមួយរយៈ។ ក្រោយមកទៀត ខ្មែរក្រហមឲ្យខ្ញុំមើលក្មេងៗ នៅក្នុងកង។ ខ្ញុំមើលថែក្មេងដែលមានអាយុចន្លោះពី៧ ទៅ៨ឆ្នាំ។ ក្រោយមកនៅឆ្នាំ១៩៧៨ ខ្ញុំនិងក្រុមគ្រួសារត្រូវខ្មែរក្រហមជម្លៀសទៅខេត្តក្រចេះ។ ពេលទៅដល់ក្រចេះ ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យធ្វើការងារលើកប្រព័ន្ធភ្លឺស្រែនិងទំនប់។ ខ្ញុំធ្វើការងារមិនបានប៉ុន្មាន ខ្មែរក្រហមចាត់ឲ្យខ្ញុំទៅមើលក្មេងៗម្តងទៀត។ នៅពេលរំដោះឆ្នាំ ១៩៧៩ ខ្ញុំបានត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំធ្វើដំណើរមកជាមួយប្តី និងកូនតូចរបស់ខ្ញុំ។ នៅតាមផ្លូវប្តី របស់ខ្ញុំឈឺរហូតព្រោះគាត់គ្មានកម្លាំង និងគ្មានអាហារហូប។ ខ្ញុំគ្រាប្តី និងពរកូនមករហូត។ ខ្ញុំឈប់សម្រាកនៅកាត់ដៃមួយខែ។ កាលនោះប្រជាជនឲ្យខ្ញុំធ្វើជ្រូកក្នុងទ្រុង ដើម្បីធ្វើម្ហូប។ ខ្ញុំស្នាក់នៅទីនោះរយៈពេល១ខែ រង់ចាំឲ្យប្តីរបស់ខ្ញុំមានកម្លាំង។ ក្រោយមកយើងមកដល់ស្រុកកំណើត។



សឿ យេន អាយុ៧៨ឆ្នាំ។
(វី លក្ខិណា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សឿ យេន ភេទប្រុស អាយុ៧៨ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិជ័យសម្បត្តិ ឃុំតាំបែរ ស្រុកតាំបែរ ខេត្តកំពង់ចាម (សព្វថ្ងៃខេត្តត្បូងឃ្មុំ)។ ឪពុករបស់ខ្ញុំឈ្មោះ ហែម សឿ និង ម្តាយឈ្មោះ ឃ្លោក មី។ ខ្ញុំមានបងប្អូនចំនួន៨នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ មាស មឿន និងមានកូន៥នាក់។ កាលពីសង្គមចាស់ខ្ញុំរៀននៅសាលាវត្ត ក្រោយមកខ្ញុំបួសបាន៤វស្សានៅវត្តតាំបែរ។ ខ្ញុំសឹកនៅពេលដែលកើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០។ ខ្ញុំសឹកបានរយៈពេល៣ខែ នៅក្នុងភូមិរបស់ខ្ញុំមានការជ្រើសរើសយុវជនឲ្យចូលបម្រើជាកងទ័ពរំដោះ ដោយនាំគ្នាចូលព្រៃនៅតាំបែរដែលជាមូលដ្ឋាន។ មុនដំបូងមានការបង្ហាត់បង្រៀនពីកងទ័ពវៀតណាមខាងជើង ឈ្មោះ ណាំបិញ។ ព្រៃដែលខ្ញុំនៅហ្វឹកហាត់នោះត្រូវបានស្គាល់ឈ្មោះថា ព្រៃសង្កែ ដោយនៅខាងក្នុងមានប្រក់ស្លឹកទ្រាំងធ្វើជាដំរំ។ យើងនាំគ្នាត្រួសត្រាយស្មៅឲ្យទៅជាវាល សម្រាប់ហាត់លូន ក្រាប និងប្រើប្រាស់កាំភ្លើង។ ដំបូងគឺយើងហ្វឹកហាត់ម្នាងគឺជាខ្លាំង ម្នាងទៀតគឺជាកងទ័ពរៀនបាញ់កាំភ្លើងឈើ និងគប់ដុំដី។ ពេលដែលហ្វឹកហាត់ស្ទាត់ជំនាញរយៈពេលមួយឆ្នាំ ទើបយើងអាចកាន់កាំភ្លើង។ យើងរៀបចំជាក្រុមត្រៀមវាយជាមួយនឹងទាហានធីវគី ចាប់ពីស្រុកតាំបែររហូតដល់ស្រុកឆ្លូង។ ប្រធានវរៈរបស់ខ្ញុំឈ្មោះ ពិសិដ្ឋ ហៅ ជ្រោយ។ ប្រធានយោធាតំបន់ឈ្មោះតាឯក ក្រោយមកឡើងជំនួសដោយ តាដែន។ វរៈ៥៩ ឈ្មោះតាសឿង និង លី សុភាព។ វរៈ៥៥ មានឈ្មោះ តាសាធ និងតាសី ហើយមានចំនួន ២គ គឺ គ-៦២ និងគ-៦៣។ ខ្ញុំនៅក្នុងគ-៦២ ឈរជើងនៅគោកចារ នៅជីរោទ៍រហូតដល់ទន្លេបិទ។ នៅឆ្នាំ ១៩៧៥ ខ្ញុំបានសម្រាកពីកងទ័ព មកនៅក្នុងសហករណ៍។ ក្រោយមកគណៈស្រុកបានឲ្យខ្ញុំទៅធ្វើការនៅសង្កាត់រំចេក រយៈពេល ២ឆ្នាំ ៣ខែ។ ខ្ញុំបានរៀបការជាមួយនឹងកូនខ្មែរកាត់វៀតណាម។ នៅពេលដែលកងទ័ពនិរតីចូលមក គឺសម្លាប់អ្នកដែលជាប់សែស្រឡាយជាមួយនឹងវៀតណាមចោលទាំងអស់។ ខ្ញុំទទួលដំណឹងថានិរតីចង់ចាប់អ្នកបូព៌ាទាំងអស់ដែលជាថ្នាក់ដឹកនាំ។ ខ្ញុំ, ព្រាប ពិជ័យ, សុខ កែម, សុខ គង់ និង ឈិត ឃើញសភាពការណ៍មិនស្រួលក៏នាំគ្នារត់ចូលព្រៃ ប៉ុន្តែប្រពន្ធរបស់ខ្ញុំមិនបានរត់ទៅជាមួយខ្ញុំទេ។ ប្រពន្ធរបស់ខ្ញុំដែលកាត់វៀតណាមត្រូវទ័ពមជ្ឈិម និងនិរតីសម្លាប់ចោល។ នៅក្នុងព្រៃខ្ញុំបាន

យកអង្ករដែលខាងសហករណ៍យកទៅលាក់នៅក្នុងព្រៃហូបជាមួយនឹងអំបិល។ នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលទៅដល់ក្នុងព្រៃក៏បានជួបជាមួយយើង ដែលកំពុងលាក់ខ្លួន។ កងទ័ពវៀតណាមបានឲ្យកាំភ្លើង និងខោអាវ មកយើងដើម្បីវាយជាមួយនឹងខ្មែរក្រហមវិញ។ កងទ័ពវៀតណាមបញ្ជូនខ្ញុំនិងអ្នកផ្សេងទាំងអស់៦២នាក់ទៅហាត់រៀននៅបន្ទាយធូឹក សមុទ្រក្រហមរយៈពេល ៣ខែ។ ទៅដល់វៀតណាមខ្ញុំរៀននយោបាយ យុទ្ធសាស្ត្រ ហ៊ឹកហាត់ទាហាន ច្បាប់ទាហាន។ ពេលត្រឡប់មកវិញ ខ្ញុំនៅក្នុងគណៈចាត់តាំងស្រុកមេមត់។ ក្រោយមកខ្ញុំបានទៅធ្វើជាមេឃុំរំចេករយៈពេល៣ខែ ៦ថ្ងៃ ដើម្បីពង្រឹងនៅខាងឃុំរំចេក។ ពេលឃុំរំចេករឹងមាំហើយ ខ្ញុំត្រឡប់មកកាន់ទ័ពនៅស្រុកមេមត់វិញ។ នៅឆ្នាំ១៩៨២ ខ្ញុំក៏សម្រាកពីការធ្វើទ័ពមករស់នៅក្នុងភូមិជាំតាម៉ៅ និងបានរៀបការប្រពន្ធទី ២ និងរស់នៅភូមិជាំតាម៉ៅរហូតដល់សព្វថ្ងៃ។



*សោម ហាច អាយុ៧០ឆ្នាំ។*
*(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សោម ហាច ភេទស្រី អាយុ៧០ឆ្នាំ។ ខ្ញុំគឺជាជនជាតិដើមភាគតិចស្ទៀង និងរស់នៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានម្តាយឈ្មោះ កូវ សិន និងឪពុកឈ្មោះ សោម ដាន់។ ប្តីរបស់ខ្ញុំឈ្មោះ សេក ថៅ។ ខ្ញុំរៀនសូត្របានបន្តិចបន្តួចជាមួយព្រះសង្ឃនៅសាលាវត្តកន្ទួត។ កាលនោះខ្ញុំរៀនវេនយប់ ប៉ុន្តែខ្ញុំរៀនមិនសូវជាប់លាប់នោះទេ ព្រោះត្រូវជួយការងារម្តាយ។ នៅម៉ោង៧យប់ទើបខ្ញុំទៅរៀន ហើយម៉ោង៨ត្រឡប់មកផ្ទះវិញ។ នៅពេលព្រឹកខ្ញុំត្រូវមើលប្អូនតូចៗ ព្រោះម្តាយទៅធ្វើចម្ការ។ ខ្ញុំត្រូវមេភូមិឲ្យខ្ញុំយាមការពារភូមិដើម្បីកុំឲ្យកងទ័ពវៀតកុង និងទាហានអាមេរិកចូលមកដែលនាំឲ្យមានការជួបប្រយុទ្ធគ្នា និងបង្កឲ្យមានគ្រោះថ្នាក់ដល់ប្រជាជន។ នៅឆ្នាំ១៩៧៣ ក្នុងភូមិចាប់ផ្តើមធ្វើការងារប្រវាស់ដៃ។ រហូតមកដល់ឆ្នាំ១៩៧៤ ប្រជាជនក្នុងភូមិចាប់ផ្តើមធ្វើការរួម។ យើងមានរោងមួយសម្រាប់ប្រជាជននៅក្នុងភូមិមកហូបបាយជុំគ្នា។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជន១៧ មេសា ចូលមកក្នុងភូមិរបស់ខ្ញុំ និងឲ្យរស់នៅតាមផ្ទះអ្នកស្រុក។ ខ្មែរក្រហមចាត់តាំងឲ្យប្រជាជនជម្លៀសធ្វើចម្ការដូចអ្នកភូមិដែរ។ ខ្ញុំរស់នៅក្នុងភូមិ ដូច្នេះខ្មែរក្រហមចាត់តាំងឲ្យខ្ញុំធ្វើចម្ការរហូតដល់ឆ្នាំ១៩៧៧ ទើបជម្លៀសទៅខេត្តក្រចេះ។ នៅពេលទៅដល់ក្រចេះ ខ្មែរក្រហមឲ្យខ្ញុំលើកប្រព័ន្ធភ្លឺស្រែ និងធ្វើស្រែចម្ការ។ នៅទីនោះខ្មែរក្រហមបានឲ្យខ្ញុំរៀបការ ប៉ុន្តែខ្ញុំបដិសេធ ដោយប្រាប់ថា ខ្ញុំមិនទាន់ចង់រៀបការទេ។ ក្រោយមកទៀត ខ្មែរក្រហមជម្លៀសខ្ញុំទៅភូមិផ្សេងៗ។ ខ្ញុំធ្វើការនៅកងចល័តរហូតដល់ថ្ងៃមួយមានប្រជាជនក្នុងភូមិប្រាប់ថា ប្រទេសរំដោះបានហើយ។ ប្រជាជនរស់នៅភូមិណា ស្រុកណាអាចទៅស្រុករបស់ខ្លួនវិញ។ ខ្ញុំដើររហូតដល់ស្រុកកំណើត។ នៅពេលមកដល់ភូមិកន្ទួត ខ្ញុំមិនហ៊ាននៅផ្ទះទេ ព្រោះមានព្រៃដុះព័ទ្ធផ្ទះ។ ខ្ញុំនិងក្រុមគ្រួសារបានធ្វើខ្ទមតូចមួយសម្រាប់រស់នៅ។ ក្រោយមកខ្ញុំរៀបការ ហើយប្រកបរបរធ្វើចម្ការដើម្បីចិញ្ចឹមជីវិត និងរស់នៅទីនេះរហូតមកដល់សព្វថ្ងៃ។

ខ្ញុំឈ្មោះ សេង កុសល ភេទប្រុស អាយុ៧២ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិកោះទ្រង់ ឃុំកោះទ្រង់ ស្រុកក្រចេះ ខេត្តក្រចេះ។ ឪពុករបស់ខ្ញុំឈ្មោះ ឃួន សេង និងម្តាយឈ្មោះ កែវ ឡាំ។ ខ្ញុំមានបងប្អូនចំនួន៣នាក់ គឺប្រុសទាំងអស់។ ប្អូនប្រុសពៅរបស់ខ្ញុំម្នាក់ស្លាប់នៅសមរភូមិទន្លេបិទ។ ប្រពន្ធរបស់ខ្ញុំឈ្មោះ សំ សុខ



*សេង កុសល អាយុ៧២ឆ្នាំ។*
*( រី លក្ខិណា / មជ្ឈមណ្ឌលឯកសារកម្ពុជា )*

*ហៅ សុទ្ធ អាយុ៦៨ឆ្នាំ។ ខ្ញុំរៀនដល់ថ្នាក់ទី៧ នៅសាលាបឋមសិក្សាភូមិកោះទ្រង់។ ក្រោយមកនៅឆ្នាំ១៩៦៨ ខ្ញុំឈប់រៀនហើយចូលបួសជាព្រះសង្ឃ។ រហូតដល់ឆ្នាំ១៩៧០ ខ្ញុំសឹកដោយសារមានសង្គ្រាមមិនអាចគង់នៅក្នុងវត្តបន្តទៀតបាន។ បន្ទាប់ពីសឹកនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧០ ខ្ញុំស្ម័គ្រចិត្តចូលបម្រើកងទ័ពតំបន់២១ តាមរយៈ គ្រូ ស្រេង ។ គ្រូ ស្រេង ទទួលបន្ទុកការងារនៅខេត្តក្រចេះ និងមានអ្នកចូលរួមកងទ័ពខ្មែរក្រហមចំនួន១០០នាក់។ បន្ទាប់មក លោក គ្រូស្រេង ឲ្យកងទ័ពទាំងអស់មកឈរជើងនៅកំពង់រាំង ស្រុកតំបែរ ជាប់ព្រំប្រទល់ជាមួយនឹងស្រុកឆ្លូង។ នៅពេលនោះមានការហាត់រៀនយុទ្ធសាស្ត្រកងទ័ព។ កងទ័ពតំបន់២១មានចំនួន២កងអនុសេនាធំ គឺគ-១ គ្រប់គ្រងដោយ វង្សា និងគ-២ គ្រប់គ្រងដោយ សាង និង សារ៉ាត់។ ក្រោយមកទៀតទើបមានបង្កើតជា គ-៣ គ្រប់គ្រងដោយ ស្រី អារុណ។ នៅពេលហាត់នោះគឺ មានទាំងកងទ័ពវៀតណាម និងកងទ័ពខ្មែរគឺជាអ្នកបង្ហាត់បង្រៀន។ ខ្ញុំហាត់យុទ្ធសាស្ត្រទាហានរយៈពេល៥ទៅ៦ខែ នៅទួលជ្រោះ ក្នុងស្រុកតំបែរ ។ នៅពេលហាត់ចប់ គឺខ្ញុំចេញទៅសមរភូមិពីផ្លូវជាតិលេខ៧ រហូតដល់ចម្ការកាហ្វេ នៅក្នុងឃុំកំពាន់ ស្រុកមេមត់។ អ្នកដែលគ្រប់គ្រងកងទ័ពតំបន់២១ គឺ កែវ សំណាង។ បន្ទាប់ពីកែវ សំណាង ផ្លាស់ទៅភូមិភាគ ឈ្មោះ សាង, សារ៉ាត់ និងសាញ់ ជាអ្នកគ្រប់គ្រងបន្ត។ ទីតាំងមន្ទីរតំបន់២១ នៅព្រៃធុយ ជាប់ ស្រុកក្រូចឆ្មារ។ នៅចុងឆ្នាំ១៩៧២ និងដើមឆ្នាំ១៩៧៣ ខ្ញុំមកកាន់ជាអនុសេនាធំលេខ៩៥។ កងទ័ពខ្ញុំឈរជើងនៅតាមផ្លូវលេខ៧ មកទន្លេបិទ, កងទ័ពសុខ សារឿន ឈរជើងនៅដីរោទិ៍ បឹងព្រួល បឹងកំប្រោរ ចំណែក សាញ់ និងសាធ ឈរជើងនៅខាងក្រោមខ្សែទឹក ចាប់ពីព្រែកដីកដូនម៉ៅ ទៅបឹងមាត់ខ្ទង់ ស្រុកត្បូងឃ្មុំ។ នៅចុងឆ្នាំ១៩៧៣ ពេលដែលបង សាង ប្រធានយោធាតំបន់២១ បានស្លាប់ដោយសារជាន់មីននៅសមរភូមិ ឈ្មោះ អ៊ួង ឯកបានឡើងជំនួស។ នៅឆ្នាំ១៩៧៤ ខ្ញុំត្រូវរបួសទៅសម្រាកព្យាបាលនៅពេទ្យព-២ និងមានស្លាកស្នាម អំបែងគ្រាប់ជាប់នៅក្នុងសាច់ខ្ញុំរហូតមកដល់សព្វថ្ងៃ។ ឯកសណ្ឋានខ្ញុំស្លៀកពាក់កាលនោះគឺខោអាវកងទ័ពគឺពណ៌ត្រែអ៊ុំ និងស្បែកជើងកង់ឡាន។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥ ខាងកងទ័ពបានហៅខ្ញុំឲ្យទៅសមរភូមិបឹងព្រួល គឺក្នុងគោលបំណងចាប់ខ្ញុំ ដោយចោទថាជាខ្មែរស ហើយយកទៅដាក់សន្តិសុខនៅពាមជីលាំង។ ខ្ញុំត្រូវសន្តិសុខវាយនឹងបំពង់ឫស្សី ឲ្យសារភាពពីរឿងហេតុការណ៍ដែលខ្មែរក្រហមចោទខ្ញុំ គឺមិនពិតឡើយ ហើយខ្ញុំបានប្រកែក ទើបឆ្មាំគុកវាយខ្ញុំ។ បន្ទាប់មក តា ចាន់ ហៅ សេង ហុង ដឹងថាខ្មែរក្រហមចាប់ខ្ញុំ គាត់សរសេរសំបុត្រសុំឲ្យដោះលែងខ្ញុំវិញ។ ខ្ញុំត្រូវបានចាត់តាំងឲ្យនៅកន្លែងពិការនៅក្នុងព្រៃស៊ីងក្រពើ៣ និងត្រូវធ្វើត្រែ តុ ធ្វើផ្ទះ ឲ្យបងប្អូនដែលពិការរស់នៅ។ នៅឆ្នាំ១៩៩២ ខ្ញុំមករស់នៅស្រុកមេមត់។ ខ្ញុំគ្រប់គ្រងកម្លាំងជីវពលនៅចម្ការកៅស៊ូ និងគ្រប់គ្រងអ្នកអតីតភាពកងទ័ព។ នៅឆ្នាំ២០០៦ ខ្ញុំធ្វើជាមេភូមិខ្ទង់ក្រពើខាងលិច ហើយចូលនិវត្តន៍នៅឆ្នាំ២០១៩។*

# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

**ជាវ៉ាន់រដ្ឋ មេត្តា**

(តពីលេខមុន)

**៥៩៥.** ខៀវ សំផន នៅរក្សាតួនាទីជារដ្ឋមន្ត្រីក្រសួងការពារជាតិនិងជាអគ្គបញ្ជាការកងទ័ពរំដោះប្រជាជនកម្ពុជា នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចកំណត់បានទេថាតើ ខៀវ សំផន នៅរក្សាតួនាទីជាអគ្គមេបញ្ជាការកងទ័ពដដែល នៅពេលដែលកងទ័ពរំដោះប្រជាជនកម្ពុជាត្រូវបានបញ្ចូលទៅក្នុងកងទ័ពបដិវត្តកម្ពុជា នៅខែកក្កដា ឆ្នាំ១៩៧៥ ដែរឬទេ។ ទោះបីជាសាក្សីបានបញ្ជាក់ថា គាត់បានជួបមេដឹកនាំ មេបញ្ជាការយោធា និងកម្មាភិបាលថ្នាក់តំបន់ ដែលក្នុងការប្រជុំនោះបានពិភាក្សាអំពីបញ្ហាយោធាក្តី តែការបដិសេធច្បាស់លាស់របស់ ខៀវ សំផន ដែលថាគាត់មានសិទ្ធិអំណាចពិតប្រាកដទៅលើកងទ័ពនោះ ត្រូវបានគាំទ្រដោយសាក្សីដទៃទៀត។ អង្គជំនុំជម្រះជឿជាក់ ទៅលើភស្តុតាងជារួមដែលមាននៅចំពោះមុខដែលថា ខៀវ សំផន មិនមានសិទ្ធិអំណាចប្រតិបត្តិផ្នែកកងទ័ពទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

### ៨.៣.២. ប្រធានគណៈប្រធានរដ្ឋ

**៥៩៦.** នៅខែមេសា ឆ្នាំ១៩៧៦ សម្តេចនរោត្តម សីហនុ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបានលាលែងពីតំណែង ដើម្បីបើកផ្លូវឲ្យមានការបង្កើតរដ្ឋាភិបាលថ្មីមួយស្របតាមរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានលុបបំបាត់រាជានិយម និងបង្កើតគណៈប្រធានរដ្ឋដែលមានប្រធានមួយរូបអនុប្រធានពីររូប ដែលមានភារៈកិច្ច«តំណាងឲ្យកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសក្រៅប្រទេស» ស្របតាមច្បាប់និងមាគ៌ានយោបាយរបស់អង្គនីតិបញ្ញត្តិរបស់កម្ពុជាប្រជាធិបតេយ្យ ដែលជាសភាតំណាងប្រជាជនកម្ពុជា។ ជាគោលការណ៍ បេក្ខជនសម្រាប់តែតំណែងគណៈប្រធានរដ្ឋត្រូវជ្រើសរើសដោយសភាតំណាងប្រជាជន។ ប៉ុន្តែជាក់ស្តែង ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋដោយគណៈកម្មាធិការមជ្ឈិម ប.ក.ក. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ប៉ុន្មានថ្ងៃមុនពេលដែលសភាតំណាងប្រជាជនបានកោះប្រជុំជាលើកដំបូង។ ការតែងតាំង ខៀវ សំផន នេះត្រូវបានបញ្ជាក់ជាផ្លូវការនៅក្នុងពិធីបើកសម័យប្រជុំសភាតំណាងប្រជាជន ដែលធ្វើឡើងពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦។

**៥៩៧.** ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បន្តបំពេញមុខងារការទូតនិងពិធីការផ្សេងៗទៀត ដូចជា ទទួលសារតាំងពីអ្នកការទូត ស្វាគមន៍និងជួបប្រជុំជាមួយគណៈប្រតិភូបរទេស ធ្វើជាម្ចាស់ផ្ទះនិងចូលរួមលៀងសាយភោជន៍ថ្នាក់រដ្ឋ ផ្ញើនិងទទួលរួមមហាសន្និបាតលើកទីប្រាំនៃចលនាមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា។

**៥៩៨.** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ក៏បានបន្តធ្វើសន្ទរកថាសរសើរប្រជាជនកម្ពុជានិងកងទ័ពបដិវត្តន៍ដែលបានដើរតួនាទីនៅក្នុង «ការរំដោះ» ទីក្រុងភ្នំពេញគាំទ្រការបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យថ្មីមួយ និងស្ថាប័ននានារបស់ខ្លួន បង្ហាញការគាំទ្រទៅលើគោលនយោបាយរបស់ ប.ក.ក.

ដូចជាការបង្កើតសហករណ៍របបហូបចុក ពលកម្មកុមារ និងការដ្ឋានការងារ អបអរសាទរចំពោះសមិទ្ធផលនៅក្នុងការកសាងជាតិ និងការកែលម្អលក្ខខណ្ឌនៃការរស់នៅ និងផ្តល់ទោសជាសាធារណៈទៅលើ «ការឈ្លានពាន» ពីសំណាក់វៀតណាម។ ខៀវ សំផន បានប្រាប់សហចៅក្រមស៊ើបអង្កេតថា អត្ថន័យនៃសុន្ទរកថារបស់គាត់ «ត្រូវបានអានឲ្យកត់ត្រា» ដោយ ប៉ុល ពត ហើយថា ទោះបីជាគាត់យល់ស្របតាមអ្វីដែលគាត់បាននិយាយ ភាគច្រើនក៏ពិតមែន ក៏ប៉ុន្តែជាបុគ្គល គាត់បង្ហាញមិនយល់ស្របទៅលើការបង្កើនជាក់លាក់មួយចំនួន ដូចជា ពាក់ព័ន្ធនឹងការលុបបំបាត់រូបិយប័ណ្ណជាដើម។

**៥៩៩.** អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មានតួនាទីជាប្រធានគណៈប្រធានរដ្ឋ ចាប់តាំងពីចុងខែមីនា ឆ្នាំ១៩៧៦ រហូតដល់ពេលដែលកម្ពុជាប្រជាធិបតេយ្យដួលរលំនៅដើមខែមករា ឆ្នាំ១៩៧៩។ ផ្អែកលើតួនាទីដែលមានលក្ខណៈជានិមិត្តរូបភាគច្រើននោះ អង្គជំនុំជម្រះជឿជាក់ថាការទទួលខុសត្រូវរបស់ ខៀវ សំផន ដែលជាផ្នែកនៃតួនាទីនេះ គឺជាការកិច្ចការទូតនៅក្នុងកម្ពុជាប្រជាធិបតេយ្យនិងការផ្សព្វផ្សាយទូទៅអំពីមាគ៌ា ប.ក.ក. ប៉ុណ្ណោះ។

### ៨.៣.៣. សមាជិកភាពនៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍

**៦០០.** ខៀវ សំផន បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម ប.ក.ក. នៅឆ្នាំ១៩៧៦ ក្រោយពីបានធ្វើជាសមាជិកត្រៀមតាំងពីឆ្នាំ១៩៧១ មក។ ខៀវ សំផន បានលើកឡើងថា ជាផ្លូវការគណៈកម្មាធិការមជ្ឈិមគឺជា «អង្គការកំពូលរបស់បក្សទាំងមូល» ប៉ុន្តែ គាត់បានបញ្ជាក់ថាគណៈកម្មាធិការនេះ «មានតែនៅលើក្រដាសប៉ុណ្ណោះ» ដោយត្រូវកោះប្រជុំពីរដងក្នុងមួយឆ្នាំ និងមិនមែនជា«អង្គការប្រតិបត្តិ» ឡើយ។ ទោះបីជាគាត់បានអះអាងថា គណៈកម្មាធិការអចិន្ត្រៃយ៍ក៏ដោយ ប៉ុន្តែ ខៀវ សំផន បានទទួលស្គាល់ថា គណៈកម្មាធិការមជ្ឈិមបានចេញសេចក្តីបង្គាប់នានា ដែលមានបំណងណែនាំដល់ «ការប្រព្រឹត្តហួសហេតុ» និងកែលម្អលក្ខខណ្ឌមួយចំនួននៅតាមជនបទ ជាពិសេសឆ្នាំដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**៦០១.** ខៀន សំផន មិនដែលធ្លាប់ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ជាផ្លូវការម្តងណាឡើយ។ ខៀវ សំផន បានទទួលស្គាល់ថា គាត់បានចូលរួមអ្វីដែលហៅថាកិច្ចប្រជុំ«បើកចំហ» ឬកិច្ចប្រជុំ «បើកទូលាយ» នៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលក្នុងកិច្ចប្រជុំនោះមានការពិភាក្សាលើប្រធានបទជាច្រើន ហើយប្រធានបទទាក់ទងនឹងតួនាទីការទូតរបស់គាត់ក៏ត្រូវបានលើកយកមកពិភាក្សាដែរ ប៉ុន្តែគាត់បានអះអាងដោយស៊ីសង្វាក់ថា គាត់មិនដែលមានមតិឬចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅអំឡុងកិច្ចប្រជុំទាំងនោះទេ។ សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា ខៀវ សំផន គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍តាមព្រឹត្តិហេតុ ហើយថា វត្តមានរបស់ ខៀវ សំផន នៅឯកិច្ចប្រជុំទាំងនេះ បានធ្វើឲ្យគាត់ក្លាយជាសមាជិកក្នុងក្រុមតូចមួយរបស់មជ្ឈិមបក្សដែលមានអំណាចនិងទទួលបានព័ត៌មានពេញលេញ។

**៦០២.** កំណត់ហេតុប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន៣៨ ត្រូវបានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដែលជាកំណត់ហេតុចាប់ពីខែសីហា ឆ្នាំ១៩៧៥ ដល់ខែមិថុនា ឆ្នាំ១៩៧៦។ ក្នុងចំណោមកំណត់ហេតុទាំងអស់នោះ មានកំណត់ហេតុចំនួន២២ ដែលមានបញ្ជីវត្តមានអ្នកចូលរួម ហើយកំណត់ហេតុចំនួន១៦ នៃកិច្ចប្រជុំបានកត់ត្រាថា« សមមិត្តហែម» មានវត្តមាន។ ជារួម ខៀវ សំផន មានវត្តមានជាច្រើនជាងគេបំផុតបន្ទាប់ពីសមាជិកអចិន្ត្រៃយ៍គឺ នួន ជា និង ប៉ុល ពត ។ នៅក្នុងការផ្តល់ចម្លើយនៅក្នុងឆ្នាំ២០០៧ ជាមួយសហចៅក្រមស៊ើបអង្កេត ខៀវ សំផន បានទទួលស្គាល់ថា បានចូលរួមកិច្ចប្រជុំប្រហែលជា១៨ដង។ កំណត់ហេតុដែលនៅសេសសល់បញ្ជាក់ថា ខៀវ សំផន ពិតជាបានចូលរួមនៅក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ទោះបីជាកំណត់ហេតុទាំងនោះមិនបញ្ជាក់អំពីការលើកឡើងរបស់អ្នកចូលរួមក្នុងកិច្ចប្រជុំក្តី ក៏ប៉ុន្តែបង្ហាញថា ខៀវ សំផន បានរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ យ៉ាងហោចណាស់ពីរ



*រូបខាងស្តាំដូរមុខ៖ ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ទទួលស្វាគមន៍ដំណើរមកដល់របស់នាយករដ្ឋមន្ត្រីភូមា នេវិន នៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*លើកដែល អំពីទំនាក់ទំនងជាមួយនឹងសម្តេច នរោត្តម សីហនុ និង «ការបោះឆ្នោត» សភាតំណាងប្រជាជន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦។*

**៦០៣.** *លើសពីនេះទៀត បើទោះបីជា ខៀវ សំផន អះអាងម្តងទៀតថា គាត់ពុំបានទទួលព័ត៌មានពេញលេញនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ និងបដិសេធអំពីការដឹងឮជាក់លាក់អំពីការបាត់ខ្លួនក្តី ក៏ប៉ុន្តែ ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែលកិច្ចប្រជុំនីមួយៗ តែងតែមានកិច្ចប្រជុំពិភាក្សាអំពីការចាប់ខ្លួន ឃោសនាការជីវភាពរស់នៅតាមជនបទ (រួមមាន ជំងឺ ជង្គាត់ ការស្លាប់ និងកង្វះស្បៀងអាហារ) ពលកម្មកុមារ កិច្ចការបរទេស ការការពារជាតិ ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម និងពាណិជ្ជកម្ម។ លើសពីនេះទៀត នៅក្នុងសៀវភៅបោះពុម្ពឆ្នាំ២០០១ ខៀវ សំផន បានរម្លឹកពីការចាប់ខ្លួននិងការបាត់ខ្លួនសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ការបាត់បង់ខ្លួនបែបនេះមិនបានបន្ថយ ទំនុកចិត្តរបស់គណៈកម្មាធិការទៅលើការដឹកនាំរបស់ ប៉ុល ពត ឡើយ។*

**៦០៤.** *អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផនមិនគ្រាន់តែនៅក្នុងក្រុមតូចមួយរបស់សមាជិក ប.ក.ក. ដែលទទួលបានព័ត៌មានពេញលេញ ដោយសារតែសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងស្ថិតនៅក្នុងតួនាទីពិសេសក្នុងបក្ស ដោយសារតែវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួន ដែលពិភាក្សានិងសម្រេចទៅលើបញ្ហាសំខាន់ៗ។*

### ៨.៣.៤. មុខងារបន្ទាប់បន្សំផ្សេងទៀត

**៦០៥.** *អង្គជំនុំជម្រះមានភស្តុតាងអំពីមុខងារផ្សេងៗរបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនស្ថិតនៅក្នុងតួនាទីជាផ្លូវការរបស់គាត់ ប៉ុន្តែដែលអង្គជំនុំជម្រះមិនអាចបញ្ចូលទៅក្នុងតួនាទីជាក់លាក់ណាមួយបាន។*

**៦០៦.** *នៅក្នុងខែមករា និង ខែកុម្ភៈ ឆ្នាំ១៩៧៦ ខៀវ សំផន បានអមព្រះរាជដំណើរសម្តេច នរោត្តម សីហនុ ទៅធ្វើព្រះរាជទស្សនកិច្ចទៅតាមទីជនបទក្នុងប្រទេសកម្ពុជា ដែលក្នុងពេលនោះបានចុះពិនិត្យមើលគម្រោងកសិកម្មនិងការដ្ឋានការងារ រួមទាំងការដ្ឋានការងារទំនប់ត្រពាំងថ្ម។*

**៦០៧.** *នៅចន្លោះពីថ្ងៃទៅ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៨ ខៀវ សំផនបានចូលរួមនិងបង្រៀនវគ្គរៀនសូត្រនយោបាយដែលធ្វើឡើងនៅបុរីកីឡា (ក-៦) និងនៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត (ក-១៥) ជាមួយនឹង នួន ជា និងជាមេដឹកនាំ ប.ក.ក. ដទៃទៀតនៅពេលនោះ។ សិក្ខាកាមចូលរួមមានចាប់ពីយុទ្ធជនរហូតដល់កម្មាភិបាល ប.ក.ក.*

និងអ្នកត្រឡប់មកពីបរទេសដែលមានចំនួនចាប់ពីរាប់សិបនាក់រហូតដល់រាប់ពាន់នាក់ ដោយពួកគេបានទទួលការបង្រៀនផ្សេងៗអំពីគោលការណ៍បដិវត្តន៍ សហករណ៍ បច្ចេកទេសកសិកម្ម និងបញ្ហាសេដ្ឋកិច្ច ដោយ ខៀវ សំផនបានបង្រៀនពីវិធីកំណត់អត្តសញ្ញាណ«ខ្មាំង» និងស្វែងរក«ជនក្បត់»។ សាក្សី អ៊ុង ចុងហៀង ដែលបានបញ្ជាក់នៅក្នុងការស្តាប់ចម្លើយក្រៅផ្លូវតុលាការ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៨ ថា ខៀវ សំផន «មកបឹងត្របែកដើម្បីដឹកនាំប្រជុំនយោបាយ» ដោយបានបន្ថែមទៀតថាភរិយារបស់គាត់ឃើញ «ខៀវ សំផន ប្រជុំទីនោះ»។ សាក្សីបានបដិសេធនៅពេលគាត់សម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស.ថា គាត់មិនដែលបានឆ្លើយបែបនេះទេ ហើយគាត់ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថា ទាំងគាត់និងភរិយារបស់គាត់ ពុំដែលបានឃើញ ខៀវ សំផន នៅ ទីតាំងនោះឡើយ។ អ្នកបើកបររបស់ ខៀវ សំផន គឺជាសាក្សី ឡុង ឈឿនមិនបានចាំថាគាត់ធ្លាប់បើក ឡានជូន ខៀវ សំផន ទៅបឹងត្របែកឡើយ។ ទោះបីជាអង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ខៀវ សំផន បានដឹកនាំវគ្គរៀនសូត្រនយោបាយនៅបឹងត្របែកក្តី តែអង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន ពិតជាធ្លាប់ចូលរួមនិងដឹកនាំវគ្គរៀនសូត្រនយោបាយនៅបុរីកីឡា និងវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ- សូវៀត។

## ៨.៣.៤.១. សមាជិកភាពមន្ទីរ ៨៧០

**៦០៨.** *មន្ទីរ៨៧០ គឺជាមន្ទីរដែលត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមន្ទីរនេះដំបូងមានសមាជិកពីររូបយ៉ាងតិចគឺសៀវ៉ាស៊ីហោ ឌឿនដែលត្រូវបានតែងតាំងជាប្រធានមន្ទីរនៅខែតុលា ឆ្នាំ១៩៧៥ និងខៀវ សំផនដែលចូលរួមប្រហែលជានៅពេលជាមួយគ្នានោះដែរ។*

**៦០៩.** *សហព្រះរាជអាជ្ញាអះអាងថា ខៀវ សំផនបន្តតំណែងពី ឌឿនជាប្រធានមន្ទីរ៨៧០ ពេលដែល ឌឿនត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧។ ខៀវ សំផន បានបដិសេធម្តងហើយម្តងទៀតថា ខ្លួនមិនដែលត្រូវបានតែងតាំងជាប្រធានមន្ទីរ៨៧០ ឬបំពេញការងារក្នុងតួនាទីដូចនេះទេ ហើយបានអះអាងថា គាត់គ្រាន់តែទទួលខុសត្រូវទៅលើ ការរក្សាទំនាក់ទំនងជាមួយសម្តេចនរោត្តម សីហនុ ការកំណត់តម្លៃផលិតផលដែលសហ-ករណ៍ផ្សេងៗបង្កើតបាន និងអង្គភាពសេដ្ឋកិច្ចដទៃទៀត*



*រូបខាងស្តាំ៖ ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) អមដំណើរនាយករដ្ឋមន្ត្រីភូមា នេវិន ធ្វើទស្សនកិច្ច។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

អនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ទាក់ទងនិងការបែងចែកផលិតផលផ្សេងៗទៅកាន់បណ្តាភូមិភាគ និងធ្វើការផ្សារលើការនាំចេញជាមួយ «នាយកដ្ឋានពាណិជ្ជកម្មបរទេស» តែប៉ុណ្ណោះ។ ខៀវ សំផន បានអះអាងថា ទោះបីជាអាចមាន ឬមិនមានការផ្លាស់ប្តូរទំនិញរវាងសហករណ៍នោះ ការទទួលខុសត្រូវរបស់ខ្លួនទៅលើការរៀបចំតម្លៃផលិតផល គឺគ្រាន់តែជាទ្រឹស្តីតែប៉ុណ្ណោះ។ មុខងាររបស់គាត់ទាក់ទងនឹងពាណិជ្ជកម្ម និងការនាំចេញ នាំចូល និងត្រូវពិភាក្សានៅផ្នែកខាងក្រោម។

**៦១០.** ខៀវ សំផន ទទួលស្គាល់ថាគាត់ធ្វើការនៅមន្ទីរ៨៧០ រហូតដល់ឆ្នាំ១៩៧៨ ប៉ុន្តែបានអះអាងថា ខ្លួនពុំបានដឹងអំពីតួនាទីពិតប្រាកដរបស់ ឌឿន ជាប្រធានមន្ទីរ៨៧០ឡើយ។ ខៀវ សំផនបានចងចាំថា ឌឿន អវត្តមានជាញឹកញាប់ ដោយសារត្រូវធ្វើដំណើរទទួលរបាយការណ៍បណ្តាភូមិភាគ និង «ទទួលកិច្ចការនយោបាយ»។ មន្ទីរ៨៧០ នៅតែបន្តបំពេញមុខនាទីរបស់ខ្លួនបន្ទាប់ពី ឌឿន ត្រូវបានចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ១៩៧៧ ដោយទូរលេខមួយចំនួនដែលមាននៅចំពោះអង្គជំនុំជម្រះចុះកាលបរិច្ឆេទក្នុងឆ្នាំ១៩៧៧ ហើយផ្ញើទៅ«មន្ទីរ៨៧០»។

**៦១១.** ខៀវ សំផន សន្និដ្ឋានថា ឈឹម សំអោក ហៅ ប៉ង់ អាចឡើងជំនួស ឌឿន ជាប្រធានមន្ទីរ៨៧០។ សាក្សី សា ឡុតបាន, រ៉ចាម តុន ហៅ ភី ភួន, ពាន យាន និង នឹម សែម បានផ្តល់សក្ខីកម្មដែរថា ប៉ង់ ធ្លាប់ជាប្រធានមន្ទីរ៨៧០។ សា ឡុតបានបានចងចាំថាបានឃើញប៉ង់ និង ឌឿន ធ្វើការនៅ ក-១ ឬមន្ទីរ៨៧០ នៅក្នុងពេលតែមួយ ដោយទទួលគ្រប់គ្រងក្រសួង និង«ចែកចាយភស្តុភារ» តាមតួនាទីរបស់ពួកគេរៀងៗខ្លួន។ ភី ភួន បានបញ្ជាក់ពីតួនាទីផ្សេងៗរបស់បុគ្គលទាំងពីរនាក់នេះ ដោយបញ្ជាក់ថា ប៉ង់ ទទួលខុសត្រូវលើការងារ «រដ្ឋបាល» ប្រចាំថ្ងៃ (សាក្សី ពាន យាន ក៏បានអះអាងបែបនេះដែរ) ចំណែក ឌឿន ទទួលខុសត្រូវលើ «គោលនយោបាយ» ដែលរួមមានការបើក បំទវគ្គរៀនសូត្រ។ អង្គជំនុំជម្រះកត់សម្គាល់ថា ទោះបីជាសក្ខីកម្មទាំងនេះ ត្រឹមត្រូវមួយផ្នែកដោយសារតែមុខងារដែលមានតែឈ្មោះ ដែលត្រូវបានអះអាងថាបានផ្តល់ជូននៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ នាថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ក្តីតែសាក្សីទាំងនេះ ទំនងជាច្រឡំគ្នារវាងមុខងារមន្ទីរ៨៧០ និងមន្ទីរ ស-៧១។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចជឿជាក់ថា ប៉ង់ គឺជាប្រធានមន្ទីរ៨៧០ ឡើយ។

**៦១២.** សាក្សីនិងអ្នកជំនាញមួយចំនួនផ្តល់សក្ខីកម្មថា ខៀវ សំផន គឺជាអ្នកឡើងជំនួស ឌឿន ជាប្រធានមន្ទីរ៨៧០។ សាក្សី កាំ ហ្គេកអ៊ាវ ហៅ ឌុច បានផ្តល់សក្ខីកម្មថា មន្ទីរដែលមានឌឿន ជាប្រធាន គេហៅថា «មន្ទីរមជ្ឈិម» ជាមន្ទីរមួយដែលគាត់ហៅថាជា «មន្ទីរ៨៧០» នៅក្នុងការស្តាប់ចម្លើយរបស់គាត់កន្លងមកជាមួយសហចៅក្រមស៊ើបអង្កេត។ ទោះបីជាគាត់បានផ្តល់សក្ខីកម្មដងដែរថា ខៀវ សំផន មានតួនាទីនៅមន្ទីរ៨៧០ ធំជាង ឌឿន ទៅទៀត ហើយក្រោយពេលឌឿនចេញទៅខៀវ សំផនក៏កាន់តំណែងនេះ ក៏ប៉ុន្តែ ឌុច បានទទួលស្គាល់នៅចំពោះមុខសហចៅក្រមស៊ើនអង្កេតថា គាត់ដឹងតិចតួចណាស់អំពីកិច្ចការនៅមន្ទីរ៨៧០ និងបានបញ្ជាក់ជាច្រើនលើកថា ការលើកឡើងរបស់គាត់អំពីតួនាទីរបស់ ខៀវ សំផន នៅមន្ទីរនោះគឺជាការសន្និដ្ឋានពីតួនាទីជាន់ខ្ពស់ជាទូទៅរបស់ ខៀវ សំផន នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីអត្ថបទសិក្សាស្រាវជ្រាវ និងពីពាក្យចចាមអារ៉ាម។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ដងដែរថា សាក្សីមានសិទ្ធិក្នុងការចូលពិនិត្យសំណុំរឿង ក្នុងនាមជាជនជាប់ចោទក្នុងសំណុំរឿង០០១ និងជាជនសង្ស័យក្នុងសំណុំរឿង០០២ ដែលនាំឲ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានថា សក្ខីកម្មរបស់ ឌុច មិនបានផ្តល់មូលដ្ឋានឯករាជ្យគ្រប់គ្រាន់សម្រាប់ការសម្រេចលើអង្គហេតុលើប្រធានបទនិងអំណះអំណាងពីតួនាទីរបស់ ខៀវ សំផន ជាប្រធានមន្ទីរ៨៧០នេះ។

**៦១៣.** កិច្ចសម្ភាសន៍ក្រៅតុលាការចំនួនពីរដែលរៀបចំដោយ Stephen HEDER បង្ហាញ ខៀវ សំផន បានក្លាយជាប្រធានមន្ទីរ៨៧០ បន្ទាប់ពីការចាប់ខ្លួន ឌឿន។ កិច្ចសម្ភាសន៍ទីមួយគឺជាកិច្ចសម្ភាសន៍ជាមួយ វ៉ាន់ រិត ជាអ្នកដឹកនាំម្នាក់នៃគណៈកម្មាធិការពាណិជ្ជកម្មនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដោយសព្វថ្ងៃ

វ៉ាន់រិតបានទទួលមរណភាពទៅហើយ។ បើ ទោះបីជាលោក Stephen HEDER (ជាសាក្សីដែលអង្គជំនុំជម្រះយល់ថា អាចជឿទុកចិត្តបានជាទូទៅក្តី) បានផ្តល់សក្ខីកម្ម ទាក់ទងនឹងកាលៈទេសៈនៃការធ្វើកិច្ចសម្ភាសន៍នេះក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចផ្តល់ទម្ងន់ធំធេងចំពោះកំណត់ហេតុនៃកិច្ចសម្ភាសន៍ដែលសរសេរដោយដៃរបស់គាត់ឡើយ។

**៦១៤.** កិច្ចសម្ភាសន៍ទីពីរគឺជាកិច្ចសម្ភាសន៍ជាមួយ អៀង សារី នៅក្នុងឆ្នាំ១៩៩៩។ បើតាមកំណត់ត្រាកិច្ចសម្ភាសន៍របស់ Stephen HEDER អៀង សារី បានអះអាងបញ្ជាក់ពីការ «តែងតាំង ខៀវ សំផន ជាប្រធានមន្ទីរ៨៧០»។ អៀង សារី បានដាក់សេចក្តីប្រកាសដោយមានចុះហត្ថលេខាជូនទៅសហចៅក្រមស៊ើបអង្កេតនៅក្នុងឆ្នាំ២០០៩ ដោយអះអាងថា គាត់មិនដែលបាននិយាយបែបនេះទេ។ នោះជាយ៉ាងនេះក្តី សាក្សី ភី ភួន បានផ្តល់សក្ខីកម្មដាច់ដោយឡែកថាបន្ទាប់ពី ឡឿន បាត់ខ្លួន អៀង សារី បានប្រាប់គាត់ថា «ខៀវ សំផន ត្រូវទៅជំនួស ឡឿន» ហើយបង្គាប់ឲ្យគាត់ទាក់ទងជាមួយ ខៀវ សំផន ដោយផ្ទាល់។ ព័ត៌មានរបស់ ភី ភួន មិនត្រូវបានសួរដេញដោលបន្ថែមនៅក្នុងតុលាការនោះឡើយ។ អៀង សារី ជាបុគ្គលដែលត្រូវបានគេអះអាងថាបានធ្វើការប្រកាសការអះអាងនេះ ក៏មិនមានវត្តមាននៅក្នុងសវនាការដើម្បីបញ្ជាក់ទៅលើព័ត៌មានដែលមានភាពខុសគ្នាទាំងនេះដែរ។ លើសពីនេះទៀត ទោះបីជា ភី ភួន បានបញ្ជាក់ថា ឡឿន បាត់ខ្លួននៅក្នុងឆ្នាំ១៩៧៨ ក្តី តែគាត់ហាក់ដូចជាយល់ច្រឡំការចាប់ខ្លួន ឡឿន (ដែលផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះថាកើតឡើងនៅក្នុងឆ្នាំ១៩៧៧) ជាមួយនឹងការចាប់ខ្លួន។ ដោយសារតែបញ្ហានេះ អង្គជំនុំជម្រះមិនអាចផ្តល់ទម្ងន់សំខាន់ដែលកំណត់ត្រាកិច្ចសម្ភាសន៍របស់ Stephen HEDER ឡើយ។

តនៅលេខក្រោយ



ខៀវ សំផន (រូបទី៤រាប់ពីស្តាំ) អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ជួបជាមួយព្រះអង្គម្ចាស់ សុផានុវង្ស (រូបទី៥រាប់ពីស្តាំ) ប្រធានរដ្ឋឡាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សមរភូមិផ្លូវច្បាប់ចុងក្រោយបង្អស់
## នៅក្នុងការកាត់សេចក្តីនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

**លី សុខឃាង**




ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) នៅក្នុងសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពីថ្ងៃច័ន្ទ ទី១៦ ដល់ថ្ងៃព្រហស្បតិ៍ ទី១៩ ខែសីហា ឆ្នាំ២០២១។ (អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា)



ដំណើរការនៃការកាត់សេចក្តីចុងក្រោយបង្អស់លើ ខៀវ សំផន អតីតប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យបានបិទបញ្ចប់ នៅក្នុងខែសីហា ឆ្នាំ២០២១។ ដំណើរការតុលាការនេះគឺចំណុចរបត់សំខាន់មួយសម្រាប់ប្រវត្តិសាស្ត្ររបស់យើង។ ខណៈដែលការពិតខ្លះត្រូវបានរកឃើញ សន្តិភាពក៏ចាប់ផ្តើមចាក់ឫសជ្រៅថែមទៀត។

ចាប់តាំងពីឆ្នាំ២០០៦មកម្ល៉េះ ដំណើរការរបស់តុលាការបានបង្កឲ្យមានប្រតិកម្មយ៉ាងច្រើននៅក្នុងចំណោមប្រជាជនកម្ពុជា។ កាលពីដើមឡើយ ប្រជាជនកម្ពុជាជាច្រើនបានបង្ហាញចេញនូវការខកចិត្តដែលអតីតមេដឹកនាំខ្មែរក្រហមមួយចំនួនតូចប៉ុណ្ណោះនឹងត្រូវនាំយកទៅជំនុំជម្រះទោស និងការដាក់ទោសទណ្ឌយ៉ាងស្រាលទៅលើ កាំង ហ្កិចអ៊ាវ ហៅ ឌុច នៅឯអង្គជំនុំជម្រះសាលាដំបូង (ក្រោយមក ឌុច ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ដោយតុលាការកំពូល)។ តែទោះជាយ៉ាងណាក៏ដោយ ការដែលបានឃើញពីការបិទបញ្ចប់ដំណើរការនៃការស្វែងរកយុត្តិធម៌អស់ជាងមួយទសវត្សរ៍កន្លងមកនេះ ហាក់ទទួលបាននូវភាពរសាយចិត្តច្រើន។

បើទោះជាមានការពន្យាពេលផ្សេងៗនៅក្នុងដំណើរការតុលាការក៏ដោយ បទពិសោធប្រកាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានស្គាល់ជាទូទៅថាជា តុលាការខ្មែរក្រហម បានទាញចំណាប់អារម្មណ៍របស់ប្រជាជនកម្ពុជា។ អស់រយៈពេលជាច្រើនឆ្នាំនៃការតស៊ូក្នុងសមរភូមិ

ផ្លូវច្បាប់ ប្រជាជនកម្ពុជាក៏បានចាប់អារម្មណ៍ចំពោះភាពអយុត្តិធម៌នៃការរស់នៅរបស់អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅក្នុងបន្ទប់ឃុំខ្លួនបណ្ដោះអាសន្នរបស់តុលាការខ្មែរក្រហម។ សាធារណជនមានភាពអាក់អន់ស្រពន់ចិត្តដោយសារតែការរៀបចំយ៉ាងសមរម្យរបស់តុលាការ ខណៈដែលអតីតមេដឹកនាំខ្មែរក្រហមទាំងនោះធ្លាប់បានបដិសេធសិទ្ធិរស់រានមានជីវិតរបស់ជនរងគ្រោះជាច្រើននាក់ ក្នុងអំឡុងរបបគ្រប់គ្រងរបស់ខ្លួន។ ប្រជាជនកម្ពុជាបានរិះគន់ពីការរៀបចំយ៉ាងសមរម្យនេះសម្រាប់អតីតមេដឹកនាំខ្មែរក្រហម ដោយរាប់បញ្ចូលទាំងបន្ទប់ស្នាក់នៅបំពាក់ម៉ាស៊ីនត្រជាក់ ការពិនិត្យសុខភាពជាទៀងទាត់ និងការទទួលបានវ៉ាក់សាំងកូវីដ១៩ ខណៈដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមខ្លះនៅរង់ចាំការទទួលបានវ៉ាក់សាំងប្រឆាំងនឹងមេរោគរាតត្បាតនេះ។ តែទោះយ៉ាងណា ទាំងអស់នេះគឺជាបទដ្ឋានមូលដ្ឋានរបស់តុលាការជាតិនិងអន្តរជាតិមួយនេះ ដែលការរៀបចំដ៏សមរម្យត្រូវបានផ្ដល់ជូនដើម្បីធានាបានថា ភាគីនៅក្នុងសំណុំរឿងក្ដីមានកាយសម្បទា និងស្មារតីពេញលេញក្នុងការបង្ហាញវត្តមានដើម្បីស្ដាប់ និងឆ្លើយតបចំពោះបទចោទប្រកាន់ទាំងឡាយប្រឆាំងមកលើខ្លួន។

ខៀវ សំផន ដែលជាមេដឹកនាំខ្មែរក្រហមវ័យចំណាស់និងជាសម្ព័ន្ធមិត្តដ៏ឥតងាករេរបស់ ប៉ុល ពត បានលៃលកប្រើប្រាស់វេទិការបស់តុលាការខ្មែរក្រហមនេះដើម្បីការពារទង្វើរបស់ខ្លួន និងរបបខ្មែរក្រហម លុះដល់ដង្ហើមចុងក្រោយនៃជីវិតរបស់ខ្លួន។ ខៀវ សំផន នៅតែមិនផ្លាស់ប្ដូរ និងមិនមានវិប្បដិសារីចំពោះការបាត់បង់អាយុជីវិតរបស់ប្រជាជនកម្ពុជាជិតពីរលាននាក់ ឬស្ថានភាពរស់នៅដ៏លំបាករបស់ប្រជាជនកម្ពុជា នៅក្រោមគោលនយោបាយប្រល័យពូជសាសន៍របស់របបខ្លួនឡើយ។ ជាជំនួសវិញ ខៀវ សំផន នៅតែទទូចថា គោលនយោបាយរបស់ខ្លួនមានតម្លៃដែលបម្រើប្រយោជន៍របស់ប្រទេសជាតិ។ ហម សឿន ដែលមានវ័យ៦៨ឆ្នាំ និងបានរស់នៅក្នុងស្រុកអន្លង់វែងចាប់តាំងពីដើមឆ្នាំ២០០០មកម្ល៉េះ និងពេជ្រ សារេន ដែលមានវ័យ៦៧ឆ្នាំ និងជាអតីតទាហានខ្មែរក្រហមនៅក្នុងអតីតតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហមនៅអន្លង់វែង បានចែករំលែកទស្សនៈរបស់ខ្លួនថា យុត្តិធម៌គួរជាទីទុកចិត្តបានគួរតែមានតុល្យភាពជាមួយអង្គហេតុពិតក្នុងអំឡុងនៃការកាន់តំណែងជាប្រធានគណៈប្រធានរដ្ឋរបស់ ខៀវ សំផន ផង។ តាមពិតទៅ សឿម គាំទ្រសិទ្ធិសម្ដែងមតិយោបល់របស់ ខៀវ សំផន ហើយជឿជាក់ថា មិនមែនគ្រប់គោលនយោបាយរបស់ ខៀវ សំផន សុទ្ធសឹងតែជាកំហុសនោះទេ។

បើទោះជាមានទស្សនៈដទៃពីគ្នាក៏ដោយ ទាក់ទងនឹងលទ្ធផលនៃការជំនុំជម្រះ ដំណើរការដ៏សមស្រប និងយុត្តិធម៌គួរតែកេរដំណែលដ៏មានសារសំខាន់របស់តុលាការខ្មែរក្រហម។ ដំណើរការតុលាការនេះបានបង្រៀនប្រទេសយើងអំពីសារប្រយោជន៍នៃភាពស្មើគ្នាចំពោះមុខច្បាប់ ដើម្បីបង្កើតបាននូវសន្តិភាព។ ការកាត់ទោសគឺជាសញ្ញាណដែលបង្ហាញថា បទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍មិនអាចគេចផុតពីការដាក់ទោសទណ្ឌឡើយ។ ការកាត់ទោសនេះក៏បានធ្វើឲ្យប្រទេសកម្ពុជាទទួលបាននូវការគោរពពីសំណាក់ប្រជាជាតិដទៃទៀតដែរ ដែលបង្ហាញថាប្រទេសកម្ពុជាបានផ្ដល់អាទិភាពខ្ពស់ក្នុងដំណើរកាត់ទោស ដើម្បីធ្វើជាគន្លឹះក្នុងការកសាងសន្តិភាព និងការផ្សះផ្សាប្រកបដោយចីរភាព។ ជាចុងក្រោយ ដំណើរការនៃការកាត់ទោសនេះក៏ជាជំហានច្បាស់លាស់ និងប្រកបដោយអត្ថន័យកំណត់សម្រាប់ការបែងចែកឲ្យដាច់ស្រឡះពីគ្នារវាងអតីតមេដឹកនាំកំពូលរបស់ខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលក្នុងនោះរាប់បញ្ចូលទាំងអតីតសមាជិកខ្មែរក្រហមគ្រប់លំដាប់ថ្នាក់ផង។

# «ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ម៉ាក ទុន ៖ អ្នកធាក់ស៊ីក្លូ

**ដោយ ៖ ផាង ពីរ័ន្ត និង វេនី ខករម្ភៀល**

**រៀបរាប់ដោយប្រពន្ធរបស់គាត់ឈ្មោះ ឈុន យឿន ៖**

ខ្ញុំបានរៀបការជាមួយបុរសពីរនាក់។ បុរសទាំងពីរគឺសុទ្ធតែជាសាច់ញាតិរបស់ខ្ញុំ។ ខ្ញុំត្រូវបានរៀបចំឲ្យរៀបការដំបូងនៅក្នុងទីក្រុងភ្នំពេញជាមួយបុរសកសិករម្នាក់មកពីភូមិរបស់ខ្ញុំ។ ក្រោយពេលយើងរៀបការរួច គាត់បានជួយលក់នំក្នុងហាងក្បែរផ្សារអូឫស្សី ចំណែកខ្ញុំធ្វើស្រែចម្ការ។ ទោះបីជាគាត់រកចំណូលបាន១.៣០០រៀលក្នុងមួយខែក៏ដោយ ក៏គាត់មិនដែលឲ្យលុយទាំងនោះមកខ្ញុំដែរ។ បន្ទាប់ពីយើងរៀបការជាមួយគ្នាបានរយៈពេល ៩ខែមក ខ្ញុំបានសម្រេចចិត្តលែងលះជាមួយគាត់។ យើងមិនដែលរស់នៅចុះសម្រុងជាមួយគ្នាទេ។

ការរៀបការលើកទី២របស់ខ្ញុំគឺខុសគ្នា។ ខ្ញុំគឺជាអ្នកធ្វើការសម្រេចចិត្តថាគួររៀបការជាមួយនរណា។ ឆ្នាំបន្ទាប់មក ខ្ញុំបានរៀបការជាមួយ ម៉ាក ទុន។ គាត់ធ្លាប់បានសិក្សានៅក្នុង



ម៉ាក ទុន អាយុ២០ឆ្នាំ
ក្នុងអំឡុងឆ្នាំ១៩៦០ នៅភ្នំពេញ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វត្តកោះស្តេច និងធ្លាប់បួសជាសង្ឃ។ គាត់គឺជាបុរសចិត្តល្អ សន្ដូរ ប៉ុន្តែមិនសូវមានចំណេះដឹងជ្រៅជ្រះទេ។

ខ្ញុំក៏គ្មានចំណេះដឹងជ្រៅជ្រះដែរ ពីព្រោះក្រុមគ្រួសាររបស់ខ្ញុំមានជីវភាពក្រីក្រណាស់។ ពេលខ្ញុំមានអាយុ១៥ឆ្នាំ ខ្ញុំបានរៀនថ្នាក់អនក្ខរកម្ម។ ខ្ញុំបានសិក្សាអស់រយៈពេល១ឆ្នាំ ហើយជាសិស្សពូកែជាងគេក្នុងចំណោមសិស្ស២០នាក់ផ្សេងទៀត។

ក្រោយពេលរៀបការលើកទីពីរ ខ្ញុំបានធ្វើនំត្នោត និងតាប៉ែ លក់នៅទីក្រុងភ្នំពេញ។ ទុន គឺជាអ្នកធាក់ស៊ីក្លូ។ ជួនពេលខ្លះ គាត់មកហូបបាយនៅផ្ទះ ប៉ុន្តែជាទូទៅគាត់ត្រឡប់មកផ្ទះវិញក្នុងមួយសប្តាហ៍ម្តង។

នៅអំឡុងរបបលន់ នល់ ខ្មែរក្រហមបានកាន់កាប់ភូមិរបស់ខ្ញុំរួចទៅហើយ និងមានការទម្លាក់គ្រាប់បែកជារឿយ ដូចច្នេះ ក្រុមគ្រួសាររបស់ខ្ញុំ និងអ្នកភូមិផ្សេងទៀតបានផ្លាស់ប្តូរមកនៅខាងក្រៅក្រុងបន្តិចគឺនៅម្តុំចំការដូង។ ប្តីរបស់ខ្ញុំបានសង់ខ្ទមមួយ។ វាមានទំហំដែលអាចដាក់បានត្រឹមតែគ្រែមួយប៉ុណ្ណោះ ហើយយើងបានរស់នៅទីនោះអស់រយៈពេល៣ឆ្នាំ។ គាត់បានជួយខ្ញុំធ្វើទឹកត្នោត និងស្រែចម្ការ។ យើងមានកូនមួយ។

នៅពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កូនប្រុសទីពីររបស់ខ្ញុំមានអាយុត្រឹមតែមួយខែតែប៉ុណ្ណោះ។ វាពិតជាលំបាកខ្លាំងណាស់នៅពេលដែលខ្ញុំ

ដើរ និងបីកូនរបស់ខ្ញុំក្នុងពេលដំណាលគ្នា ពីព្រោះខ្ញុំងងឹតភ្នែកនៅពេលយប់ (ខ្វាក់មាន់)។ ប្តីរបស់ខ្ញុំបានទុកដាក់សម្ភារនៅលើរទេះគោ និងធ្វើដំណើរឆ្ពោះទៅខេត្តកណ្តាល ប៉ុន្តែយោធាខ្មែរក្រហមបានប្រាប់យើងឲ្យធ្វើដំណើរទៅកាន់ខេត្តសៀមរាបជំនួសវិញ។ នៅពេលដែលពួកយើងធ្វើដំណើរទៅដល់ទីនោះ ប្តីរបស់ខ្ញុំបានចាប់ផ្តើមសាងសង់កន្លែងស្នាក់នៅសម្រាប់យើង។ កន្លងទៅអស់រយៈពេលប្រហែល៨ទៅ៩ខែ គាត់បានរៀបចំប្រក់ដំបូលខ្ទមជាមួយនឹងស្លឹកត្នោត។ យើងចំណាយរយៈពេលប្រហែល១ឆ្នាំ ដើម្បីបានផ្ទះត្រឹមត្រូវមួយសម្រាប់ស្នាក់នៅ។

ប្តីរបស់ខ្ញុំបានធ្វើការងារនៅក្នុងកងភ្ជួររាស់ ចំណែកការងាររបស់ខ្ញុំគឺដាំបបរឲ្យជ្រូកនិងសាបព្រោះ។ ជួនពេលខ្លះ ខ្ញុំបានព្រោះស្រូវទាំងយប់ទាំងថ្ងៃ។ ខ្ញុំមិនដែលខ្ជិលច្រអូស និងខ្ជះខ្ជាយចំពោះការងាររបស់ខ្ញុំនោះទេ ពីព្រោះខ្ញុំខ្លាចស្លាប់។ អ្នកដែលខ្ជិលត្រូវបានខ្មែរក្រហមយកទៅនៅពេលយប់ និងសម្លាប់ចោល។ ស្ត្រីម្នាក់ដែលរស់នៅក្បែរខ្ទមរបស់ខ្ញុំបានត្អូញត្អែរអំពីការខ្វះខាតអាហារ និងសួរថាតើស្រូវអង្ករដែលធ្វើបានទាំងអស់នោះយកទៅណា។ អង្គការបានចាប់ខ្លួនគាត់ និងប្តីរបស់គាត់។ អង្គការបានយកអ្នកទាំងពីរទៅ ហើយទុកកូនៗរបស់គាត់នៅក្នុងកងកុមារ។

នៅថ្ងៃទី១០, ២០ និង៣០ ប្រចាំខែ អង្គការបានកោះហៅប្រជាជនឲ្យចូលរួមការប្រជុំដែលនិយាយអំពីភាពស្មើគ្នានៅក្នុងការធ្វើការងារ និងការបង្កបង្កើនផល។ ខ្ញុំសង្ស័យថាស្រូវទាំងអស់ត្រូវបានរក្សាទុកនៅក្នុងជង្រុក ពីព្រោះប្រជាជនអត់ឃ្លានខ្លាំងណាស់។

នៅក្នុងភូមិរបស់យើង ប្រជាជនថ្មីគ្មានសិទ្ធិនិយាយស្តីទេ។ ទោះបីជាខ្ញុំដើរទៅធ្វើការ ហើយឃើញប្តីរបស់ខ្ញុំនៅតាមផ្លូវ ក៏ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យក្រឡេកមើលមុខរបស់គាត់ដែរ។ នៅពេលដែលខ្ញុំឈឺដេកនៅក្នុងមន្ទីរពេទ្យ អង្គការមិនអនុញ្ញាតឲ្យប្តីរបស់ខ្ញុំមកមើលថែខ្ញុំឡើយ។ ថ្នាំដែលពេទ្យឲ្យខ្ញុំគឺជាថ្នាំដែលធ្វើពីឬសឈើ ដែលមើលទៅស្រដៀងនឹងអាចម៍ទន្សាយ។



ឈុន ឃឿន នៅភ្នំពេញ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៧៧ ឈឿន ប្រធានកងស្នើប្តីរបស់ខ្ញុំឲ្យដូរគោជាមួយគាត់។ ទុន មិនយល់ព្រមដូរគោនោះទេ ពីព្រោះយើងបានយកគោនោះមកជាមួយយើងតាំងពីភ្នំពេញ។ បន្ទាប់មក អង្គការបានចោទប្រកាន់ប្តីរបស់ខ្ញុំថាជាវរសេនីយ៍ឯក។ មួយខែក្រោយមក អង្គការបានហៅគាត់និងបុរសប្រហែល៨០នាក់ផ្សេងទៀតទៅកាប់ឆ្ការព្រៃ។ ម៉ោងប្រហែល៧ព្រឹក យោធាខ្មែរក្រហម ២នាក់បានយកប្តីខ្ញុំ និងបុរសទាំងនោះចេញទៅក្រៅភូមិ។ មេភូមិបានប្រាប់ខ្ញុំកុំឲ្យបារម្ភពីព្រោះប្តីខ្ញុំនឹងត្រឡប់មកវិញនៅក្នុងរយៈពេល ៩ខែ និង១០ថ្ងៃក្រោយមក។

អ្នកភូមិបានលួចខ្សិបប្រាប់ខ្ញុំថា ៩ខែនិង១០ថ្ងៃ មានន័យថាប្តីរបស់ខ្ញុំត្រូវបានសម្លាប់និងចាប់ជាតិថ្មីហើយ។ ស្ត្រីផ្សេងទៀតដែលប្តីរបស់គាត់ត្រូវបានអង្គការនាំយកទៅដែរនោះបានប្រាប់ខ្ញុំថា គាត់បានឃើញយោធាខ្មែរក្រហមនាំប្តីរបស់ខ្ញុំទៅកាន់គុកស្អាង ហើយអ្នកដែលត្រូវបាននាំយកទៅគុកស្អាងនោះគឺកម្រនឹងមានជីវិតរស់ណាស់។ ខ្ញុំមិនបានទទួលដំណឹងពីប្តីរបស់ខ្ញុំទេ ចាប់តាំងពីពេលនោះមក។

ខ្ញុំពិតជាមានអារម្មណ៍សោកស្តាយជាខ្លាំងដែលខ្ញុំមិនបានជួបប្តីរបស់ខ្ញុំជាលើកចុងក្រោយ។

**ប៉ាង ពីច័ន្ទ និង ទេរី ខកហ្គៀល**

រូបក្របមុខ៖

ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩) ត្រូវបានចាប់ខ្លួនពីផ្ទះរបស់គាត់ នៅក្នុងខេត្តប៉ៃលិន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ និងបញ្ជូនតាមឧទ្ធម្ភាគចក្រមកឃុំឃាំងនៅអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

ខៀវ សំផន (នៅ ខាងឆ្វេង) អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ ១៩៧៥ - ១៩៧៩) ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 260, August 2021 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.